01675051

F1/9.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Court Suprême

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការបណ្តឹងសាទុក្ខ
# ក្នុងសំណុំរឿង ០០២/០២
## សាធារណៈ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

**ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១**

**ម៉ោង ០៩:១៨ នាទី**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-21, 14:40
CMS/CFO: Sann Rada

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រ៊ីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម ម៉ូរីន ហាឌីង ក្លាក
*(Judge Maureen Harding CLARK)*

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា

ចៅក្រម ផ្លរិនស៍ ដេផេល វ៉ាឈិន-មុំមបា
*(Judge Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

កញ្ញា ភីស ម៉ាល្លេនី *(Ms. Peace Malleni)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី ប្រេនដា ហូលិស
*(Ms Brenda J. HOLLIS)*

លោក សេង ប៊ុនឃាង

លោកស្រី នីសា ប៉ាតែល *(Ms Nisha Patel)*

លោកស្រី ហេឡេន វើសនុប *(Ms Helen Worsnop)*

លោកស្រី រូថ ម៉ារី ហេគ្គ័រ
*(Ms Ruth Mary Hackler)*

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr.Vincent de wilde d'Estmael)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី មេហ្គិន ហឺសត៍ *(Ms. Megan Hirst)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ុនណា

**មេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ *(Ms. Anta GUISSE )*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម គង់ ស្រ៊ីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូរីន ហាឌីង ក្លាក | អង្គគ្លេស |
| ចៅក្រម សោម សិរិវឌ្ឍ | ខ្មែរ |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី ហេឡេន វើសនុប | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| ក្រឡាបញ្ជី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញបាទ!

[០៩:១៨:១៧]

**ប្រធានអង្គជំនុំ៖**

តាងនាមអង្គការសហប្រជាជាតិ និងប្រជារាស្ត្រខ្មែរ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក សូមប្រកាសបើកសវនាការជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ភាគីប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយត្រូវបានចេញនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ដែលជនជាប់ចោទ ខៀវ សំផន បានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខជាច្រើន និងលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលមានតែមួយទឡ្ហីករណ៍។

សមាសភាពចៅក្រមអង្គជំនុំជម្រះតុលាការកំពូលៈ ទី១ ខ្ញុំ គង់ ស្រីម ប្រធាន, ទី២ ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ, ទី៣ ចៅក្រម  ម៉ុង មុន្នីចរិយា, ទី៤ ចៅក្រម សោម សិរិវុឌ្ឍ, ទី៥ ចៅក្រម ផ្លូរិនស៍ ដេផេល វ័រឈិន-ម៉ុមបា, ទី៦ ចៅក្រម យ៉ា ណារិន, និងទី៧ ចៅក្រម ម៉ូរីន ហាឌីង ក្លាក។ សមាសភាពចៅក្រមបម្រុង ១) ចៅក្រម ស៊ីន រិទ្ធ ២) ចៅក្រម ហ្វីលីព រ៉ាប៉ូហ្សា ដែលត្រូវបានចូលរួមពីចម្ងាយ។ ក្រឡាបញ្ជី លោក ស៊ា ម៉ៅ, ទី២ លោកស្រី ភីស ម៉ាល្លេនី។

លោកក្រឡាបញ្ជី សូមរាយការណ៍អំពីវត្តមាន!

[០៩:២០:៣៥]

**ក្រឡាបញ្ជី៖**

បាទ ជម្រាបប្រសាសន៍ឯកឧត្តមប្រធាន និងអង្គជំនុំជម្រះ។ ថ្ងៃនេះមានវត្តមានរបស់សហព្រះរាជអាជ្ញា លោកជំទាវ ជា លាង, លោកស្រី ប្រេនដា ហូលិស ហើយខាងដើមបណ្តឹង -- សហមេធាវីរបស់លោក ខៀវ សំផន មានលោកមេធាវី គង់ សំអុន, មានលោកស្រីមេធាវី អង់តា ហ្គីសសេ និងមានវត្តមានរបស់មេធាវីនាំ -- ហើយនិងវត្តមានរបស់ជនជាប់ចោទលោក ខៀវ សំផន។ រីឯមេធាវីដើម --

មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានលោកមេធាវី ពេជ អង្គ និងលោកស្រីមេធាវី មេហ៊្គិន ហ៊ីសត៍។

សូមជម្រាបឯកឧត្តមប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះ បាទ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដោយសារភាគី និងមេធាវីហ្នឹងមានវត្តមាននៅតាមទីកន្លែងដែលបានគ្រោងទុករួចហើយ អ៊ីចឹងតុលាការអាចបន្តសវនាការបាន។

ថ្ងៃនេះ ជាថ្ងៃទី១ នៃសវនាការលើបណ្តឹងសាទុក្ខដែលបានធ្វើឡើងដោយជនជាប់ចោទ ខៀវ សំផន។ ជនជាប់ចោទបានធ្វើបណ្តឹងប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលក្រោយមកត្រូវបានចេញនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៩ ហើយនេះជាសវនាការលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផងដែរ ដែលមានតែទឡ្ហីករណ៍មួយប៉ុណ្ណោះ។

[០៩:២២:២២]

អង្គជំនុំជម្រះតុលាការកំពូលបានទទួលសារណាជាលាយលក្ខណ៍អក្សរច្រើន -- យ៉ាងច្រើន និងទូលំទូលាយ ដែលក្នុងនោះភាគីបានលើកអំណះអំណាងដើម្បីគាំទ្របណ្តឹងសាទុក្ខរបស់ខ្លួន និងបានដាក់សារណាតបផងដែរ។ សវនាការបណ្តឹងសាទុក្ខនេះ គឺជាការផ្តល់ឱកាសឲ្យភាគីលើកបញ្ហាទិដ្ឋភាពសំខាន់ៗបំផុតនៃបណ្តឹងសាទុក្ខរបស់ខ្លួន និងដើម្បីបំភ្លឺអំណះអំណាងពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ចាំបាច់នៃបណ្តឹងសាទុក្ខ និងដើម្បីធ្វើការឆ្លើយតបទៅនឹងអំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាទៅនឹងសារណាបណ្តឹងសាទុក្ខ។

គោលបំណងនៃសវនាការបណ្តឹងសាទុក្ខនេះ តាមធម្មតាពុំមែនជាការរៀបរាប់សាឡើងវិញនូវសារណាជាលាយលក្ខណ៍អក្សរ ហើយក៏ពុំមែនយន្តការសម្រាប់ឲ្យភាគីលើកបញ្ហាអង្គហេតុ ឬអង្គច្បាប់ដែលពុំបានបញ្ជាក់ពីដំបូងនៅក្នុងសារណានៃបណ្តឹងសាទុក្ខរបស់ខ្លួននោះឡើយ។

[០៩:២៣:២៧]

ខ្ញុំសូមធ្វើការរំឭកដល់ភាគីលើចំណុចនេះ នៅពេលធ្វើសារណារបស់ខ្លួន។ សវនាការលើបណ្តឹងសាទុក្ខនេះ ក៏បានផ្តល់ឱកាសដល់ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល សួរសំណួរភាគីពាក់ព័ន្ធនឹងការបំភ្លឺលើចំណុចក្នុងសារណា និងដោះស្រាយបញ្ហាដែលអាចជួយដល់ការសម្រេចលើបណ្តឹងសាទុក្ខផងដែរ។ ចៅក្រមអាចសួរសំណួរទៅភាគីក្នុងអំឡុងពេលនៃសវនាការបណ្តឹងសាទុក្ខនេះ ហើយអង្គជំនុំ

ជម្រះក៏បានបម្រុងទុកពេលវេលាសម្រាប់ចៅក្រមសួរសំណួរបន្ថែម នៅពេលបញ្ចប់វគ្គនីមួយៗផងដែរ ប្រសិនបើចាំបាច់។

អង្គជំនុំជម្រះតុលាការកំពូល ត្រូវបើកសវនាការតាមលក្ខណៈពីចម្ងាយ ដោយសារមូលហេតុនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីចៀសវាងការរំខាននានាក្នុងអំឡុងពេលនៃការចូលរួមពីចម្ងាយ ភាគីត្រូវបិទមីក្រូហ្វូនរៀងៗខ្លួននៅពេលដែលខ្លួនពុំត្រូវនិយាយ។ គ្រប់ភាគីត្រូវធ្វើសារណាទៅតាមរយៈម៉ាស៊ីនថតវីដេអូ ប្រសិនបើភាគីណាមានបំណងធ្វើការជំទាស់ណាមួយ ពុំត្រូវបានអនុញ្ញាតឱ្យកាត់សម្តីចំពោះសារណារបស់ភាគីឡើយ ដោយត្រូវរង់ចាំរហូតដល់ពេលវេនរបស់ខ្លួននិយាយ។

ក្នុងករណីដែលមានបញ្ហាផ្នែកបច្ចេកទេស ឬការបកប្រែ តម្រូវឱ្យមានការផ្អាកដំណើរការរហូតទាល់តែបញ្ហានោះត្រូវបានដោះស្រាយដោយការិយាល័យរដ្ឋបាល។ ដើម្បីធានាការប្រើប្រាស់ពេលវេលាឱ្យបានមានប្រសិទ្ធភាព និងអនុញ្ញាតឱ្យជនជាប់ចោទនិងភាគីមានឱកាសគ្រប់ៗគ្នាក្នុងការលើកបណ្តឹងសាទុក្ខរបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចបំបែកទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខជាប្រាំមួយវគ្គតាមប្រធានបទនីមួយៗ។ វគ្គនៃប្រធានបទទាំងប្រាំ -- ដំបូងគឺពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខដែលធ្វើឡើងដោយជនជាប់ចោទដែលបានលើកទឡ្ហីករណ៍ប្រមាណ ២០០ ទៅ ៣០០ ចោទប្រកាន់អំពីកំហុសអង្គហេតុ អង្គច្បាប់និងកិច្ចដំណើរការនីតិវិធី។ ទឡ្ហីករណ៍ទាំងនេះត្រូវបានប្រមូលផ្តុំតាមប្រធានបទ ដើម្បីឱ្យងាយស្រួលដល់សាធារណជនតាមដានសវនាការបណ្តឹងសាទុក្ខនេះ។ ភាគីត្រូវបានអញ្ជើញឱ្យធ្វើការពិចារណាទៅលើកាលវិភាគបណ្តឹងអាសន្នសម្រាប់សវនាការបណ្តឹងសាទុក្ខ បន្ទាប់ពីទទួលសេចក្តីសង្កេតអង្គជំនុំជម្រះបានព្យាយាមសម្របសម្រួលដល់ភាគីដាក់បញ្ចូលនូវសំណើសុំទាំងនោះនៅក្នុងការវិភាគស្តាពរ ដែលបានភ្ជាប់ជាមួយនឹងដីកាកំណត់កាលបរិច្ឆេទនៃសវនាការ។ វគ្គទី១ ដែលត្រូវបានចាប់ផ្តើមបន្ទាប់ពីសេចក្តីផ្តើមនេះ គឺផ្តោតទៅលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងភាពពុំត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែលផ្តើមចេញពីសារណាដ៏សំខាន់របស់ជនជាប់ចោទ។ ទឡ្ហីករណ៍នេះបានជំទាស់ទៅលើសុពលភាពនៃការចេញសាលក្រមជាពីរដំណាក់កាលរបស់អង្គជំនុំជម្រះសាលាដំបូង។ វគ្គទី២ ដែលត្រូវចាប់ផ្តើមបន្ទាប់នឹងផ្តោតទៅលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។ វគ្គទី៣គឺសម្រាប់ទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលចោទប្រកាន់អំពីកំហុសពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ ដូចដែលបានបញ្ជាក់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព ដោយសារជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃបក្សកុម្មុយនីស្ត

កម្ពុជាដែលបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលបណ្តាលឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលកំណត់គោលដៅទៅលើប្រជាជនស៊ីវិលកម្ពុជា រំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលកំណត់គោលដៅទៅលើជនជាប់ឃុំជនជាតិវៀតណាម និងបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា។ ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពផងដែរពីបទជួយទំនុកបម្រុងដល់អំពើមនុស្សឃាតដោយចេតនាប្រយោល។

[០៩:២៧:៥៨]

វគ្គបន្ទាប់ គឺផ្តោតទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលសម្រាប់បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ បន្ទាប់ពីការបញ្ចប់នៃអំណះអំណាងពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល គឺចាប់ផ្តើម វគ្គស្តីពីអំណះអំណាងរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងការប្រកាសទោស ដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។ ចុងក្រោយគឺវគ្គស្តីពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ ពាក់ព័ន្ធនឹងទៅនឹងដំណើរការតាមវគ្គនីមួយៗ ដោយអនុលោមតាមនីតិវិធីដែលបានប្រើប្រាស់ក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿងលេខ០០១ និង ០០២/០១ វគ្គសវនាការនីមួយៗ នឹងត្រូវចាប់ផ្តើមជាមួយនឹងរបាយការណ៍ពាក់ព័ន្ធនឹងចៅក្រមរបស់ចៅក្រមរបាយ-ការណ៍ ដែលលើកប្រធានបទជាក់លាក់នៃបណ្តឹងសាទុក្ខ។ ក្នុងនាមជាប្រធានអង្គជំនុំជម្រះតុលាការកំពូល ខ្ញុំបានចាត់តាំងសហចៅក្រមរបាយការណ៍ជាបីក្រុម សម្រាប់បណ្តឹងសាទុក្ខ ព្រមទាំងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផងដែរ។

[០៩:២៩:១៤]

ដោយសារទទ្បីករណ៍នៃបណ្តឹងសាទុក្ខ ដែលបានដាក់ដោយជនជាប់ចោទមានចំនួនច្រើន ទើបរបាយការណ៍របស់សហចៅក្រមរបាយការណ៍ ពុំអាចសង្ខេបរាល់ការលើកឡើងក្នុងបណ្តឹងសាទុក្ខបាន។ ផ្ទុយទៅវិញរបាយការណ៍នេះប្រើប្រាស់ជាសេចក្តីផ្តើមនៃវគ្គសវនាការនីមួយៗដែលពាក់ព័ន្ធ និងធ្វើជាទិដ្ឋភាពទូទៅនៃបញ្ហាដែលបានលើកឡើងក្នុងបណ្តឹងសាទុក្ខ។ នៅពេលដែលអំណះអំណាង ឬទទ្បីករ-ណ៍នៃបណ្តឹងសាទុក្ខណាមួយត្រូវបានលើកនៅក្នុងរបាយការណ៍ មានន័យថា សហចៅក្រមរបាយ-ការណ៍បានចាត់ទុកថាមានភាពចាំបាច់ក្នុងការបំភ្លឺបន្ថែមដោយមានលើកឧទាហរណ៍ជាក់លាក់ និងការយោងនានា។ ទទ្បីករណ៍ដទៃទៀតនៃបណ្តឹងសាទុក្ខក៏ពុំត្រូវមើលរំលងផងដែរ ប៉ុន្តែត្រូវបានដាក់បញ្ចូលគ្នាតាមប្រធានបទសំខាន់ៗដែលបានបញ្ជាក់ខាងលើ ឬត្រូវលើកអំណះអំណាងគាំទ្រគ្រប់គ្រាន់រួច

ហើយ។ បន្ទាប់ពីអានរបាយការណ៍របស់ចៅក្រមរបាយការណ៍ ភាគីនឹងត្រូវអញ្ជើញឲ្យថ្លែងចំពោះមុខអង្គជំនុំជម្រះតាមលំដាប់លំដោយដូចបញ្ជាក់នៅក្នុងកាលវិភាគ។ ភាគីត្រូវបានបង្គាប់ឲ្យព្យាយាមធ្វើយ៉ាងណាគោរពតាមម៉ោងពេលដែលបានបែងចែកនោះ។ ក្នុងករណីដែលមើលទៅទំនងជាតម្រូវឲ្យបន្ថែមពេលវេលាចំពោះទិដ្ឋភាពជាក់លាក់នៃសារណា អង្គជំនុំជម្រះអាចបន្ថែមម៉ោងឲ្យភាគីដើម្បីបំពេញបន្ថែមសារណារបស់ខ្លួន ប្រសិនបើអង្គជំនុំជម្រះពិចារណាឃើញថា បញ្ហានេះត្រូវឲ្យមានអំណះអំណាងបន្ថែមដែលមានអត្ថប្រយោជន៍ និងកែលម្អ។

[០៩:៣១:០៦]

សូមបញ្ជាក់ផងដែរ នៅចុងបញ្ចប់នៃសវនាការ អង្គជំនុំជម្រះបានបម្រុងទុកពេលសម្រាប់សួរសំណួរ ប្រសិនណាអង្គជំនុំជម្រះយល់ឃើញថាមានភាពចាំបាច់។ ជាចុងក្រោយខ្ញុំសូមបញ្ជាក់ថា ដោយអនុលោមតាមវិធាន១០៩(៤) នៃវិធានផ្ទៃក្នុង ខៀវ សំផន មានសិទ្ធិថ្លែងចំពោះមុខអង្គជំនុំជម្រះ និងអនុលោមតាមវិធាន២១(ឃ) នៃវិធានផ្ទៃក្នុង ស្តីពីសិទ្ធិជាមូលដ្ឋានក្នុងការមិនឆ្លើយតបនឹងសំណួរ ដូចបានបញ្ជាក់នៅក្នុងកាលវិភាគ ពេលវេលាត្រូវបានបែងចែកទុកជាក់លាក់សម្រាប់ ខៀវ សំផន មានឱកាសថ្លែងចុងក្រោយក្នុងអំឡុងពេលបិទសវនាការ។ ប៉ុន្តែគាត់អាចជ្រើសរើសថ្លែងនៅពេលណាមួយបាន ប្រសិនបើគាត់មានបំណងដូចជា នៅពេលបញ្ចប់សារណាបណ្តឹងសាទុក្ខ ឬនៅពេលបញ្ចប់ផ្នែកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ឬនៅពេលដែលចាប់ផ្តើមសវនាការបណ្តឹងសាទុក្ខតែម្តង។

អ៊ីចឹងខ្ញុំសុំសួរបញ្ជាក់ទៅជនជាប់ចោទ តើគាត់នឹងថ្លែង មានបំណងនឹងថ្លែងនៅពេលនេះ ឬនៅក្នុងពេលណាមួយដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញហ្នឹង ឬរង់ចាំនៅពេលដែលចុងបញ្ចប់នៃសវនាការ?

សូមអញ្ជើញ!

[០៩:៣២:៤៣]

**លោក គង់ សំអុន៖**

សូមគោរពឯកឧត្តមប្រធានអង្គជំនុំជម្រះ។ លោក ខៀវ សំផន មានបំណងនឹងថ្លែង ប៉ុន្តែសុំអនុញ្ញាតថ្លែងនៅពេលចុងបញ្ចប់នៃពេលសវនាការ។ សូមអរគុណលោកប្រធាន។ ប៉ុន្តែភ្ជាប់នេះដែរ លោក ខៀវ សំផន មានសំណើមួយនៅក្នុងដំណើរការសវនាការនេះ លោក ខៀវ សំផន សុំអនុញ្ញាតចេញទៅបន្ទប់ទឹកអាចជាញឹកញាប់បន្តិច ហេតុដូច្នេះសូមឯកឧត្តមប្រធានអនុញ្ញាតតែម្តងឲ្យសម្រាប់រាល់ពេលដែលលោក ខៀវ សំផន ត្រូវការទៅបន្ទប់ទឹក។ សូមអរគុណ បាទ។

**ប្រធានអង្គជំនុំ៖**

ទាក់ទងនឹងបញ្ហាសំណើរបស់ ខៀវ សំផន ដែលសុំធ្វើសេចក្ដីថ្លែងនៅចុងបញ្ចប់ហ្នឹង គឺតាមកាលវិភាគ អាហ្នឹងអត់មានបញ្ហាអីទេ គឺអាចក្រុមប្រឹក្សាមិនជំទាស់អីទេ។ ហើយនៅក្នុងកាលវិភាគក៏មានស្រាប់ហើយ ហើយចំណែកការស្នើសុំទៅបន្ទប់ទឹកនៅក្នុងពេលដែលដំណើរការសវនាការនេះ ក៏អង្គជំនុំជម្រះមិនមានការជំទាស់អីដែរ។ សំខាន់គឺថាឲ្យតែគាត់ត្រូវការទៅបន្ទប់ទឹក មិនចាំបាច់សួរ ឬក៏មកសុំមកអង្គជំនុំជម្រះម្ដងទៀតទេ គឺគាត់អាចសំណើ ធ្វើដំណើរទៅតែម្ដង ហើយបន្ទាប់មកគាត់ចូលមកវិញមក ហើយសវនាការយើងបន្តធម្មតាទៅ បាទ។

អ៊ីចឹង ដោយសារអត់មានបញ្ហាអីទេ គឺខ្ញុំសូមចាប់ផ្ដើមបើកវគ្គទី១ នៃសវនាការលើកបណ្ដឹងសាទុក្ខ។ អ៊ីចឹងជាបន្ត សូមអញ្ជើញសហចៅក្រមរបាយការណ៍ធ្វើរបាយការណ៍។

[០៩:៣៥:១២]

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

សូមគោរពឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីទាំងអស់។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតផ្ដល់នូវ ខ្ញុំបានទទួលនូវរបាយការណ៍ដែលទើបបានប្រកាសគឺការប្រព្រឹត្តកំហុសដោយសារតែវិការៈផ្នែកនីតិវិធី។ ការចេញសម្អាងហេតុនៅពេលក្រោយពុំអាចជួសជុលការវិការៈនោះបានឡើយ។ សារណានេះបានអះអាងបន្ថែមទៀតថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានផុតអាណត្តិរបស់ខ្លួននៅពេលសាលក្រមមានសម្អាងហេតុពេញលេញរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានចេញនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ និងថាទង្វើរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមមានសម្អាងហេតុពេញលេញ គឺធ្វើតាមអំពើចិត្ត និងហួសពីដែនកំណត់នេះច្បាប់។ ជាជម្រើស ជនជាប់ចោទបានលើកឡើងថាការជំនុំជម្រះទាំងមូលបានធ្វើឡើងដែលពុំមានភាពយុត្តិធម៌ និងការសិទ្ធិមូលដ្ឋានរបស់គាត់ដូចមានចែងក្នុងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ពុំត្រូវបានគោរពចាប់តាំងពីដើមរហូតដល់ចុងបញ្ចប់នៃការជំនុំជម្រះ មានដូចជា នីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈលម្អៀងចំពោះគោលការណ៍បំភ្លឺស្ដីពីច្បាប់ព្រហ្មទណ្ឌ និងកិច្ចដំណើរការនីតិវិធីដែលមាននៅក្នុងការជំនុំជម្រះដំបូងរបស់ខ្លួននៅក្នុងសំណុំរឿង០០២/០១ និងភាពលម្អៀងចំពោះសាលក្រម ដែលទាំងអស់នេះ បានធ្វើឲ្យមានការជំនុំជម្រះលើជនជាប់ចោទមានភាពមិនយុត្តិធម៌។ ដូច្នេះ ជនជាប់ចោទបានស្នើសុំឲ្យបដិសេធការសម្រេចដាក់ពិរុទ្ធភាព និងការប្រកាសទោសមកលើរូបគាត់។ ជនជាប់ចោទបានលើកនូវចំណុចដាក់លាក់បន្ថែមទៀត

ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រដែលមានលក្ខណៈលម្អៀង និងជាឧទាហរណ៍អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ដោយខកខានក្នុងការអនុវត្តតាមបទដ្ឋានគតិយុត្តក្នុងការពិនិត្យលើបញ្ហាថា តើបទឧក្រិដ្ឋដែលគាត់បានចោទប្រកាន់នោះ ឬទម្រង់នៃការទទួលខុសត្រូវដែលបានរកឃើញនោះ គ្រប់គ្រាន់អាចយល់ដឹងបានថាជាបទល្មើស និងមានច្បាប់ចែងក្នុងឆ្នាំ១៩៧៥ ដែរឬយ៉ាងណា? និងរួមបញ្ចូលនូវបញ្ហាដែលថា តើលក្ខខណ្ឌធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានបំពេញដែរឬយ៉ាងណា? ជាពិសេសគាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានដាក់ទម្ងន់ពុំសមស្របចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មក្រោយតែពីការអនុវត្តច្បាប់ជាធរមាននៅពេលនោះ។

[០៩:៣៨:១២]

បន្ថែមលើនេះ ជនជាប់ចោទបានជំទាស់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលមានលក្ខណៈមិនច្បាស់លាស់ និងទូលំទូលាយទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ នាំឱ្យមានការពិចារណាលើអង្គហេតុក្រៅពីវិសាលភាពសំណុំរឿង និងលើអង្គហេតុដែលពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទទាំងនោះ។ គាត់បានអះអាងថា កំហុសទាំងនេះបានរំលោភបំពានលើសិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខខណ្ឌ និងមូលហេតុនៃបទចោទប្រឆាំងលើរូបគាត់ និងទទួលបានពេលវេលាគ្រប់គ្រាន់ព្រមទាំងគ្រឿងបរិក្ខារសម្រួលសម្រាប់ការត្រៀមរៀបចំការការពារខ្លួនដូចមានចែងក្នុងមាត្រា១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ គាត់បានអះអាងថា កំហុសច្បាប់ទាំងអស់នេះ បង្ហាញពីកង្វះអាណាគតិរបស់អង្គជំនុំជម្រះសាលាដំបូង។

[០៩:៣៩:០៥]

ទាក់ទងទៅនឹងអំណះអំណាងស្ដីពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌត្រឹមត្រូវឥតលម្អៀង ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងដោយពុំបានដោះស្រាយការចោទប្រកាន់របស់គាត់អំពីកង្វះនូវអាណាគតិ ដែលកើតឡើងដោយសារអង្គជំនុំជម្រះដោយធ្វើការជំនុំជម្រះសំណុំរឿង០០២/០១ ដែលរូបគាត់ គឺជាជនជាប់ចោទ។ ការណ៍នេះ បានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូង បង្កើតការសម្រេចដាក់ពិរុទ្ធភាពថ្មីក្នុងសំណុំរឿង០០២/០២ ចេញពីអង្គហេតុដែលសាលដីកាស្ថាពរបានចេញរួចហើយក្នុងសំណុំរឿង០០២/០១ ទោះបីជាបញ្ហានេះត្រូវបានជំនុំជម្រះនិងសម្រេចពីមុនរួចមក ជនជាប់ចោទអាចផ្ដោតសារណានោះ លើបញ្ហាបន្ថែម

ទៀត នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ជនជាប់ចោទអះអាងថា ភាពលម្អៀងរបស់អង្គជំនុំជម្រះត្រូវបង្ហាញបន្ថែមទៀត តាមរយៈការកែប្រែបទចោទនៃការសម្លាប់រង្គាលទៅលើ ទៅជាអំពើមនុស្សឃាត ដែលមានធាតុផ្សំអត្តនោម័តិមិនច្បាស់លាស់នៃចេតនាប្រយោល។ គាត់លើកឡើងថា បន្ថែមលើនេះ ជនជាប់ចោទបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានអនុវត្តស្របគ្នានូវគោលការណ៍ ដែលពុំគប្បីមានការប្រើប្រាស់នូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែមួយលើរឿងក្ដីពីរនេះ។ គាត់បានលើកឡើងបន្ថែម ផ្អែកលើការប្រើប្រាស់វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងការបំភ្លឺរបស់អង្គជំនុំជម្រះតុលាការកំពូលថា បើទោះបីជាសំណុំរឿង០០២/០១ ត្រូវបានលើកមកធ្វើជាមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតទៅលើបទចោទដែលនៅសល់ និងការចោទប្រកាន់ ផ្អែកអង្គហេតុប្រឆាំងនឹងជនជាប់ចោទនៅដំណាក់កាលជំនុំជម្រះនេះយ៉ាងណាក៏ដោយ ក៏តាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបង្ហាញច្បាស់ថា ពុំគប្បីមានការប្រើប្រាស់នូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែមួយក្នុងរឿងក្ដីពីរនោះទេ និងថា ការយល់ឃើញផ្នែកអង្គហេតុពុំអាចត្រូវផ្ទេរពីសំណុំរឿង០២/០១ មកសំណុំរឿង០២/២ បានឡើយ។ អាស្រ័យហេតុនេះ ទោះបីជាភស្តុតាងនៅតែមានលក្ខណៈរួមជាទូទៅចំពោះរឿងក្ដីដែលត្រូវបំបែកក៏ដោយ ក៏លក្ខណៈរួមនេះពុំអាចពន្លាតវិសាលភាពដល់ការយល់ឃើញ ហើយធាតុផ្សំផ្នែកអង្គច្បាប់នៅគ្រប់ករណីទាំងអស់ដែលកើតចេញពីសំណុំរឿង០២/២ ត្រូវតែធ្វើការបង្ហាញជាថ្មីម្ដងទៀត។

[០៩:៤១:៤២]

ជនជាប់ចោទបានលើកឡើងថា ការបដិសេធរបស់អង្គជំនុំជម្រះក្នុងការទទួលយកសំណើរបស់គាត់សុំឱ្យកោះហៅសាក្សីសាឡើងវិញពីសំណុំរឿង០២/១ ពុំមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងការសម្រេចពីមុនរបស់អង្គជំនុំជម្រះ ដោយបានអនុញ្ញាតការបង្ហាញនូវកំណត់ហេតុស្ដាប់ចម្លើយរាប់រយក្នុងសំណុំរឿង០៣, ០៤ ក្រោយមកទៀតក្នុងពេលជំនុំជម្រះ។ កំណត់ហេតុស្ដាប់ចម្លើយទាំងនេះ ពុំបានបែងចែកច្បាស់លាស់រវាងភស្តុតាងដោះបន្ទុក និងដាក់បន្ទុក និងបានអូសបន្លាយពេលវេលានៃការជំនុំជម្រះដែលរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដេញដោលចំពោះមុខ និងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលដោយសមហេតុផលឡើយ។ ជនជាប់ចោទអាចពិចារណាដោយផ្ដោតលើអ្វីខ្លះដែលជាភស្តុតាងដោះបន្ទុកត្រូវបានមើលរំលងនោះ។

ប្រធានបទនៃភាពលម្អៀង និងភាពមិនយុត្តិធម៌ ដែលបានចោទប្រកាន់បានបង្ហាញឱ្យឃើញ

បន្ថែមនូវក្នុងសេចក្តីសម្រេចបន្ទាន់ភ្លាមៗ ពាក់ព័ន្ធទៅនឹងបញ្ហាភស្តុតាងដោយបានលើកឡើងក្នុងអំឡុងពេលនៃការជំនុំជម្រះ។ សេចក្តីសម្រេចនេះ អាចស្មើនឹងកំហុសដែលស្តែងឲ្យដឹងតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្ករឲ្យមានព្យសនកម្មដល់រូបគាត់។ សេចក្តីសម្រេចនោះ ពាក់ព័ន្ធទៅនឹងលំដាប់លំដោយនៃការស្តាប់សាក្សី ការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃសវនាការដែលអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ការទទួលយកភស្តុតាងរបស់អ្នកស្រាវជ្រាវ និងអ្នកប្រវត្តិសាស្ត្រដែលពុំបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ការបង្ហាញភស្តុតាងពីសំណុំរឿង០៣, ០៤ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបើកកិច្ចដំណើរការនីតិវិធីជំនុំជម្រះសាជាថ្មី។ អំណះអំណាងនៃភាពមិនយុត្តិធម៌បានលើកឡើងពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តបទដ្ឋានទទួលយកភស្តុតាងដែលហួសពីវិមតិសង្ស័យ និងការអនុវត្ត ដែលអនុញ្ញាតឲ្យសាក្សីពិនិត្យមើលឡើងវិញនូវចម្លើយរបស់ខ្លួនពេលផ្តល់សក្ខីកម្មក្នុងតុលាការ។ ការផ្តល់អាទិភាពលើភាពឆាប់រហ័សជាងការស្វែងរកការពិត វិធីសាស្ត្រប្រើប្រាស់ចំពោះភស្តុតាងជាក់លាក់មួយប្រភេទ ជាពិសេសការប្រើប្រាស់ចម្លើយ និងអត្ថបទផ្សព្វផ្សាយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ការសម្អាងទៅលើភស្តុតាងដែលរកតាមរយៈការធ្វើទារុណកម្ម ការសម្អាងលើភស្តុតាងចចាមអារ៉ាម និងលើឯកសារដែលមានប្រភពចម្រូងចម្រាស។ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវវិធីសាស្ត្រផ្សេងៗគ្នា នៅពេលដោះស្រាយលើភស្តុតាងដាក់បន្ទុក ដែលផ្ទុយពីភស្តុតាងដោះបន្ទុក និងវិធីសាស្ត្រលើតម្លៃជាភស្តុតាង នៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុភាពនៃការរំលោភបំពានទាំងអស់ បូកបញ្ចូលគ្នាបានបណ្តាលឲ្យការជំនុំជម្រះរបស់គាត់មានភាពមិនយុត្តិធម៌ទៅដល់កម្រិតមួយ ដែលអង្គជំនុំជម្រះតុលាការកំពូលគប្បីធ្វើអន្តរគមន៍បដិសេធការសម្រេចដាក់ពិរុទ្ធភាព និងការប្រកាសទោសនោះ។ អង្គជំនុំជម្រះស្វាគមន៍ចំពោះការយោងជាក់លាក់ពាក់ព័ន្ធទៅនឹងការពិនិត្យភស្តុតាងមិនស៊ីសង្វាក់គ្នាដែលបានចោទប្រកាន់ ជាពិសេសភស្តុតាងដោះបន្ទុកដែលជនជាប់ចោទបានយល់ឃើញថា ពុំត្រូវបានធ្វើ ពុំត្រូវបានអើពើ ឬពិនិត្យដោយពុំស្របនោះ។

ជាចុងក្រោយ ខ្ញុំសូមបញ្ចប់នូវរបាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះសូមអញ្ជើញមេធាវីការពារក្តី ខៀវ សំផន ធ្វើសារណា។

**លោក គង់ សំអុន៖**

សូមគោរពឯកឧត្ដមប្រធាន សូមគោរពអង្គជំនុំជម្រះ! ខ្ញុំបាទ គង់ សំអុន ជាសហមេធាវីជាតិការពារក្ដីលោក ខៀវ សំផន ខ្ញុំនឹងបង្ហាញអំពីមូលដ្ឋានបណ្ដឹងសាទុក្ខចម្បងរបស់យើងដែលស្នើសុំឯក-ឧត្ដមប្រធាន លោក លោកស្រី ចៅក្រមធ្វើមោឃភាពនៃសាលក្រម។ នេះគឺជាមូលដ្ឋានបណ្ដឹងសាទុក្ខមិនធម្មតា ពីព្រោះដំណាក់កាលរបស់អង្គជំនុំជម្រះសាលាដំបូងក៏មិនធម្មតាដែរ។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងបរិវេណសាលសវនាការដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញនិងប្រកាសសាលក្រមដោយបានសម្រេចឲ្យកូនក្ដីយើងខ្ញុំ គឺលោក ខៀវ សំផន ជាប់ពិរុទ្ធពីបទឧក្រិដ្ឋជាច្រើន ព្រមទាំងបានផ្ដន្ទាទោសរូបគាត់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ប៉ុន្ដែនៅថ្ងៃនោះ អង្គជំនុំជម្រះសាលាដំបូងមិនបានចេញសម្អាងហេតុជាលាយលក្ខណ៍អក្សរទេ ទោះបីជាមានការតម្រូវតាមច្បាប់ពីវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ក៏ដោយ។

[០៩:៤៦:២១]

អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែបានអះអាងថា នឹងចេញសម្អាងហេតុក្នុងពេលសមស្រប ដោយមិនបានបញ្ជាក់ពេលវេលា និងមូលហេតុនោះឡើយ។ បីខែក្រោយមក យើងក៏បានប្ដឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលដោយលើកឡើងអំពីមោឃភាពនៃសាលក្រម ដែលត្រូវបានប្រកាសដោយខុសច្បាប់។ នៅខែកុម្ភៈ ឆ្នាំ២០១៩ លោក លោកស្រីចៅក្រម បានសម្រេចបដិសេធបណ្ដឹងសាទុក្ខនេះក្នុងខណៈដែលទន្ទឹងរង់ចាំការចេញសម្អាងហេតុ។ ក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានចេញសម្អាងហេតុនៅចុង ខែមីនា ឆ្នាំ២០១៩ ពោលគឺជិតប្រាំមួយខែ ក្រោយពីប្រកាសសាលក្រម។ យើងបានលើកឡើងអំពីមោឃភាពនៃសាលក្រមជាថ្មីម្ដងទៀតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងក្របខ័ណ្ឌបណ្ដឹងសាទុក្ខ។

សហព្រះរាជអាជ្ញាបានជ្រកពីក្រោមសេចក្ដីសម្រេចបដិសេធនៅខែកុម្ភៈ ឆ្នាំ២០១៩ របស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីអន្ទងឲ្យឯកឧត្ដមប្រធាន លោក លោកស្រីចៅក្រម ជឿជាក់ថា ត្រូវតែបដិសេធមូលដ្ឋាននៃបណ្ដឹងសាទុក្ខរបស់យើង ប៉ុន្ដែយើងសូមរំឭកថា លោក លោកស្រី មិនបានសម្រេចលើអង្គសេចក្ដីនោះឡើយ។ លោក លោកស្រីចៅក្រម បានអះអាងថា បណ្ដឹងសាទុក្ខរបស់យើងមិនអាចទទួលយកបានដោយសារតែវាមិនចូលក្នុងករណីផ្សេងៗនៃភាពដែលអាចទទួលយកបាន ដែលមានចែងក្នុងវិធានផ្ទៃក្នុង។

[០៩:៤៧:០៣]

ច្បាស់ណាស់វិធានផ្ទៃក្នុងក៏មិនបានចែងឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមជាពីរដំណាក់កាលនោះដែរ។ ផ្ទុយទៅវិញ វិធានផ្ទៃក្នុងបានហាមឃាត់យ៉ាងច្បាស់ វិធានផ្ទៃក្នុងបានចែងអំពីវិធានពិសេសៗសម្រាប់សាលក្រម គឺតម្រូវឲ្យសាលក្រមមានសម្អាងហេតុ និងចេញជាលាយលក្ខណ៍អក្សរនៅថ្ងៃប្រកាសតែម្តង។ យោងតាមវិធាន១០១ ដែលមានចំណងជើងថា "ទម្រង់ការនៃសាលក្រម" សាលក្រមត្រូវចែកជាពីរផ្នែក។ ខ្ញុំសុំដកស្រង់៖ ផ្នែកសម្រេចសេចក្តី -- ក) ផ្នែកសម្អាងហេតុជាទឡ្ហីករណ៍ខាងអង្គហេតុនិងអង្គច្បាប់ ដែលនាំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច។ ខ) ផ្នែកសម្រេចសេចក្តីផ្ទាល់តែម្តង។ លើសពីនេះទៅទៀត សាលក្រមដើមត្រូវចុះហត្ថលេខាដោយចៅក្រម និងក្រឡាបញ្ជី ខ្ញុំសុំដកស្រង់៖ "យ៉ាងយូរបំផុតនៅថ្ងៃចេញសាលក្រម"។ ខ្ញុំសូមនិយាយម្តងទៀត "យ៉ាងយូរបំផុតនៅថ្ងៃចេញសាលក្រម"។

ចំណុចនេះ គឺជាក់លាក់និងច្បាស់លាស់ណាស់ យោងតាមវិធាន១០២ ដែលមានចំណងជើងថា "ការប្រកាសសាលក្រមនៅសវនាការសាធារណៈ គ្រប់សាលក្រមទាំងអស់ត្រូវតែប្រកាសនៅក្នុងសវនាការសាធារណៈ។ ផ្នែកសង្ខេបនៃសម្អាងហេតុ និងផ្នែកសង្ខេបសេចក្តីត្រូវតែអានខ្លាំងៗ។ ក្រឡាបញ្ជីត្រូវផ្តល់សាលក្រមចម្លងមួយច្បាប់ឲ្យទៅភាគីទាំងឡាយ និងត្រូវធានាថា សាលក្រមត្រូវបានផ្សព្វផ្សាយ។ វិធាននេះបានបញ្ជាក់ថា បើសិនជនជាប់ចោទអវត្តមាននៅពេលប្រកាសសាលក្រម ជនជាប់ចោទនឹងត្រូវបានជូនដំណឹងតាមរយៈមេធាវីរបស់ខ្លួន ហើយក្នុងករណីនេះរយៈពេលដាក់បណ្តឹងសាទុក្ខត្រូវគិតចាប់ពីថ្ងៃជូនដំណឹង។ ដើម្បីការពារអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានផ្អែកលើវិធាន១០៧(៤) ដែលចែងថា "រយៈពេលនៃបណ្តឹងសាទុក្ខ" សុំដកស្រង់៖ "គិតចាប់ពីថ្ងៃប្រកាសសាលក្រម ឬការជូនដំណឹងពីសាលក្រមនោះមកករណីសមស្រប" ឬជូនដំណឹងពីសាលក្រមនោះតាមករណីសមស្របមិនមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានជម្រើសអាចជូនដំណឹងពីសម្អាងហេតុតាមក្រោយនោះទេ។ នេះគឺជាករណីដែលចែងនៅក្នុងវិធាន១០២ ដែលបញ្ជាក់ថា ប្រសិនបើជនជាប់ចោទអវត្តមានរយៈពេលដាក់បណ្តឹងសាទុក្ខគិតចាប់ពីថ្ងៃជូនដំណឹងសាលក្រម យើងមិនអាចធ្វើមិនដឹងមិនឮដូចសហព្រះរាជអាជ្ញាដែលបានធ្វើនោះទេ។

[០៩:៥០:៥៩]

ករណីនេះគឺច្បាស់លាស់ណាស់ក្នុងច្បាប់កម្ពុជាដូចគ្នាបេះបិទ។ ខ្ញុំសូមឯកឧត្តមប្រធាន លោក

លោកស្រី ចៅក្រមពិនិត្យលើមាត្រា៣៨១ និងមាត្រា៣៨២ ក៏ដូចជាមាត្រា៣៦០ និងមាត្រា៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងរំលោភលើវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់ពន្យល់ទាល់តែសោះ ហេតុអ្វីបានជាធ្ងន់ធ្ងរ ពីព្រោះនៅទីបំផុតអង្គជំនុំជម្រះសាលាដំបូងបានចេញសម្អាងហេតុជាលាយលក្ខណ៍អក្សរ ហើយលោក ខៀវ សំផន បានប្តឹងសាទុក្ខ នេះគឺជាអ្វីដែលសហព្រះរាជអាជ្ញាបានសន្និដ្ឋានលើកឡើងថា វាមិនធ្ងន់ធ្ងរទេ មិនមានបញ្ហាអីទេ។

សម្រាប់យើងពិតជាមានបញ្ហា ហើយជាបញ្ហាធំទៀតផង គឺថាដើម្បីផ្តល់យុត្តិធម៌ចៅក្រមត្រូវគោរពច្បាប់ ចៅក្រមជាអ្នកធានាការគោរពច្បាប់ និងជាអ្នករក្សាសេរីភាពបុគ្គល និងសិទ្ធិជាមូលដ្ឋាន។ បើចៅក្រមខ្លួនឯងមិនគោរពវិធានច្បាប់របស់ខ្លួន នោះគឺចប់តែម្តង។

[០៩:៥២:២២]

នោះគឺជាបរាជ័យក្នុងវិស័យច្បាប់ដែលជាការធ្វើតាមទំនើងចិត្ត គ្មាននីតិរដ្ឋ និងគ្មានទំនុកចិត្តលើយុត្តិធម៌។ បញ្ហាគឺថា អង្គជំនុំជម្រះសាលាដំបូងមិនបានគោរពវិធានច្បាប់ ដើម្បីចេញសេចក្តីសម្រេចចុងក្រោយ និងសំខាន់បំផុតដែលជាគោលដៅនៃបេសសកម្មរបស់ខ្លួន គឺសេចក្តីសម្រេចលើភាពគ្មានទោស ឬមានពិរុទ្ធភាពរបស់ជនជាប់ចោទ រួមទាំងផលប៉ះពាល់ទាំងអស់ ដូចដែលលោក លោកស្រីចៅក្រមជ្រាប ការផ្តន្ទាទោសលោក ខៀវ សំផន មិនត្រឹមត្រូវតាមច្បាប់ គឺធ្វើឡើងដោយខុសច្បាប់ និងតាមទំនើងចិត្ត។ ការផ្តន្ទាទោសនេះ មិនអាចជឿទុកចិត្តបាន និងគ្មានយុត្តិធម៌នោះទេ។

អស់រយៈពេលរាប់ខែលោក ខៀវ សំផន មិនបានដឹងពីសម្អាងហេតុ និងមិនអាចប្តឹងសាទុក្ខបាន។ រយៈពេលរាប់ខែនៃអសច្ចភាព និងចន្លោះប្រហោងនៃច្បាប់ ដែលរូបលោកមិនអាចអនុវត្តសិទ្ធិបាន និងមិនអាចលុបបំបាត់បានដូចប្រើសីល៍ទេ។ ភាពយឺតយ៉ាវរាប់ខែដោយឥតហេតុផល ក្នុងការជំនុំជម្រះមិនអាចទូទាត់បានទេ ជាពិសេសសាលក្រមផ្តន្ទាទោសគ្មានមូលដ្ឋានផ្លូវច្បាប់ទាល់តែសោះ។ ដូច្នេះ ទោះបីជាសហព្រះរាជអាជ្ញានិយាយយ៉ាងម៉េចក៏ដោយ គឺពិតជាមានបញ្ហា និងជាបញ្ហាធ្ងន់ធ្ងរបំផុតទៀតផង។ ម្យ៉ាងទៀត សហព្រះរាជអាជ្ញាខ្លួនឯងក៏ធ្លាប់មានបញ្ហានៅក្នុងបរិបទមួយផ្សេងទៀត ដែលមិនសូវសំខាន់ដូចសាលក្រមផង និងដែលវិធានផ្ទៃក្នុងមិនបានចែងអំពីវិធានពិសេសៗ ដូចមានចែងអំពីសាលក្រមនោះដែរ។ នោះគឺសេចក្តីសម្រេចបំបែកកិច្ចនីតិវិធីដំណើរការនីតិវិធីដែលចេញដោយផ្ទាល់មាត់ និងដែលអង្គជំនុំជម្រះសាលាដំបូងមានការយឺតយ៉ាវក្នុងការផ្តល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ។

[០៩:៥៤:២៨]

ខ្ញុំសូមយោងទៅលើសំណើរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ E163/5/1/13/2 ជាអាទិ៍កថាខណ្ឌ២៣, កថាខណ្ឌ២៥ និង កថាខណ្ឌ២៩។ សហព្រះរាជអាជ្ញាបានប្ដឹងអំពីការមិនទទួលបានសម្អាងហេតុនៃសេចក្ដីសម្រេចនេះក្រោយពីចេញបាន២៥ថ្ងៃ។ សហព្រះរាជអាជ្ញាបានលើកឡើងអំពីផលវិបាកធ្ងន់ធ្ងរលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិធ្វើបណ្ដឹងសាទុក្ខ កថាខណ្ឌ២៣ ផលប៉ះពាល់លើសិទ្ធិរបស់ភាគីនៅក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ កថាខណ្ឌ២៣ និងសេចក្ដីទុកចិត្តរបស់សាធារណជនលើរដ្ឋបាលតុលាការ កថាខណ្ឌ២៥ និងអ្វីដែលភាគីបានបាត់បង់ ខ្ញុំសុំដកស្រង់៖ “ដោយពេលវេលាកន្លងផុតពីមួយថ្ងៃទៅមួយថ្ងៃ” កថាខណ្ឌ២៩។

ដូច្នេះច្បាស់ណាស់ថា ក្នុងករណីដែលក្រុម -- សាលក្រមដោះលែងលោក ខៀវ សំផន សហព្រះរាជប្រាកដជាប្ដឹង និងលើកឡើងអំពីព្យសនកម្មធ្ងន់ធ្ងរ គួរឲ្យលោកស្ដាយដែលសហព្រះរាជអាជ្ញាមើលឃើញវិធានច្បាប់ប្រែប្រួលទៅតាមផលប្រយោជន៍របស់ខ្លួន។ ម្យ៉ាងវិញទៀត នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មានឧទាហរណ៍ថ្មីមួយអំពីបណ្ដឹងឧទ្ធរណ៍រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចដោះលែងដែលបានចេញដោយផ្ទាល់មាត់មុនពេលផ្ដល់សម្អាងហេតុជាលាយលក្ខណ៍អក្សរនៅប៉ុន្មានក្រោយ។

ក្នុងរឿងក្ដី ជីបាបូ និង ប្លេកូដេ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានពន្យល់នៅពេលចេញសេចក្ដីសម្រេចថា ខ្លួនធ្វើរបៀបនេះ ដើម្បីកុំឲ្យជនជាប់ចោទបន្តជាប់ឃុំក្នុងពេលរង់ចាំសម្អាងហេតុ។ មូលហេតុបណ្ដឹងឧទ្ធរណ៍ទី១ របស់រដ្ឋអាជ្ញា គឺការរំលោភលើលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរ-ជាតិ។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធមូលហេតុបណ្ដឹងឧទ្ធរណ៍នេះ ដោយហេតុថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្ដីនេះ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុសទេ ក្នុងការផ្ដល់អាទិភាពដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសេរីភាពរបស់ជនជាប់ចោទ ដែលត្រូវបានដោះលែងពីលើគម្រោងការនិយម ដែលត្រូវបានបង្កើតឡើង ដើម្បីការពារ និងធានាសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[០៩:៥៧:១៣]

លោក លោកស្រីចៅក្រម នឹងបានឃើញឯកសារយោងនៃសេចក្ដីសម្រេចនេះនៅក្នុងបញ្ជីឯក-សារសម្អាងរបស់យើង ដែលយើងបានភ្ជាប់សម្រង់ពាក់ព័ន្ធ។ យើងមិនបានរកឃើញករណីផ្សេងទៀតដែលអង្គជំនុំជម្រះសាលាដំបូងមិនបានគោរពវិធានតុលាការរបស់ខ្លួន ដើម្បីចេញសាលក្រោមនោះឡើយ។

ក្នុងករណីលោក ខៀវ សំផន វាមិនមែនជាការដោះលែងទេ អង្គជំនុំជម្រះសាលាដំបូង មិនបានផ្ដល់សេចក្ដីពន្យល់ណាមួយ ហើយគ្មានកាលៈទេសៈចាំបាច់ដែលអាចជាយុត្តិកម្ម ជាយថាហេតុឲ្យចៅក្រមមិនគោរពវិធានការពារសិទ្ធិរបស់ជនជាប់ចោទឡើយ។

ក្នុងលក្ខខណ្ឌបែបនេះ ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម គ្មានជម្រើសអ្វីក្រៅពីធ្វើមោឃភាពសាលក្រម ថ្វីត្បិតតែដូចសហព្រះរាជអាជ្ញាបានលើកឡើង វិធានផ្ទៃក្នុងមិនបានចែងច្បាស់ពីការធ្វើមោឃភាព ប៉ុន្តែច្បាស់ណាស់ថា កិច្ចមួយខុសច្បាប់ ដែលត្រូវបានធ្វើឡើងនៅក្រៅក្របខ័ណ្ឌគតិយុត្ត ឬផ្ទុយនឹងក្របខ័ណ្ឌគតិយុត្ត ពុំមានអានុភាពគតិយុត្តឡើយ។

[០៩:៥៨:៣២]

ម្យ៉ាងវិញទៀត ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម បានធ្លាប់ប្រកាសបែបនេះរួចហើយ ខ្ញុំនឹងលើកឧទាហរណ៍ចំនួនបី។ យូរណាស់មកហើយ គឺនៅឆ្នាំ២០១២ លោក លោកស្រីចៅក្រម បានប្រកាសថា នៅអ.វ.ត.ក ការមិនចេញសាលក្រមជាលាយលក្ខណ៍អក្សរ គឺនាំឲ្យមោឃភាព ដែលខុសពីសេចក្ដីសម្រេចផ្សេងទៀត។ នោះគឺជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ E174/2/1/4 ដែលយើងបានដកស្រង់ ត្រង់កថាខណ្ឌ៣៥ នៃសារណាបណ្ដឹងសាទុក្ខរបស់យើង។ ដូច្នេះវាច្បាស់ណាស់សម្រាប់ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម បើទោះបីវិធានផ្ទៃក្នុងមិនបានបញ្ជាក់ច្បាស់លាស់ក៏ដោយ។

ថ្មីជាងនេះនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកឧត្តម ប្រធាន លោកស្រីចៅក្រម បានប្រកាសថា៖ “សារណាដែលចេញហួសពីក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក មិនអាចទទួលយកបានទេ ហើយលោក លោកស្រីចៅក្រម នឹងមិនលើកយកមកពិចារណាទេ”។ នោះគឺជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ F50/1/2 កថាខណ្ឌ១២។

ថ្មីជាងនេះទៅទៀត នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ក្នុងសំណុំរឿង០០៤/០២/២ សេចក្ដីសម្រេចដែលមានឯកសារលេខ E004/2/1/1/2 លោក លោកស្រីចៅក្រម បានកត់សម្គាល់ថា “កិច្ចខុសច្បាប់ និងផ្ទុយពីក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក គឺជីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ត្រូវទុកជាមោឃៈ” កថាខណ្ឌ៥១ និងកថាខណ្ឌ៥៣។

លោក លោកស្រីចៅក្រមបានសម្រេចថា ខ្ញុំសុំដកស្រង់៖ “កិច្ចដែលគ្មានសុពលភាពមិនអាចបង្កើតផលវិបាក ឬលទ្ធផលត្រឹមត្រូវតាមច្បាប់” នៅក្នុងកថាខណ្ឌ៦៧។

លោក លោកស្រីចៅក្រម រំឭកថា ខ្ញុំសុំដកស្រង់៖ “ដោយហេតុថា ជាការជាក់ច្បាស់គោលបំណងនៃកិច្ចព្រមព្រៀង និងច្បាប់របស់ អ.វ.ត.ក គឺដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត មកកាត់ទោសពីបទឧក្រិដ្ឋ ទើបត្រូវធ្វើឡើងផ្អែកតាមវិសាលភាពនៃច្បាប់” កថាខណ្ឌ៦៨។

ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមដោយរំលោភលើក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក និងមិនបានបំពេញបេសកកម្មរបស់ខ្លួនស្របតាមច្បាប់។ សាលក្រមផ្តន្ទាទោសលោក ខៀវ សំផន ពុំមានអានុភាពគតិយុត្តឡើយ ពោលគឺត្រូវទុកជាមោឃៈ។

ហេតុនេះ យើងខ្ញុំស្នើសុំអង្គជំនុំជម្រះតុលាការកំពូល អ.វ.ត.ក បដិសេធចោលសាលក្រមសំណុំរឿង០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទុកជាមោឃៈ។

សូមអរគុណ។

[១០:០២:៤៥]

**លោកស្រី អង់តា ហ្គីសសេ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

ខ្ញុំសូមនិយាយបន្តពីលោកមេធាវី គង់ សំអុន។ អ្វីដែលសំខាន់នៃបណ្តឹងសាទុក្ខរបស់យើង ខ្ញុំនឹងចាប់ផ្តើមដោយរំឭកពាក្យរបស់អ្នកនិពន្ធបារាំងដ៏ល្បីនៃសតវត្សរ៍ទី១៩ គឺលោក ព្យែរ-ចូហ្សេះ ប្រូដុង ដែលគាត់និយាយអំពីនីតិវិធី។ គាត់និយាយថា យុត្តិធម៌គឺជាមនុស្ស គឺគ្មានអ្វីក្រៅពីមនុស្សទេ ពីព្រោះថា យុត្តិធម៌ជាមនុស្សហ្នឹងហើយ គឺការត្រួតពិនិត្យនៃភាពត្រឹមត្រូវនៃនីតិវិធី គឺមានសារៈសំខាន់ណាស់ ពីព្រោះថាវាជាមនុស្ស។

នៅពេលដែលយើងឈើបឈរនៅចំពោះមុខចៅក្រមនៃតុលាការនេះ យើងគោរពចំពោះការងាររបស់ចៅក្រម ហើយនិងអ្វីដែលបានប្រគល់ជូនដោយច្បាប់។ អ្វីដែលចៅក្រមស្លៀកពាក់នេះគឺបង្ហាញអំពីពួកគាត់គឺជាមនុស្ស។ មនុស្សមានន័យថា គឺមានចំណុចខ្សោយ គឺតែងតែមានការប្រព្រឹត្តកំហុស ហើយជួនកាលនោះ គឺថាអាចចេញនូវសេចក្តីសម្រេចដែលមានភាពលម្អៀង ទោះបីជាដោយអសតិ-សម្បជញ្ញៈ ឬក៏ដោយជាសតិសម្បជញ្ញៈក៏ដោយ។

[១០:០៤:១៦]

អ៊ីចឹងហើយបានជាមេធាវីការពារក្តីនេះមានតួនាទីត្រួតពិនិត្យគ្រប់គ្រងការពារសិទ្ធិរបស់ជន

ជាប់ចោទ។ ដូច្នេះគឺយើងរិះគន់ទៅលើសាលក្រម -- យើងឃើញហើយថាសាលក្រមហ្នឹងមានប្រវែងវែងណាស់ ហើយគឺថាមានការគោពទៅលើការជំនុំជម្រះដោយយុត្តិធម៌។

នៅក្នុងបណ្ដឹងសាទុក្ខរបស់យើង គឺយើងបង្ហាញអំពីការត្រួតពិនិត្យដោយលម្អៀងទៅលើភស្តុ-តាង គឺជាការជ្រើសរើសដោយលម្អៀងទៅលើសក្ខីកម្មមួយចំនួន ហើយនិងអវត្តមាននៃភស្តុតាងដោះបន្ទុកដែលបានលើកឡើង ជាពិសេសក្នុងពេលសួរចម្លើយរបស់មេធាវីការពារក្ដី។ យើងបានលើករួចមកហើយនៅក្នុងសារណារបស់យើង ដោយបញ្ជាក់អំពីថាតើហេតុអ្វីបានជាវាផ្ដល់នូវព្យសនកម្មដល់លោកខៀវ សំផន។ ដូច្នេះថ្ងៃនេះ ខ្ញុំមិនអាចនិយាយវែងឆ្ងាយច្រើនពាក់ព័ន្ធនឹងកំហុសទាំងអស់ហ្នឹងទេ ហើយដូចលោកប្រធានបានបញ្ជាក់អម្បាញ់មិញហើយ គឺយើងមិននិយាយឡើងវិញដដែលៗទេ គឺយើងគ្រាន់តែបង្ហាញភស្តុតាងមួយចំនួន ដើម្បីបង្ហាញអំពីកំហុសនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

មុននឹងចូលទៅប្រធានបទ ខ្ញុំសូមបញ្ជាក់ថាខ្ញុំសូមឆ្លើយទៅនឹងតុលាការកំពូលគឺថា យើងនឹងព្យាយាមឆ្លើយតបទៅនឹងប្រធានបទនីមួយៗតាមលទ្ធភាពរបស់យើង។ ហើយប្រសិនបើយើងមិនបានឆ្លើយតបនៅក្នុងពេលឡើងថ្លែងនេះទេ យើងនឹងឆ្លើយនៅពេលចុងក្រោយ។ ខ្ញុំសូមបញ្ជាក់ជាទូទៅថាដោយសារតែវាជាបញ្ហាដែលមាននៅក្នុងរបាយការណ៍របស់តុលាការកំពូល គឺមានលក្ខណៈដដែលៗ គឺគឺថាជួនកាលគឺយើងត្រឡប់ទៅនិយាយអំពីបញ្ហាដែលបានពិនិត្យរួចមកហើយ ជាពិសេសនៅក្នុងសំណុំរឿង០០២/០១ គឺនៅក្នុងសាលដីកា គឺបញ្ហាពាក់ព័ន្ធទៅនឹងកថាខណ្ឌ៥ នៃរបាយការណ៍របស់ចៅក្រម គឺពាក់ព័ន្ធទៅនឹង ការកែប្រែបទចោទនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលទៅជាឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត។ នៅពេលនិយាយអំពីបញ្ហានេះ ខ្ញុំនឹងលើកឡើងលម្អិត។ ទោះជាយ៉ាងណាក៏ដោយ គឺខ្ញុំនិយាយអំពីគោលជំហរទូទៅរបស់យើង ពាក់ព័ន្ធនឹងបញ្ហាមួយនេះ។ ជំហររបស់យើង គឺកើតចេញសេចក្ដីសម្រេចលេខ១១ ដែលចេញដោយអង្គជំនុំជម្រះតុលាការពិសេសពាក់ព័ន្ធនឹងបណ្ដឹងដិតចិត្តរបស់យើង ខ្ញុំបញ្ជាក់ថាមុនពេលដែលយើងដាក់បណ្ដឹងឧទ្ធរណ៍នោះ គឺបណ្ដឹងសាទុក្ខហ្នឹង គឺយើងបានដាក់បណ្ដឹងដិតចិត្តរួចមកហើយ ឬក៏យើងខ្លាចថាតុលាការកំពូលដែលបានស្ដាប់អង្គហេតុ និងធាតុផ្សំនៃអង្គច្បាប់ជាច្រើនរួចមកហើយនៅក្នុងសំណុំរឿង០០២/០១ នោះ គឺយើងខ្លាចថាគាត់គឺធ្វើដដែលដូចក្នុងសំណុំរឿង០០២/០២ នេះទៀតចំពោះលោក ខៀវ សំផន។

[១០:០៨:០២]

ចំណុចអង្គហេតុ និងអង្គច្បាប់មួយចំនួនត្រូវបានដោះស្រាយរួចមកហើយ ហើយយើងគិតទៅ

លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស គឺសេចក្តីសម្រេចលេខ១១ ដែលខ្ញុំបានលើកឡើងមកហើយនោះ ជាពិសេសកថាខណ្ឌ៧៣ ដល់ ៧៥ ដែលនិយាយអំពីភាពត្រួតគ្នានៃអង្គហេតុ និងអង្គច្បាប់ គឺកថាខណ្ឌ៧៣។ អង្គជំនុំជម្រះពិសេស សូមបញ្ជាក់ថាយើងត្រូវសន្មតថា ចៅក្រមគឺអាចរក្សានូវគោលជំហរសេរី គឺមិនត្រូវមានទំនោរបុគ្គលនោះឡើយ គឺនៅកថាខណ្ឌ៧៤ អង្គជំនុំជម្រះតុលាការពិសេសនោះក៏បានបន្តទៅទៀតថា ក្រុមប្រឹក្សាពិសេសយល់ឃើញថា សហមេធាវីមិនបង្ហាញថាអ្នកសង្កេតការណ៍សមហេតុផលនោះយល់ឃើញថា ចៅក្រមដែលត្រូវបានជំទាស់តវ៉ានោះ មិនបង្ហាញអំពីភាពលម្អៀងនៅពេលដែលខ្លួនបានកាត់សេចក្តីនៅលើសំណុំរឿង០០២ ដោយសារតែបញ្ហានោះវាត្រួតគ្នាវាស៊ីគ្នាជាមួយនឹងសំណុំរឿង០០២/០១ និង ០០២/០២។

ហើយជាចុងក្រោយ នៅកថាខណ្ឌ៧៥នៃសេចក្តីសម្រេចនេះ ក្រុមប្រឹក្សាជំនុំចម្រះពិសេសយល់ស្របជាមួយនឹងសហមេធាវីការពារក្តីថា កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងសំណរឿង០០២/០២ នៅចំពោះមុខតុលាការកំពូលនោះ គឺជាកម្រិតចុងក្រោយបំផុតសម្រាប់លោក ខៀវ សំផន ហើយចៅក្រមក៏បានសម្រេចនៅក្នុងសំណុំរឿង០០២/០១។

[១០:១០:០២]

ដូច្នេះយើងបានធ្វើបណ្តឹងសាទុក្ខពេញលេញនៅក្នុងសំណុំរឿង០០២/០២ នេះ គឺដើម្បីឲ្យវាមានយុត្តិធម៌នៃនីតិវិធី និងការធានានូវសិទ្ធិរបស់លោក ខៀវ សំផន ហើយនៅក្នុងសំណុំរឿង០០២/០២ នេះ យើងមានលទ្ធភាពអាចឆ្លើយតបបន្ថែមដែលមិនត្រូវបានបង្ហាញនៅក្នុងសំណុំរឿង០០២/០១។ ទោះជាយ៉ាងណាក៏ដោយ ពេលវេលាមានកម្រិត ដូច្នេះខ្ញុំផ្តោតលើចំណុចតែបីទេ។ ទីមួយ គឺការគោរពគោលការណ៍នីត្យានុកូលភាពជាទូទៅ។ ទីពីរ គឺរបៀបដែលអង្គជំនុំជម្រះបានប្រព្រឹត្តចំពោះការកែប្រែបទចោទ ដោយមិនផ្តល់លទ្ធភាពឲ្យជនជាប់ចោទធ្វើការកត់សម្គាល់។ ទីបី គឺការប្រើប្រាស់ឯកសារដោយរំលោភលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

ដូច្នេះបន្ទាប់មកទៀត ខ្ញុំនឹងឆ្លើយតបទៅនឹងចម្លើយរបស់អង្គជំនុំជម្រះ ដែលខ្ញុំមិនបានលើកឡើងពីមុន។ ហើយខ្ញុំនឹងផ្តល់អំពីអភិក្រមរបស់អង្គជំនុំជម្រះ ដែលមានវិការៈនៅក្នុងសំណុំរឿង០០២/០១ ហើយនិងភស្តុតាង ឬក៏ឧទាហរណ៍ពាក់ព័ន្ធនឹងការធ្វេសប្រហែស ឬការព្រងើយកន្តើយ និងភស្តុតាងដោះបន្ទុក។ ជាដំបូងខ្ញុំសូមនិយាអំពីគោលការណ៍ -- ការរំលោភគោលការណ៍នីត្យានុកូលភាព។ ខ្ញុំសូមធ្វើការកត់សម្គាល់ជាទូទៅទៅលើគោលការណ៍នេះ។ ខ្ញុំសូមពិនិត្យទៅលើរបាយការណ៍កថាខណ្ឌ២ និង

កថាខណ្ឌ២២របស់ចៅក្រមនោះ ដែលលោក លោកស្រីចៅក្រមថាឲ្យយើងនិយាយអំពីកំហុសអង្គច្បាប់ ដោយរំលោភទៅនឹងគោលការណ៍នីត្យានុកូលភាព។ ប៉ុន្តែខ្ញុំក៏សង្កត់ធ្ងន់ទៅលើគោលការណ៍ទូទៅ នៃនីត្យានុកូលភាពដែលអង្គជំនុំជម្រះសាលាដំបូងនោះ គាត់បានប្រព្រឹត្តមិនត្រឹមត្រូវ។ ខ្ញុំនឹងពន្យល់ហេតុអ្វីបានជាគោលការណ៍នេះមានសារៈសំខាន់នៅក្នុងសំណុំរឿងយើងនេះ។

[១០:១២:៣៦]

មធ្យោបាយ ឬក៏ទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់យើងគឺមិនត្រូវបានគេយល់ច្បាប់ទេ ហើយនិងត្រូវបានបំប្លែងដោយសហព្រះរាជអាជ្ញាថែមទៀតផង។ យើងនឹងបញ្ជាក់ច្បាស់នៅពេលក្រោយមកទៀត។ ក្នុងសារណារបស់យើង គឺ F54 គឺយើងបានបញ្ជាក់រួចមកហើយអំពីបញ្ហាទាំងអស់នេះគឺនៅកថាខណ្ឌ៣០០ ដល់ ៣៨០។ អង្គជំនុំជម្រះមិនបានអនុវត្តគោលការណ៍នីត្យានុកូលភាពនោះទេ គឺពួកគាត់បានពិនិត្យត្រឹមតែទម្រង់ទេ គឺរបៀបដូចជាមានត្រឹមតែជាទម្រង់តែប៉ុណ្ណោះ។ ដូច្នេះពួកគេមិនបានពិនិត្យទៅលើបច្ចេកទេសនៃឧក្រិដ្ឋកម្មទាំងអស់នោះ ដើម្បីអាចឲ្យដឹងថាតើមានច្បាប់អនុវត្តបានដែរឬទេ។ ដូច្នេះ យោងតាមភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនោះ គឺអង្គជំនុំជម្រះបានបង្កើតនូវអញ្ញត្រកម្មចំពោះការពិនិត្យពាក់ព័ន្ធនឹងបញ្ហានេះ។ ក៏ប៉ុន្តែគោលការណ៍នីត្យានុកូលភាពនេះ គឺថាវាមិនមានការលើកលែងបែបហ្នឹងទេ គឺត្រូវតែពិនិត្យទាំងអស់គ្រប់កាលៈទេសៈ ទាំងពេលសង្គ្រាម ទាំងឧក្រិដ្ឋគ្រោះថ្នាក់ចំពោះសាធារណជន ឧទាហរណ៍ដូចជា ភេរវកម្មជាដើមនេះ។ ដូច្នេះ នៅពេលដែលយើងពិនិត្យធ្វើបែបហ្នឹង គឺថាអង្គជំនុំជម្រះគាត់បានប្រកាន់យកនូវវិចារណកិច្ចមួយដែលមានកំហុសខាងផ្លូវច្បាប់ ដោយរំលោភលើគោលការណ៍ច្បាប់ គឺអង្គជំនុំជម្រះសាលាដំបូងបង្ហាញនូវភាពលម្អៀងនិងភាពអគតិ។

យើងបានបង្ហាញច្បាស់រួចមកហើយនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើង យើងមិនត្រឡប់មកនិយាយលម្អិតដដែលវិញទេ ប៉ុន្តែនៅទីនេះ គឺគ្រាន់តែយើងបង្ហាញពីការឆ្លើយតបមួយចំនួនទៅកាន់សហព្រះរាជអាជ្ញានៅក្នុងសារណារបស់យើង។ តើសហព្រះរាជអាជ្ញាគាត់បាននិយាយអ្វីខ្លះ? សហព្រះរាជអាជ្ញាគាត់បានយកនូវទឡ្ហីករណ៍របស់អង្គជំនុំជម្រះ ហើយបន្ថែមនូវធាតុផ្សំបន្ថែមដែលវាមិនមានលក្ខណៈគួរឲ្យទុកចិត្តបានទេ។ គាត់បាននិយាយថា យុទ្ធសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ពាក់ព័ន្ធទៅនឹងគោលការណ៍នីត្យានុកូលភាព ហើយគាត់បកស្រាយរបៀបឱកាសនិយម ពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងបង្ហាញអំពីធាតុផ្សំអង្គហេតុពាក់ព័ន្ធនឹងភាពអាចប្រមើលមើលបាន។ ជាដំបូងគាត់និយាយអំពីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ពាក់ព័ន្ធនឹង

គោលការណ៍នីត្យានុកូលភាព។ គឺគោលការណ៍នេះ ត្រូវបានពិភាក្សាជាច្រើនដងហើយនៅចំពោះមុខ អ.វ.ត.ក ហើយនេះជាលើកទីមួយ ហើយដែលយើងឃើញថា មានការយោងទៅដល់យុត្តិសាស្ត្រ ក្រោយសង្គ្រាមលោកលើកទី២ ពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយចំណុចនេះគឺមានអ្នកច្បាប់អ្នកអនុវត្តផ្នែកច្បាប់ក៏បាននិយាយច្រើនរួចមកហើយ។ ដូច្នេះគឺថាសាលក្រមហ្នឹង ក្រោយសង្គ្រាមលោកលើកទី២នេះ គេធ្វើឡើងដោយរបៀបប្រញាប់ប្រញាល់ខ្លាំងណាស់។ អ៊ីចឹងហើយ ទោះបីជានៅក្នុងឧទាហរណ៍ដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ១២១ហ្នឹង គាត់ដកស្រង់នូវសាលដីកា គឺដកស្រង់របៀបចោះ ចោលៗកាត់ត គាត់និយាយថា មុខតំណែងដែលមនុស្សមួយចំនួនបានកាន់កាប់នៅក្នុងរដ្ឋាភិបាលនៅ -- នៅក្នុងរដ្ឋាភិបាល វ៉ាច្ឆូ នោះ គឺគាត់បន្ថែមពាក្យថាវា ក្នុងចំណោមមនុស្សមួយចំនួនទាំងអស់នោះ។ ដូច្នេះគាត់ដកស្រង់មក គឺដកស្រង់មិនពេញលេញទេ គឺវាមិនគ្រប់លក្ខណៈទេ គាត់កាត់ចំណុចណាដែលមានប្រយោជន៍ចំពោះគាត់ ហើយគាត់ក៏បានបកស្រាយតាមរបៀបឱកាសនិយមនូវយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្ស។ ហើយសហព្រះរាជអាជ្ញាក៏ដកស្រង់របៀប មិនពេញលេញដែរ គឺគាត់បាននិយាយថា នៅក្នុងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបនោះ គឺវាមានការបែងចែកគ្នាច្បាស់លាស់ គឺថាក្នុងករណីដែលការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនោះ មិនត្រូវបានវិនិច្ឆ័យថាវាមានភាពពាក់ព័ន្ធទេ ហើយនិងលក្ខណៈមួយទៀត គឺថា អង្គហេតុហ្នឹងវាមានលក្ខណៈធ្ងន់ធ្ងរ ហើយធ្ងន់ធ្ងររហូតទៅដល់ថា វាមានលក្ខណៈជាឧក្រិដ្ឋច្បាស់លាស់ណាស់។ ហើយបន្ទាប់មកទៀត សហព្រះរាជអាជ្ញាក៏បានដកស្រង់នូវសាលដីកា កូណូណូ ដែលជាយុទ្ធសាស្ត្រមួយគឺថា មានដោយឯកឯង គ្មានយុត្តិសាស្ត្រណាដូចយុត្តិសាស្ត្រហ្នឹងទេ គឺមានតែមួយហ្នឹងទេ។ អ៊ីចឹងយើងមិនអាចនិយាយជាលក្ខណៈទូទៅយកមកនិយាយបានទេ ព្រោះថាវាមានតែមួយករណីហ្នឹងមួយ ហើយយើងមិនអាចទាញយកជាលក្ខណៈទូទៅពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មហ្នឹងបានទេ ក្នុងក្របខ័ណ្ឌនៃសារណារបស់យើង គឺយើងបានដកស្រង់នូវសាលដីកាមួយចំនួនរួចមកហើយ ជាពិសេស សាលដីកា វ៉ាស៊ីឡូស្កាស ទល់នឹង ប្រទេស លីទុអានី ដែលចេញដោយតុលាការកំពូលនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប នៅឆ្នាំ២០១៥ នោះ និយាយអំពីបញ្ហាប្រល័យពូជសាសន៍ គឺឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្ម។ ដូច្នេះ រឿងហេតុវាអត់មានការបែងចែកឲ្យច្បាស់លាស់រវាងការវាយតម្លៃភាពធ្ងន់ធ្ងរ ហើយនិងអង្គហេតុដែលមានភាពធ្ងន់ធ្ងរនោះទេ។

[១០:១៨:៤១]

ហើយមានយោបល់របស់តុលាការកំពូលដែលបង្ហាញច្បាស់អំពីគោលការណ៍នេះ គឺនៅក្នុង

យោបល់ពិគ្រោះលេខ P16 219 001 ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ដែលយើងបានដាក់បញ្ចូលទៅក្នុងបញ្ជីសម្អាងផ្លូវច្បាប់របស់យើងគឺអង្គជំនុំជម្រះតុលាការកំពូលនោះ បាននិយាយអំពីនីតិកម្មពាក់ព័ន្ធទៅនឹងបទល្មើស នៅក្នុងយោបល់នេះ អង្គជំនុំជម្រះតុលាការកំពូលបានរំឭកអំពីគោលការណ៍ទូទៅដែលទាញចេញដោយយុទ្ធសាស្ត្ររបស់ខ្លួនពាក់ព័ន្ធទៅនឹងសច្ចភាពផ្លូវច្បាប់ និងភាពអាចប្រមើលមើលបានដែលវាកើតចេញពីមាត្រា៧ នៃអនុសញ្ញា។ គឺពាក់ព័ន្ធទៅនឹងគោលការណ៍អនីត្យានុកូលភាព គឺមិនមាននិយាយអំពីបញ្ហាភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទេ គឺនិយាយអំពីធាតុផ្សំ។ ដូចឧទាហរណ៍នៅកថាខណ្ឌ៦០ នៃមតិយោបល់នេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរំឭកថា លក្ខខណ្ឌដែលវាយតម្លៃអំពីការប្រមើលមើលបាននូវការព្យាករបាននោះ គេត្រូវតែបំពេញសម្រាប់ការឲ្យនិយមន័យទៅលើឧក្រិដ្ឋកម្ម ក៏ដូចជាចំពោះទោសដែលកើតចេញពីឧក្រិដ្ឋកម្មនោះ។

អង្គជំនុំជម្រះតុលាការសិទ្ធិមនុស្សអឺរ៉ុបក៏បានបញ្ជាក់អំពីអានុភាពនៃសញ្ញាណភាពអាចប្រមើលមើលបាន ដែលវាអាស្រ័យយ៉ាងធ្ងន់ធ្ងរទៅលើខ្លឹមសារនៃអត្ថបទ។ ចំណុចទី៣ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះគឺ ធាតុផ្សំនៃឧក្រិដ្ឋកម្មគឺថា លោក ខៀវ សំផន គាត់អាចដឹងបាន គឺនៅកថាខណ្ឌ៣៣ នៃសារណារបស់គាត់ ទឡ្ហីករណ៍នេះគឺវាមិនត្រឹមត្រូវទេ។ ខ្ញុំដូចជាមិនមើលឃើញថា គាត់ លោក ខៀវ សំផន ហ្នឹងគាត់ដឹងអំពីទម្រង់នៃការទទួលខុសត្រូវ ឬទម្រង់នៃឧក្រិដ្ឋកម្មអ្វីនោះទេ ហើយគាត់ក៏មិនមានការវិភាគអីស៊ីជម្រៅទៅលើច្បាប់ពាណិជ្ជកម្មអន្តរជាតិដែរ ដូចនៅក្នុងនិក្ខេបបទបណ្ឌិតរបស់គាត់នោះ។ ដូច្នេះ សហព្រះរាជអាជ្ញានោះ គាត់បានប្រព្រឹត្តខុសពាក់ព័ន្ធនឹង -- អ៎! សុំទោស -- គឺអង្គជំនុំជម្រះសាលាដំបូងនោះ គាត់បានប្រព្រឹត្តខុសពាក់ព័ន្ធទៅនឹងគោលការណ៍នៃនីត្យានុកូលភាព។

[១០:២១:៥៧]

ហើយសហព្រះរាជអាជ្ញាក៏មិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់យើងដែរ។ យើងបានសង្កត់ធ្ងន់ទៅលើការបង្ហាញអំពីនិយមន័យនៃឧក្រិដ្ឋកម្មមួយចំនួននៅក្នុងច្បាប់អន្តរជាតិ។ ដូច្នេះ គឺយើងឃើញថា ដីកាដំណោះស្រាយបានចេញនៅឆ្នាំ២០១០ ហើយអង្គហេតុដែលត្រូវអនុវត្ត និងច្បាប់ និងអង្គហេតុដែលត្រូវអនុវត្តចំពោះលោក ខៀវ សំផន នោះគឺវាកើតតាំងពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ ឯណោះអ៊ីចឹង។ ដូច្នេះ ទម្រង់នៃការទទួលខុសត្រូវ និងឧក្រិដ្ឋកម្មមួយចំនួនគឺថា លោក ខៀវ សំផន គាត់មិនអាចប្រមើលមើលបានដឹងទេ ដូចជាសហឧក្រិដ្ឋកម្មរួមជាដើមនោះ។ ទោះបីជាសហព្រះរាជអាជ្ញាសាលាដំបូង ឬតុលាការកំពូលផ្តល់នូវនិយមន័យផ្សេងៗគ្នាទៅលើធាតុផ្សំទាំងអស់នេះក៏ដោយ។ អង្គជំនុំជម្រះគឺថា គាត់បាន

បរាជ័យក្នុងការកំណត់នូវនិយមន័យទូទៅពាក់ព័ន្ធទៅនឹងបញ្ហាផ្លូវច្បាប់នេះ គឺថាយើងសុំឲ្យអង្គជំនុំជម្រះពិនិត្យមើលនូវសារណាបណ្តឹងសាទុក្ខរបស់យើងគឺនៅកថាខណ្ឌ៥៦៩ ដល់ ៥៧១។ ដូច្នេះ គឺមានការអនុវត្តច្បាប់ដែលវាមិនមានកើតនៅក្នុងពេលអង្គហេតុ ហើយយើងនឹងមិននិយាយអំពីបញ្ហានេះ នៅពេលក្រោយបន្តមកទៀត។ ចំណុចទីពីរ គឺការកែប្រែឧក្រិដ្ឋកម្មសម្លាប់រង្គាលទៅជាឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាត។ យើងបានបញ្ជាក់អំពីជំហររបស់យើងរួចមកហើយនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងគឺនៅកថាខណ្ឌ១៣៥ ដល់ ១៥៧ គឺយើងមានជំហរថា អង្គជំនុំជម្រះហ្នឹង គឺថាមិនបានប្រាប់យើងអំពីការកែប្រែបទចោទហ្នឹងទេ ហើយអង្គជំនុំជម្រះសាលាដំបូងហ្នឹងបានបញ្ចូលធាតុផ្សំថ្មី គឺចេតនាប្រយោល។ ហើយទី៣ ហ្នឹងគឺវាមានបញ្ហានៃភាពលម្អៀងពាក់ព័ន្ធទៅនឹងអភិក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ យើងបានឆ្លើយតបរួចមកហើយទៅនឹងសហព្រះរាជអាជ្ញានៅក្នុង -- ពាក់ព័ន្ធទៅនឹងសារណារបស់ព្រះរាជអាជ្ញា គឺកថាខណ្ឌ៨៥ ដល់ ៩១។ ហើយយើងទទួលបានការជូនដំណឹងអំពីសាលដីកា០០២/០១ ក៏ប៉ុន្តែវាមានបញ្ហាពាក់ព័ន្ធនឹងព័ត៌មាន គឺភាពមិនផ្តល់សុពលភាព ពីព្រោះថាមេធាវីការពារក្តីហ្នឹងគឺថាមិនបានយល់ដឹងច្បាស់អំពីបញ្ហាទាំងអស់នេះ។ ខ្ញុំសូមរំឭកឡើងវិញពាក់ព័ន្ធទៅនឹងបញ្ហាដែលយើងធ្លាប់បានរំឭកអំពីគោលការណ៍របស់យើងរួចមកហើយ ហើយអង្គជំនុំជម្រះយល់ច្បាស់ហើយ។ ខ្ញុំសូមនិយាយអំពីបញ្ហាកថាខណ្ឌ៨៧ របស់សហព្រះរាជអាជ្ញា គាត់និយាយថា តុលាការកំពូលដែលជាចំណុចសំខាន់នោះ ហើយសហចៅក្រមស៊ើបអង្កេតដែលជាអ្នកចេញសេចក្តី ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ហ្នឹង គឺសុទ្ធតែបានបកស្រាយនូវធាតុផ្សំអត្តនោម័តិនៃការសម្លាប់រង្គាល ដូចជានិយមន័យនៃចេតនាប្រយោល។

[១០:២៦:០០]

នៅឆ្នាំ២០១៦ នៅពេលដែលតុលាការកំពូលគាត់បានបញ្ជាក់ថា គឺថាវីហ្នឹងមានចេតនាផ្ទាល់ក្នុងការសម្លាប់ ដែលសហព្រះរាជអាជ្ញាហ្នឹង គាត់មិនដែលបានបកស្រាយអំពីចេតនាប្រយោលនេះទេ។ គាត់មិនបានបកស្រាយអំពីធាតុផ្សំអត្តនោម័តិថា ជាចេតនាប្រយោលនោះទេ។ គឺយើងឃើញថានៅក្នុងអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងហ្នឹងគឺមិនមានចេតនាប្រយោលនោះទេ ហើយពាក់ព័ន្ធទៅនឹង--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យមេធាវីគាត់និយាយយឺតៗបន្តិចលោកប្រធាន គាត់និយាយញាប់ពេកអ្នក

បកប្រែតាមអត់ទាន់លោកប្រធាន។

[១០:២៧:២០]

**លោកស្រី អង់តា ហ្គីសសេៈ**

*(គ្មានការបកប្រែ)*

ខ្ញុំនឹងនិយាយយឺតជាងនេះបន្តិច ព្រោះថាបកប្រែអត់ទាន់ ប៉ុន្តែខ្ញុំភ័យដោយសារពេលវេលាដើរទៅមុខលឿន។ ឥឡូវនេះខ្ញុំសូមចាប់ផ្តើមទាក់ទងទៅនឹងនៅក្នុងដីកាដំណោះស្រាយនៅកថាខណ្ឌ១៣៩១ *(ស៊ីក)* ដល់ ១៣៩០ ធាតុផ្សំអត្តនោម័តិនោះគឺមានចេតនាដោយប្រយោល។ យើងឃើញនៅកថាខណ្ឌ ១៣៧៣ ដល់ ១៣៨០ នេះយើងឃើញច្បាស់ហើយគឺថាការដាក់បន្ទុកលើឃាតកម្មសម្លាប់នោះហ្នឹងគឺវាមានភាពខុសគ្នារវាងនឹងការសម្លាប់រង្គាល។ ចៅក្រមស៊ើបអង្កេតមិន-- *(គ្មានការបកប្រែ)* -- ខុច ទាក់ទងទៅនឹងលក្ខខណ្ឌជីវភាពនោះគាត់បានជ្រើសរើសយកតែសញ្ញាណនៃការសម្លាប់ដោយរង្គាលតែប៉ុណ្ណោះ។ អ៊ីចឹងយើងឃើញថា មានភាពខុសគ្នារវាងចេតនាទាំងពីរនេះ ហើយវាមានសារៈសំខាន់ណាស់ក្នុងការលើកឡើងពីចំណុចនេះ។ ទាក់ទងទៅនឹងច្បាប់ដែលអនុវត្តបានសហព្រះរាជអាជ្ញាបានធ្វើការរៀបរាប់ដោយគ្មានក្បាល គ្មានកន្ទុយ មិនគ្រប់ជ្រុងជ្រោយ គាត់បានលើកឡើងពីយុត្តិសាស្ត្រចំនួនបី។ ក៏ប៉ុន្តែនៅពេលដែលយើងមើលកំណត់ត្រាជើងទំព័រនោះ យើងឃើញថាៗមានរឿងក្តីហ្នឹងដល់ទៅ ១៣ឯណោះ ដែលគេបានលើកឡើង គេបានដកស្រង់នោះ។ ហើយគាត់បានផ្តោតទៅលើតែបីប្រភពតែប៉ុណ្ណោះ គឺមានរឿងក្តីដែលនៅក្នុងសាលាដំបូងតែប៉ុណ្ណោះ ដូចរឿងក្តីរបស់ ប្លាហ្កោស៊ីវិក ដែលគាត់បាននិយាយអំពីចេតនាដោយប្រយោល ហើយនិងរឿងក្តី កេហ្សុស៊ីម៉ា ដែលគាត់និយាយពីថា ចេតនាដោយធ្វេសប្រហែស ហើយនិងមួយទៀតគឺរឿងក្តី ស្តាគិច ដែលជំទាស់ទៅនឹងចេតនាដោយធ្វេសប្រហែសនោះ។ ដូច្នេះ យើងឃើញថា មិនដែលមានលើកឡើងអំពីចេតនាដោយផ្ទាល់ទាក់ទងនឹងធាតុផ្សំអត្តនោ-ម័តិនោះទេ។

ទាក់ទងរឿងក្តីទាំងពីរនេះដែលព្រះរាជអាជ្ញាដកស្រង់ឡើងហ្នឹង គាត់មិនដែលនិយាយអំពីការវាយប្រហារនិងធាតុផ្សំសត្យានុម័តទេ។ សាលដីកា --*(គ្មានការបកប្រែ)*-- អ៊ីចឹងគាត់ផ្អែកទៅលើយុត្តិ-សាស្ត្រទាំងអស់នោះ គឺវាមិនត្រឹមត្រូវនោះទេ។ ហើយវាជាការមិនត្រឹមត្រូវផងដែរក្នុងការនិយាយថាពីសាលដីការឿង ខុច ហ្នឹងទៅអង្គជំនុំជម្រះសាលាដំបូងហ្នឹងបានបកស្រាយថា វាមានចេតនាប្រយោលនោះ ព្រោះថាសាលដីកា ខុច ហ្នឹងនៅកថាខណ្ឌ៣២៣ បែងចែកឲ្យច្បាស់ធាតុផ្សំនៃការទទួលវិញ

ហើយនិងការសម្លាប់រង្គាល។ ខ្ញុំសូមដកស្រង់នៅក្នុងកំណត់ត្រាជើងទំព័រ៧១៦--

**អ្នកបកប្រែ៖**

បកមិនទាន់។

លោកប្រធានសូមឲ្យលោកស្រីមេធាវីនិយាយយឺតបន្តិច ពីព្រោះគាត់អានបកអត់ទាន់លោកប្រធាន។

[១០:៣២:០០]

**លោកស្រី អង់តា ហ្គីសសេ៖**

ដូច្នេះដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ហើយនិងការតវ៉ារបស់យើងនៅនឹងសាលាដំបូងនោះគឺថាយើងមិនអាចមានលទ្ធភាពតវ៉ាហ្នឹងតាំងពីសាលាដំបូង -- *(គ្មានការបកប្រែ)* -- ព្រះរាជអាជ្ញានិយាយថា យើងត្រូវការពារហើយនិងសូមការបំភ្លឺតវ៉ា ហើយនិងការធ្វើការបំភ្លឺយុត្តិសាស្រ្តដែលការលើកឡើងដែលថា មិនអាចអនុវត្តបាន -- ដែលអាចអនុវត្តបាននោះ ពីព្រោះថា--

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

*(គ្មានការបកប្រែ)*

**លោកស្រី អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមៗផ្អាកតិចលោកស្រីនិយាយ។ សូមអញ្ជើញ!

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

សូមទោសខ្ញុំកាត់បន្តិច ប៉ុន្តែខ្ញុំតាមអត់ទាន់ វាធ្វើឲ្យខ្ញុំមានការយល់ច្រឡំ គឺថាមានពីរចំណុចដែលមេធាវីទើបលើកឡើងខ្លីៗអំមិញហ្នឹង ហើយវាជារឿងសំខាន់គឺគាត់និយាយថា ការកំណត់ប្រភេទនៃបទល្មើសហ្នឹងធ្វើឲ្យមាននូវធាតុផ្សំថ្មី ដូច្នេះចង់ឲ្យគាត់បញ្ជាក់មានន័យយ៉ាងម៉េច? ហើយគាត់ក៏បានលើកឡើងផងដែរថា ធាតុផ្សំសីលធម៌មិនត្រូវបានពិចារណា។ ខ្ញុំយល់ -- ខ្ញុំមិនច្បាស់ថា តើគាត់ចង់មានន័យបែបណាដែលថា ធាតុផ្សំសីលធម៌អាចដោយសារគាត់និយាយជាភាសាបារាំង ហើយបកទៅអង់គ្លេស ឬមួយក៏យ៉ាងម៉េចដែរ ខ្ញុំចង់ឲ្យលោកស្រីមេធាវីបកស្រាយទៅលើពីរចំណុចនេះ។ សូមអរគុណ ឯកឧត្តមប្រធាន។

[១០:៣៤:២១]

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំនិយាយអំពីធាតុផ្សំថ្មីហ្នឹងពីចេតនាប្រយោលនៅក្នុងក្របខ័ណ្ឌនៃការសម្លាប់រង្គាល។ អ្វីដែលខ្ញុំលើកឡើងនេះគឺថាយើងមិនអាចត្រៀមលក្ខណៈការពារលោក ខៀវ សំផន ទៅលើការចោទប្រកាន់ទាក់ទងនឹងឃាតកម្មសម្លាប់មនុស្សទៅលើចេតនាដោយប្រយោលនោះទេ។ អ៊ីចឹងផ្តល់ឲ្យមានចេតនាចង់សម្លាប់ពាក់ព័ន្ធនឹងការសម្លាប់រង្គាលនេះ វាខុសពីឧក្រិដ្ឋកម្មប្រឆាំងនឹង -- ឧក្រិដ្ឋកម្មមនុស្សឃាត។

[១០:៣៥:១៥]

**ចៅក្រម ម៉ូរីន ហាឌឹង ក្លាក៖**

ដូច្នេះចំពោះការកំណត់ប្រភេទនៃបទល្មើស អ៊ីចឹងថាតើយើងអាចធ្វើដូច្នេះបានឬទេ ចំពោះខ្ញុំ ខ្ញុំយល់ថាការពិភាក្សាអំពីបញ្ហានេះក្នុងរយៈពេលពីរបីនាទីហ្នឹង គឺវាមិនអាចធ្វើទៅបានទេ។

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំសូមបញ្ជាក់ថា ពេលវេលាបន្ថែមហ្នឹង គឺត្រូវការ វាមានភាពចាំបាច់ណាស់ដើម្បីកុំឲ្យខ្ញុំនិយាយលឿនពេក ដើម្បីឲ្យអ្នកទាំងអស់គ្នាអាចតាមខ្ញុំទាន់ ក៏ប៉ុន្តែទោះយ៉ាងនេះក្តី ការភាពខុសគ្នា គឺថាដើម្បីឆ្លើយតបនឹងសំណួររបស់លោកស្រីហ្នឹង គឺថាយើងត្រូវការពេលវេលាបន្ថែមហ្នឹង គឺថាបើគិតឲ្យសមហេតុផលហ្នឹងគឺថាក្នុងពេលហ្នឹងតែម្តងទៅ បើសិនជាអនុញ្ញាតឲ្យខ្ញុំធ្វើយ៉ាងដូច្នេះ ហើយសុំឲ្យតុលាការកំពូលវិនិច្ឆ័យទៅ ថាពេលបន្ថែមឲ្យខ្ញុំនោះនៅពេលណា? ហើយបើខ្ញុំថាជាសមហេតុផលគឺពេលហ្នឹងតែម្តង។

**ចៅក្រម ម៉ូរីន ហាឌឹង ក្លាក៖**

សូមអរគុណ ឥឡូវខ្ញុំគិតថាអង្គជំនុំជម្រះប្រហែលជាត្រូវពិភាក្សាគ្នាហើយ យើងនឹងពិភាក្សានៅពេលក្រោយ។

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំសូមបន្ត។ ការសម្លាប់រង្គាលហ្នឹង មិន -- កំណត់និយមន័យ ហើយនិងរួមបញ្ចូលនឹងចេតនាប្រយោលនោះទេ ហើយនៅក្នុងសាលាដំបូងក៏អ៊ីចឹង នៅតុលាការកំពូលហ្នឹងក៏ដោយ ហើយយើងឃើញមានថា ការសម្លាប់រង្គាលនេះ ហើយយើងមិនទាន់បានមានឱកាសក្នុងការធ្វើការកត់សម្គេតទាក់ទងនឹងចំណុចនេះទេ។ តុលាការអន្តរជាតិសិទ្ធិមនុស្សនៅក្នុងសារណារបស់យើងហ្នឹង យើងបានដឹងថានៅពេលដែលមានការប្រែបទចោទ គឺត្រូវតែមានការកែប្រែហ្នឹងគឺត្រូវតែប្រកាសដោយអង្គជំនុំជម្រះ ឬក៏

សហព្រះរាជអាជ្ញាដើម្បីធ្វើយ៉ាងណាឲ្យភាគីការពារក្តីអាចធ្វើការកត់សម្គាល់បាន។ ហើយមានយុត្តិសាស្ត្រផ្សេងទៀត ដែលទាក់ទងនឹងចំណុចនេះដែរ ខ្ញុំយោងទៅកំណត់ត្រាជើងទំព័ររឿងក្តីជ្រាសស្បៀ។ យើងសូមគូសបញ្ជាក់ថា តុលាការកំពូល និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងខាងព្រះរាជអាជ្ញាយើងនេះ យើង -- សហព្រះរាជអាជ្ញានិយាយថា យើងមិនមានទទួលរងព្យសនកម្មនោះទេ គឺការលើកឡើងដូចនេះ គឺវាខុសស្រឡះតែម្តង ព្រោះថានៅក្នុងសាលដីកា ០០២/០១ ព្រះរាជអាជ្ញានោះបាននិយាយថា ត្រូវតែយល់ពីសញ្ញាទាំងអស់នេះជារួម ហើយដឹងថាតើវារកដំណោះស្រាយយ៉ាងដូចម្តេច ក៏ប៉ុន្តែបញ្ហាវានៅត្រង់ថា នៅក្នុងក្របខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍ចំពោះមុខ អ.វ.ត.ក នេះ គឺថា លោកស្រីចៅក្រមជាតុលាការឧទ្ធរណ៍ផង ហើយនិងតុលាការកំពូលផង។ អ៊ីចឹងសេចក្តីសម្រេចដែលអស់លោកលោកស្រីចៅក្រមចេញនៅកថាខណ្ឌ -- នៅរឿងក្តីឌុច ឬក៏សំណុំរឿង០០២/១ នោះ គឺអស់លោកលោកស្រីចៅក្រមហ្នឹង មិនត្រឡប់មកនិយាយសើៗអំពីការវាយតម្លៃភស្តុតាងនោះទេ។

អ៊ីចឹងបើសិនជាយើងអត់ បាត់បង់លទ្ធភាពទាក់ទងលទ្ធភាពនិយាយ -- ផ្តល់ពីសម្អាងហេតុរបស់យើងនោះ គឺយើងបាត់ឱកាសទាំងអស់តែម្តង។

[១០:៤០:០៩]

ខ្ញុំសូមរំឭកដល់យុត្តិសាស្ត្ររបស់លោក លោកស្រីចៅក្រមមួយទៀត គឺនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ កាលនោះមេធាវី នួន ជា បានដាក់សំណើរទៅ ព្យសនកម្មនោះពិតណាស់ ហើយគឺដំណោះស្រាយគឺត្រូវតែលើកលែងការចោទប្រកាន់។

ទាក់ទងនឹងការធ្វើទារុណកកម្មនេះ មាននៅក្នុងសារណារបស់យើង គឺថាតុលាការបានរំលោភមាត្រា១៥ ស្តីពីការធ្វើទារុណកម្ម គឺវាមានលក្ខណៈច្បាស់លាស់ ហើយអង្គជំនុំជម្រះបានធ្វើការបកស្រាយហួសពីភាពច្បាស់លាស់នៃអនុសញ្ញានេះ ដែលបញ្ជាក់ថា ការលើកលែងតែមួយគត់ សម្រាប់ការប្រើប្រាស់ ឬការហាមឃាត់នៃការប្រើប្រាស់ ការធ្វើទារុណកម្មនោះគឺប្រើបាន តែសម្រាប់ថា រឿងអង្គហេតុនោះពិតជាកើតឡើងមែន។ ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចពីដំបូងថា នៅឯកសារ E300 -- បានរំឭកពីគោលការណ៍នេះ ក៏ប៉ុន្តែអង្គជំនុំជម្រះបានព្យាយាមប្រើខ្លឹមសារនៃឯកសារដែលមានវិការៈនេះដែលទទួលបានពីការធ្វើទារុណកម្មនេះ ដើម្បីបង្ហាញថាអង្គហេតុផ្សេងមានការកើតមាន -- មានការបង្ហាញអង្គហេតុផ្សេង។

[១០:៤២:០៣]

អ៊ីចឹងគឺថា ចៅក្រម ហ្វេនស៍ កាលនោះគាត់បានចេញមតិយោបល់ជំទាស់ដាច់ដោយឡែក ហើយខាងសហព្រះរាជអាជ្ញាហ្នឹងគឺថា មិនមានបញ្ហានោះ មានកំហុសអីទេ គឺដែលយើងអាចយកភស្តុ-តាងបានពីការធ្វើទារុណកម្មនោះហ្នឹង។ ហើយភស្តុតាងដែលមាននៅក្នុងកំណត់ត្រាការធ្វើទារុណកម្មនោះគឺដូចជាសក្ខីកម្មរបស់ ឌុច ជាដើមនោះ គឺថា។ សក្ខីកម្មរបស់គាត់នោះអាចទទួលយកបាន កាលនោះនិយាយពាក់ព័ន្ធនឹង ប៉ង់ អីជាដើម ហើយពាក់ព័ន្ធនឹង ខៀវ សំផន។ ហើយពីអំពើ ហើយនិងអាកប្បកិរិយារបស់ជនជាប់ចោទ ដែល ឌុច ធ្វើសក្ខីកម្មទៅលើនោះ ដោយផ្អែកទៅលើខ្លឹមសារនៃចម្លើយដែលបានពីមន្ទីរស-២១ នោះគឺថា គាត់ថាអាចប្រើបាន គឺវាមិនត្រឹមត្រូវទាំងអស់។ ហើយធម្មតាមិនអាចទទួលយកបានទេ ហើយការឆ្លើយតបរបស់យើងគឺថា នៅមាត្រាទី១៥ គឺមិនត្រូវឲ្យមានការលើកលែងណាមួយនោះទេ ចំពោះបញ្ហាការប្រើអំពើទារុណកម្មនេះ។ សេចក្តីសម្រេចរបស់តុលាការកំពូលបានបញ្ជាក់ថា តុលាការកំពូលយល់ឃើញថា ខ្លឹមសារមាត្រាទី១៥ មានលក្ខណៈច្បាស់លាស់ដើម្បី --*(គ្មានការបកប្រែ)* --អនុវត្តតឹងរ៉ឹងនៅមាត្រានេះ។ ហើយបន្ទាប់មកទៀត ខ្លួនបាននិយាយថានៅពេលដែលសេចក្តីសង្ខេបនៃចម្លើយសារភាពមានព័ត៌មានចេញពីអ្នកផ្សេងក្រៅពីអ្នកជាជនរងគ្រោះគឺអាចយកប្រើប្រាស់បាន ដើម្បីបង្ហាញកាលៈទេសៈមួយចំនួនដឹងថាអ្នកណាមានវត្តមាននៅទីនោះ ហើយនិងរបៀបធ្វើទារុណកម្មយ៉ាងម៉េច? ហើយដំណើរការសួរចម្លើយនោះយ៉ាងម៉េចដែរ?

[១០:៤៤:៣៧]

ហើយក្រៅពីធាតុផ្សំទាំងអស់នេះ អស់លោក លោកស្រី ចៅក្រម បានលើកឡើងថា ព័ត៌មានដែលទទួលបានពីការធ្វើទារុណកម្មមិនអាចទទួលយកបានជាភស្តុតាងនោះទេ ទោះបីជាវាពាក់ព័ន្ធទៅនឹងចំណុចផ្សេង ហើយនិងមានតម្លៃជាភស្តុតាងតិចតួចក៏ដោយ។ អ៊ីចឹង--

**ប្រធានអង្គជំនុំ៖**

សូមបញ្ជាក់ជូនតិចលោកស្រីមេធាវី ដោយសារឥឡូវនេះគឺឌីវីឌីបានអស់ហើយ អ៊ីចឹងហើយសុំឲ្យខាងបច្ចេកទេសប្តូរឌីវីឌីមួយភ្លែតសិន។ បាទ សូមផ្អាកបន្តិច!

*(សម្រាករយៈពេលខ្លី ប្តូរឌីវីឌី)*

[១០:៤៦:១៣]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់ជូនថា ខាងសហមេធាវីការពារក្តីហ្នឹងនៅសល់ប្រហែលជាប៉ុន្មាននាទីទៀតចប់?

សូមបញ្ជាក់ជូនបន្តិច។ ហើយបើខ្លី យើងអាចធ្វើបន្ត។

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំត្រូវការយ៉ាងហោចណាស់១០នាទីទៀត ហើយសូមបញ្ជាក់ថា ខ្ញុំមិនទាន់បានឆ្លើយតបទៅនឹងអង្គជំនុំជម្រះពីធាតុផ្សំភស្តុតាងដោះបន្ទុក។ បើនិយាយមែនទែនទៅ ដើម្បីឲ្យគ្រប់គ្រាន់នោះត្រូវការពេល១៥នាទី។ ហើយបើយ៉ាងម៉េចយ៉ាងម៉ានោះ គឺខ្ញុំអាចនិយាយអំពីបញ្ហាទាំងអស់នេះនៅពេលក្រោយទៀតនៅក្នុងសប្តាហ៍នេះ ក៏ប៉ុន្តែខ្ញុំគិតថា១៥នាទីនេះប្រហែលជាសមរម្យហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញលោកស្រីមេធាវី សូមអញ្ជើញបន្ត អនុញ្ញាតឲ្យ១៥នាទីបន្តទៀត បាទ។ សូមអញ្ជើញ!

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំនិយាយថាខ្ញុំយល់យ៉ាងម៉េចលោកប្រធាន? លោកប្រធានឲ្យខ្ញុំចាប់ផ្តើមនិយាយឥឡូវហ្នឹង ឬក៏លោកប្រធានចង់សម្រាកសិន? ខ្ញុំអត់យល់។

[១០:៤៨:២០]

**ប្រធានអង្គជំនុំ៖**

ឲ្យបន្តទៀត១៥នាទី ហើយបានសម្រាកតាមក្រោយ។

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ដូចដែលខ្ញុំបានលើកឡើងឡើងអម្បាញ់មិញអ៊ីចឹង ធាតុផ្សំដែលអង្គជំនុំជម្រះបានប្រើប្រាស់នៅក្នុងឯកសារដែលចេញពីការធ្វើទារុណកម្មនៅគុកទួលស្លែងនោះ គឺនៅកថាខណ្ឌ-- ទោះបីជាខាងព្រះរាជអាជ្ញាហ្នឹងឆ្លើយតបមកថា សៀវភៅកំណត់ត្រានេះ គឺវាមិនខុសពីកំណត់ត្រានៅក្នុងការសួរឆ្លើយ ក៏ប៉ុន្តែបញ្ជីដែលអង្គជំនុំជម្រះប្រើប្រាស់នោះគឺមិនមែនតែជាបញ្ជីនោះទេ គឺខ្លឹមសារនោះក៏បានប្រើប្រាស់ដោយអង្គជំនុំជម្រះដែរ ដើម្បីធ្វើការស៊ីសង្វាក់គ្នា។ ហើយអស់លោកចៅក្រមអាចមើលនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍យើងបាន។ ហើយសក្ខីកម្មរបស់ ឌុច ហ្នឹងក៏វាមានវិការៈដែរ ដូចនិយាយពី ប៉ង់ ចាប់ខ្លួននៅមន្ទីរស-២១ ហើយកាលនោះ ឌុច បានលើកឡើងអំពីវត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និយាយពីជោគវាសនារបស់ ជូ ជេត។ អ៊ីចឹងខ្ញុំយោងទៅលើសារណាបណ្តឹងឧទ្ធរណ៍របស់ខ្ញុំដែរ។

[១០:៥០:០៧]

ផ្នែកនៃសក្ខីកម្មរបស់ ឌុច នេះគឺថាដែលគាត់និយាយថា ខៀវ សំផន មានវត្តមាននៅទីនោះដែលនិយាយពីជោគវាសនារបស់ ប៉ង់ នោះគឺវាមិន -- មានវិការៈមិនត្រឹមត្រូវទេ គឺថាវាមាន -- ដោយសារមានការបង្ខំ ឬក៏ធ្វើបាបអីនៅមន្ទីរស-២១ នោះ គឺយើងមិនអាចប្រើភស្តុតាងនេះបានប្រឆាំងនឹង ខៀវ សំផន នោះទេ។ ដូច្នេះការអះអាងចាំបាច់ហ្នឹងត្រង់ចំណុចហ្នឹង ហើយឥឡូវនេះដើម្បីឆ្លើយតបទៅនឹងអង្គជំនុំជម្រះលើព្យសនកម្មទូទៅដែល ខៀវ សំផន ទទួលរងលើការប្រើប្រាស់ឯកសារដែលធ្វើការ -- បានពីការធ្វើទារុណកម្មនេះ គឺអង្គជំនុំជម្រះប្រើប្រាស់ឯកសារទាំងអស់នេះ ដើម្បីពីគោលនយោបាយសម្លាប់ខ្មាំង កម្ទេចខ្មាំង ថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួនមនុស្ស ហើយពីបញ្ជីរបស់មន្ទីរសន្តិសុខ ក្រាំងតាចាន់ បានប្រើបញ្ជីហ្នឹងដើម្បីគាំទ្រ។ ទាក់ទងទៅនឹងបញ្ហាកថាខណ្ឌ៤១៦នៃរបាយការណ៍របស់លោកស្រីចៅក្រមហ្នឹង ដែលនៅក្នុងរបាយការណ៍ហ្នឹងអស់លោកស្រីចៅក្រមបានសុំថាតើអង្គហេតុណាដែលត្រូវបានបញ្ចូលមកក្នុងសំណុំរឿង០០២នេះ ខ្ញុំសូមយកឧទាហរណ៍ពីរគឺរចនាសម្ព័ន្ធរដ្ឋបាល គឺថាគ្រាន់តែយើងកត់ចម្លងតែប៉ុណ្ណឹងដែលថាពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន ហើយទាក់ទងនឹងទំនួលខុសត្រូវរបស់គាត់ ខ្ញុំយកសុន្ទរកថាពីបក្សកុម្មុយនីស្តកម្ពុជា -- កងទ័ពកម្ពុជាដែលមាននៅក្នុងសារណារបស់យើង គឺថាអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដូចគ្នានឹងសំណុំរឿង០០២/០១ ដែលអង្គហេតុនេះត្រូវបានបដិសេធហើយនៅ -- ដោយតុលាការកំពូល ហើយពាក្យថាដែលគេយកទៅញាត់ចូលមាត់ ខៀវ សំផន នោះគឺវាមិនត្រឹមត្រូវនោះទេ។ ទោះបីជាមានការសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលក៏ដោយ អង្គជំនុំជម្រះបានកត់ចម្លង ហើយមិនបានពិចារណាអ្វីទេ។ ហើយមានចំណុចផ្សេងមួយទៀតដែលយើងឃើញឧទាហរណ៍ពីការដាក់សក្ខីកម្មរបស់ វឿន ដែលមាននៅក្នុងសម្ពាងហេតុសាលក្រមដែរ ដែលនៅក្នុងនោះ គឺមិនមានការយកភស្តុតាងដែលមេធាវីការពារក្តីលើកឡើងយកមកពិចារណាទេ។ ទាក់ទងនឹងភស្តុតាងដោះបន្ទុកនោះគឺមានឧទាហរណ៍ជាច្រើន ក៏ប៉ុន្តែខ្ញុំនឹងនិយាយអំពីការសួរសំណួររបស់សាក្សី ប៉ុងសួដ៍ ដែលយើងត្រូវដឹងថា នេះជាបញ្ហាធ្ងន់ធ្ងរណាស់ ត្រូវតែគោរពពីភស្តុតាងហើយនិងសិទ្ធិរបស់ជនជាប់ចោទ។

[១០:៥៣:៥៧]

ខ្ញុំសូមរំឮកថាចំពោះសំណុំរឿង០០២/០២នេះ យើងបានសុំស្តាប់តែសាក្សីចំនួនប្រាំពីរនាក់ប៉ុណ្ណោះ ប៉ុន្តែអង្គជំនុំជម្រះបានឲ្យសាក្សីមកនិយាយតែពីអង្គហេតុដែលមិនពាក់ព័ន្ធទៅនឹងសំណុំរឿងទៅវិញ។

តែអ្វីដែលបង្ហាញឲ្យយើងឃើញថា អង្គជំនុំជម្រះមានភាពលម្អៀងនោះគឺថា នៅក្នុងសំណុំរឿង០០២/០១ នោះយើងអាចសួរសំណួរទៅសាក្សីទាក់ទងទៅនឹងអង្គហេតុនៃសំណុំរឿង០០២/០១នេះ ហើយអង្គជំនុំជម្រះក៏បានសាក្សី សៅ សារុន ដែលបានមកបង្ហាញសក្ខីកម្ម ធ្វើសក្ខីកម្មនៅសំណុំរឿង០០២ ហើយនុ៎ង មកធ្វើ មកផ្ដល់ មកបង្ហាញខ្លួននៅសំណុំរឿង០០២/០២ ហ្នឹងដែរ ហើយយើងបានលើកឡើងនៅក្នុងសារណារបស់យើងផងដែរ។

ដូច្នេះនៅត្រង់ចំណុចនេះ គឺថា យើងឃើញថាមានភាពមិនស្មើគ្នា គឺថា សៅ សារុន ដែលគាត់សង្ឃឹមថា នឹងអាចមានភស្តុតាងដាក់បន្ទុកទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយហ្វ្រង់ស័រ ប៉ុងសូដ៍ ហើយនិង ស្ទីវ ហេដឌ័រ ដែលមានបទពិសោធន៍ពីស្រុកខ្មែរ ហើយថែមទាំងបទពិសោធន៍អំពីនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នេះផងដែរ ប្រហែលអាចបំភ្លឺយើងបានច្រើន។ គឺខ្ញុំសូមរំឭកផងដែរថា អង្គជំនុំជម្រះគឺបង្កព្យសនកម្មមកលើជនជាប់ចោទ ដោយសារយើងមិនបានមានឱកាសចោទសំណួរទៅ ស្ទីវ ហេដឌ័រ ហើយនិង ប៉ុងសូដ៍ ហើយពេលដែល ប៉ុងសូដ៍ គាត់ជាជនជាតិបារាំងគាត់នៅប្រទេសខ្មែរយូរហើយគាត់ចេះ គាត់ស្គាល់ភាសាខ្មែរ គាត់មានបទពិសោធន៍នៅស្រុកខ្មែរ មុនពេលខ្មែរក្រហមចូលកាន់អំណាចមកទៀត រហូតដល់ឆ្នាំ៧៥ទៀត ហើយគាត់ -- ដែលអង្គជំនុំជម្រះមិនព្រមស្ដាប់សក្ខីកម្មរបស់គាត់ ហើយទាក់ទងទៅនឹងនឹងសហករណ៍ និងរបៀបដែលដាំ ធ្វើស្រែហើយហ្វីលីព ស្សូត ដូចគ្នា គឺយើងមានលើកឡើងនៅក្នុងសារណារបស់យើង។ យើងសូមរំឭកថា យើងមិនអាចទទួលបានការបំភ្លឺ ឬអំពីសាក្សីទាំងអស់នេះ នៅក្នុងសំណុំរឿង០០២/២។ ព្រះរាជអាជ្ញាគឺលើកឡើងថា ពួកគាត់ទាំងអស់នោះ គឺត្រូវបានសាកសួររួចមកហើយ។ ហើយកាលនៅសំណុំរឿង០០២/១ គឺយើងសង្កត់ធ្ងន់តែលើអង្គហេតុនៅក្នុងសំណុំរឿងហ្នឹងទេ យើងមិនបាននិយាយមកដល់សំណុំរឿង០០២/២ នោះទេ។ ក៏ប៉ុន្តែនៅពេលដែល ពេលព្រះរាជអាជ្ញាសុំបញ្ជូនភស្តុតាងថ្មីនោះ គឺអង្គជំនុំជម្រះមិនកំណាញ់អីទេ ហើយយើងស្នើសុំឲ្យស្ដាប់សាក្សីតែប្រាំពីរ ប៉ុន្តែមានតែពីរទេ ដែលបានទទួលដោយអង្គជំនុំជម្រះ។ អ៊ីចឹងគឺថា នៅក្នុងសំណុំ -- នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់យើងមានទាំងអស់ លើកឡើងពីបញ្ហាទាំងអស់នេះ។ ដូច ប៉ែន យៀរណាន់ នេះ គឺនៅក្នុងសាលក្រមនោះគឺមានលើកឡើងពីសក្ខីកម្មរបស់គាត់ច្រើន យកមកធ្វើជាសម្អាងហេតុ។

[១០:៥៨:០៣]

គឺសក្ខីកម្មរបស់គាត់នោះ គឺប្រើនោះ វាច្រើនហួសហេតុទៅពេក ដែលមិនអាចឲ្យយើង មិន

អាចឆ្លើយតបទៅនឹងបានដោយសារយើងមិនមានលទ្ធភាពសួរចម្លើយគាត់។ ហើយអ៊ីចឹង ប៉ុន្តែបញ្ហាដែលអភិក្រមមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះនេះគឺនៅក្នុងសារណារបស់យើង គឺថាការចេញសាលក្រមផ្តន្ទាទោសទាក់ទងទៅនឹងឧក្រិដ្ឋកម្មសម្លាប់រង្គាលនៅភ្នំក្រោល ហើយយើង-- ដែលថា ខៀវ សំផន ត្រូវបានផ្តន្ទាទោសការសម្លាប់រង្គាល់នៅភ្នំក្រោល ហើយនៅក្នុងអង្គសេចក្តីនៃសាលក្រមនោះ មិនបានបង្ហាញថា ឧក្រិដ្ឋកម្មទាំងអស់នេះពិតជាបានកើតឡើងនោះទេ នេះហើយគឺជាភស្តុតាងសម្រាប់យើងក្នុងការបង្ហាញឲ្យឃើញថា មានបង្កើតលទ្ធផលជាមុនហើយ បានខំរកភស្តុតាងដើម្បីមកគាំទ្រទៅវិញ។ ហើយខ្ញុំសូមបញ្ចប់ត្រង់លើចំណុចមួយទៀត ខ្ញុំ ហើយក្រៅពីហ្នឹងខ្ញុំនឹងនិយាយពីចំណុចផ្សេងទៀត នៅពេលទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន ហើយនិងការចូលរួមចំណែករបស់ ខៀវ សំផន ជាដើម។ ខ្ញុំធ្លាប់ឃើញថា អង្គជំនុំជម្រះគឺតែងតែបំភ្លៃភស្តុតាង ហើយធ្វើទៅជាភស្តុតាងដាក់បន្ទុកទាំងអស់នៅក្នុងសំណុំរឿង០០១/២ហ្នឹងក៏គាត់បានប្រើទង់បដិវត្តន៍គឺ E3/25 ដែលប្រើនៅក្នុងសាលក្រម កថាខណ្ឌ១០៩ ហើយក៏ផ្នែកដដែលហ្នឹងក៏ប្រើនៅក្នុងសំណុំរឿង០០២/២ ដែរហើយអង្គជំនុំជម្រះបានប្រើទង់បដិវត្តន៍នេះ ដើម្បីពន្យល់ថា មានការជម្លៀសទីក្រុងទាក់ទងនឹងមនុស្សទាំងអស់គ្នាដោយគ្មានការលើកលែង។ ហើយនៅក្នុងសំណុំរឿង០០២/២ អង្គជំនុំជម្រះបានប្រើឯកសារដូចគ្នាដដែលនេះ ដើម្បីលើកឡើងអំពីវិធានការដាក់លាក់ប្រឆាំងនឹងជនជាតិវៀតណាម។ ហើយដើម្បីឲ្យច្បាស់លាស់តែម្តងនោះ ជូនចំពោះអស់លោក លោកស្រីចៅក្រមនៅទីនេះ គឺដកស្រង់ យកសម្រង់មួយនៅក្នុងកថាខណ្ឌ នៅក្នុងសំណុំរឿង ០០២/១ នៅក្នុងសម្រង់ដ៏វែងមួយនោះ មានការលើកឡើងថា កថាខណ្ឌ១០៨ គឺថា មាគ៌ានយោបាយហ្នឹងគឺការជម្លៀសជាប្រព័ន្ធ ប្រជាជនពីទីកដីរំដោះ ហើយដែលមិនពន្យល់ពីព័ត៌មានលម្អិតនោះទេ។

អ៊ីចឹងអង្គជំនុំជម្រះពន្យល់ថា ខ្មែរក្រហមគឺចង់ជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ ដោយសារមានជម្លោះជាមួយនឹងទាហានកងទ័ពលន់នល់ អ៊ីចឹងមិនឲ្យមានមនុស្សនៅហ្នឹងមូលដ្ឋានហ្នឹងទេ។ នៅក្នុងទង់បដិវត្តនេះដែរ មានយោងនៅកថាខណ្ឌ១០៨ និង១០៩ នៃសាលក្រមសំណុំរឿង០០២/១ មានលើកឡើងថា យើងបានជម្លៀសទាំងអស់គ្នាទោះបីជនជាតិវៀតណាម អាណិកជនវៀតណាម ចិន ទាហាន ឬនគរបាល យើងជម្លៀសប្រជាជនហ្នឹងដើម្បីប្រឆាំងនឹងខ្មាំង។ ហើយគេប្រើវគ្គនេះ ដើម្បីបញ្ជាក់ថា មានវិធានការដាក់លាក់នេះ ប្រឆាំងទៅនឹងជនជាតិវៀតណាម។ នេះជាភស្តុតាងបញ្ជាក់ថា អង្គជំនុំជម្រះបានបំភ្លៃ ឬក៏ប្រើប្រាស់ភស្តុតាងដោយផ្នែកៗមិនគ្រប់ជ្រុងជ្រោយ ដើម្បីប្រយោជន៍របស់ខ្លួន។

ខ្ញុំសូមបញ្ចប់ត្រឹមនេះ លោកប្រធាន។ ហើយខ្ញុំសូមថ្លែងអំណរគុណដែលលោកប្រធានអនុញ្ញាតបន្ថែមពេលឲ្យខ្ញុំ។

**ប្រធានអង្គជំនុំ៖**

ដោយសារយើងដល់ពេលវេលាត្រូវសម្រាកហើយ អ៊ីចឹង តុលាការកំពូល -- អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាក សម្រាកសិន ពីម៉ោងហ្នឹងរហូតទៅដល់ ម៉ោងដប់មួយកន្លះ សឹមយើងចូលវិញ។ អញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:០៣នាទី ដល់ម៉ោង ១១:៣០នាទី)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមបន្តសវនាការ។ ជាបន្តទៅនេះសូមអញ្ជើញ សហព្រះរាជអាជ្ញាធ្វើសារណា។

**លោកស្រី ជា លាង៖**

អរុណសួស្តី លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព និងអង្គសវនាការទាំងមូល។ ពេលនេះខ្ញុំ និងសហការីរបស់ខ្ញុំ នឹងលើកអំពីភាពត្រឹមត្រូវនៃនីតិវិធី នៃកិច្ចដំណើរការនីតិវិធី។

ដោយសារការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ខៀវ សំផន ដែលថាការជំនុំជម្រះមិនត្រឹមត្រូវ មាននៅក្នុងបណ្តឹងសាទុក្ខទាំងមូលរបស់គាត់ ដែលជនជាប់ចោទ ខៀវ សំផន បានលើកអំណះអំណាងតាមវិធីផ្សេងៗគ្នា។ ពិតហើយវាជាសិទ្ធិរបស់គាត់ក្នុងការជំទាស់ទៅនឹងរាល់ទិដ្ឋភាពដែលអាចពិនិត្យមើលឡើងវិញបាននៃការជំនុំជម្រះនេះដោយសន្មតថា ការជំទាស់ទាំងនេះបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញ។ ទោះជាយ៉ាងណា ដូចដែលសហការីរបស់ខ្ញុំនឹងពិភាក្សា និងខ្ញុំពិភាក្សាលម្អិតជាងនេះ ការជំទាស់របស់ ខៀវ សំផន មិនទទួលបានផលទេ ដោយហេតុថា ការលើកឡើងត្រឹមត្រូវនៃច្បាប់ និងភស្តុតាងច្រើនសន្ធឹកសន្ធាប់ដែលសាលក្រមបានផ្អែកលើ បញ្ជាក់យ៉ាងច្បាស់លាស់ថា ជាការជំទាស់ទាំងនោះមិនត្រឹមត្រូវទេ។ ទោះបីជាពេលខ្លះ មានការអះអាងដោយ ក្តីឈឺចាប់របស់គាត់ក្តី ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ខកខានមិនបានបង្ហាញអង្គជំនុំជម្រះ

សាលាដំបូងមានភាពលម្អៀងប្រឆាំងទៅនឹងគាត់នោះទេ មិនបានបង្ហាញថា អង្គជំនុំជម្រះបានរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ។ មិនបានបង្ហាញថា អង្គជំនុំជម្រះបានផ្តន្ទាទោសគាត់ចំពោះឧក្រិដ្ឋកម្មដែលគាត់មិនបានប្តឹងមកខ្លួន ឬថាបានផ្តន្ទាទោសគាត់ចំពោះឧក្រិដ្ឋកម្មដែលមិនត្រូវបានទទួលស្គាល់តាមច្បាប់នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង។ ហើយម្ចាស់បណ្តឹងសាទុក្ខ ជនជាប់ចោទ ខៀវ សំផន ក៏មិនបានបង្ហាញថា គាត់ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលមិនត្រូវបានបញ្ជាក់ឲ្យហួសពីវិមតិសង្ស័យនោះដែរ។

ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ក៏ខកខានមិនបានផ្តល់ការគាំទ្រ ដល់ការអះអាងដែលជាមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់គាត់ទាំងមូលដែរ គឺការអះអាងដែលថា គាត់មិនបានដឹងអ្វីទាំងអស់ មិនបានឃើញ និងមិនបានឮអ្វីសោះអំពីឧក្រិដ្ឋកម្មនានា ដែលគាត់ត្រូវបានផ្តន្ទាទោស។ ជាងនេះទៀត ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន មិនបានបង្ហាញថា អំពើរបស់គាត់មិនបានធ្វើឲ្យរូបគាត់ ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះដែរ។ ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ភស្តុតាងជាមូលដ្ឋាននៃការផ្តន្ទាទោសរបស់គាត់មានច្រើនសន្ធឹកសន្ធាប់ចម្រុះ និងមានលក្ខណៈចាប់បង្ខំ។ ភស្តុតាងទាំងនេះបង្កើតបានជារឿងក្តីមួយដែលបន្សល់នូវតែសេចក្តីសន្និដ្ឋានមួយប៉ុណ្ណោះ នោះគឺ ពិរុទ្ធភាពរបស់គាត់ចំពោះឧក្រិដ្ឋកម្ម។ ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន គឺជាបុគ្គលម្នាក់ក្នុងចំណោមមេដឹកនាំសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសាហាវ ឃោរឃៅ និងព្រៃផ្សៃប្រឆាំងនឹងប្រជាជនខ្លួនឯងផ្ទាល់ សម្រាប់គោលដៅរបស់ខ្លួន និងសម្រាប់គោលដៅមនោគមន៍វិជ្ជា និងនយោបាយរបស់បក្សគាត់ផ្ទាល់។

[១១:៣៤:០៧]

អំពើរបស់ម្ចាស់បណ្តឹងសាទុក្ខ ជនជាប់ចោទ ខៀវ សំផន បានចូលរួមចំណែកក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះតាមវិធីជាច្រើន ដែលសហព្រះរាជអាជ្ញានឹងពិភាក្សាជាលម្អិតនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាំងអស់នេះ។ ការចូលរួមចំណែករបស់គាត់ បានបន្សល់ទុកនូវទុក្ខវេទនា និងការឈឺចាប់សម្រាប់ប្រជាជនកម្ពុជា រួមទាំងដង្ហើមចុងក្រោយរបស់ពួកគេដែលមិនអាចពណ៌នាបាន។ សម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលជាមូលដ្ឋាននៃការផ្តន្ទាទោស និងការកំណត់ទោសចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺត្រឹមត្រូវ ល្អិតល្អន់ និងពេញលេញ។ ភាពសមហេតុសមផល

របស់វា ផ្អែកទៅលើការលើកឡើង និងការអនុវត្តច្បាប់យ៉ាងត្រឹមត្រូវដល់កម្រិតមួយដែលទទួលបានការគាំទ្រខ្ពស់ពីភស្តុតាងទាំងមូល។ ភាពជារួមនៃភស្តុតាងនេះបញ្ជាក់អំពីពិរុទ្ធភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខដូចដែលត្រូវបានផ្ដន្ទាទោស ផ្អែកលើការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម និងការជួយ និងការជំរុញរបស់គាត់ក្នុងឧក្រិដ្ឋកម្មទាំងនោះ។ យើងពឹងផ្អែកទៅលើចម្លើយតបជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញា ដែលរៀបរាប់ជាលម្អិតអំពីមូលហេតុ ដែលមូលដ្ឋានទាំង២៥៦ របស់ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន គួរត្រូវច្រានចោល។ សារណាផ្ទាល់មាត់របស់យើងនឹងផ្ដោតលើការឆ្លើយសំណួររបស់អង្គជំនុំជម្រះ និងការដោះស្រាយបញ្ហានានាដែលសហព្រះរាជអាជ្ញាយល់ឃើញថានឹងផ្ដល់អត្ថប្រយោជន៍មតិយោបល់បន្ថែម។ យ៉ាងណាក៏ដោយ មុនពេលខ្ញុំប្រគល់វេទិកានេះទៅឲ្យសហការីរបស់ខ្ញុំ គឺលោក ស្មីត ដើម្បីបន្តចម្លើយតបរបស់ពួកយើងទៅនឹងអំណះអំណាងស្ដីការជំនុំជម្រះដោយត្រឹមត្រូវរបស់ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ខ្ញុំសូមគូសបញ្ជាក់នូវកំហុសជាប្រព័ន្ធមួយចំនួន ដែលម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន លើកឡើងវិញនៅក្នុងបណ្ដឹងសាទុក្ខទាំងមូលរបស់គាត់។

[១១:៣៦:៣៩]

ក្រុមទី១នៃកំហុសទាំងនោះ ទាក់ទងទៅនឹងការបរាជ័យរបស់ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ក្នុងការបំពេញបទដ្ឋាននៃការពិនិត្យឡើងវិញសម្រាប់បណ្ដឹងសាទុក្ខ។ គាត់បានខកខានមិនបានធ្វើដូច្នេះដោយមូលហេតុជាច្រើន។ ទីមួយ គាត់ខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ឬអង្គហេតុ។ គាត់បរាជ័យដោយសារតែគាត់មិនបានព្យាយាមកំណត់អត្តសញ្ញាណកំហុស ឬមិនបានបង្ហាញ -- មិនមានលទ្ធភាពបង្ហាញឲ្យឃើញថា មានកំហុសណាមួយកើតឡើង។ ចំពោះកំហុសផ្នែកច្បាប់ ដែលបានចោទប្រកាន់វិញ ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ខកខានមិនបានបង្ហាញអំពីកំហុសណាមួយនៅក្នុងការលើកឡើង ឬការអនុវត្តច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។ ចំណែកឯកំហុសអង្គហេតុវិញ ម្ចាស់បណ្ដឹងសាទុក្ខ ជនជាប់ចោទ ខៀវ សំផន ខកខានមិនបានបង្ហាញថា ការសន្និដ្ឋានផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះ មិនសមហេតុសមផលនោះទេ។ គឺមិនបានបង្ហាញថា មិនមានអ្នកវិនិច្ឆ័យអង្គហេតុ មានហេតុផលណាម្នាក់អាចសម្រេចបែបនោះផ្អែកលើការវាយតម្លៃលើភស្តុតាងទាំងមូល។ គាត់ក៏មិនបានបង្ហាញអំពីមូលហេតុដែលអង្គជំនុំជម្រះនេះគួរអន្តរាគមន៍លើសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុទាំងនោះឡើយ។ ជាពិសេស នៅពេលដែលអង្គជំនុំជម្រះមាន

ឱកាសត្រួតពិនិត្យដោយផ្ទាល់លើសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ ដែលអនុញ្ញាតឲ្យពួកគាត់ស្ថិតក្នុងទីតាំងល្អ ក្នុងការវាយតម្លៃលើភាពជឿជាក់បាន និងភាពអាចទុកចិត្តបាននៃភស្តុតាងរបស់ពួកគេនៅក្នុងការថ្លឹងថ្លែង និងសម្រេចថា តើភស្តុតាងណាមួយដែលពួកគាត់ចង់បានជាង បន្ថែមលើឱកាសរបស់ពួកគាត់ក្នុងការវាយតម្លៃ និងថ្លឹងថ្លែងឯកសារភស្តុតាងជាច្រើនជាមួយនឹងសក្ខីកម្មនានានៅក្នុងតុលាការ។

[១១:៣៨:៥៨]

ទីពីរ ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ខកខានមិនបានបង្ហាញ បំពេញខាងផ្នែកទីពីរ នៃបទដ្ឋាននៃការពិនិត្យឡើងវិញ ដើម្បីធានាឲ្យមានកិច្ចអន្តរាគមន៍លើបណ្ដឹងសាទុក្ខ។ គាត់មិនបានបង្ហាញថាកំហុសអង្គច្បាប់ដែលបានចោទប្រកាន់ បានធ្វើឲ្យសាលក្រមទាំងមូល ឬដោយផ្នែកទៅជាមោឃៈឡើយ។ ហើយគាត់ក៏មិនបានបង្ហាញថា បើសិនជាគ្មានកំហុសដែលចោទប្រកាន់នោះទេ នឹងមានសេចក្ដីសម្រេចខុសពីនេះ។ ទាក់ទងនឹងកំហុសអង្គហេតុ គាត់ខកខានមិនបានបង្ហាញថា អង្គជំនុំជម្រះបានបង្កើតឲ្យមានភាពអយុត្តិធម៌ ឬបានបង្កើតវិមតិសង្ស័យចំពោះពិរុទ្ធភាពរបស់គាត់ ឬថាកំហុសដែលចោទប្រកាន់ទាំងនោះ គឺសំខាន់មិនអាចខ្វះបាន ឈានដល់ការផ្ដន្ទាទោស។ ម្ចាស់បណ្ដឹងសាទុក្ខ ខៀវ សំផន ក៏ខកខានមិនបានបង្ហាញថា កំហុសនីតិវិធីដូចបានចោទប្រកាន់នោះ បានបង្កើតឲ្យមានភាពអយុត្តិធម៌ធំធេងនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការនេះទេ ដែលជាលក្ខខណ្ឌតម្រូវចាំបាច់មួយសម្រាប់អន្តរាគមន៍តុលាការ ហើយគាត់ក៏មិនបានបង្ហាញឲ្យឃើញថា ការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនសមហេតុសមផលដូច្នេះ ដោយសារតែការធ្វើការសន្និដ្ឋានទាំងបង្ខំ ធ្វើឲ្យអង្គជំនុំជម្រះនេះខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានហ្មត់ចត់នោះដែរ។ គ្មានឧទាហរណ៍ណាមួយដែលម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីការកង្វះការថែទាំឆន្ទានុសិទ្ធិ ការប្រុងប្រយ័ត្នរបស់អង្គជំនុំជម្រះសាលាដំបូងទេ។ ពេលនេះ ខ្ញុំសូមបង្វែរទៅក្រុមកំហុសទីពីរវិញម្ដង ដែលកើតមានជាប្រព័ន្ធនៅក្នុងអំណះអំណាងរបស់ម្ចាស់បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ ខៀវ សំផន ទាំងមូល។ កំហុសទាំងនេះ គឺទាក់ទងទៅនឹងអភិក្រមមិនត្រឹមត្រូវជារួមនៃការវាយតម្លៃលើអង្គហេតុភស្តុតាងជាមូលដ្ឋាន និងសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ អភិក្រមមិនត្រឹមត្រូវនេះបានធ្វើឲ្យមានការចោទប្រកាន់អំពីកំហុសរបស់គាត់បរាជ័យ។ ទីមួយ ម្ចាស់បណ្ដឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន ពិនិត្យលើសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងជាចំណែកៗ និងដាច់ពីគ្នា ជាជាង

ការពិនិត្យមើលសម្អាងហេតុដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងសាលក្រមទាំងមូល ដែលជាលក្ខខណ្ឌតម្រូវនោះ។ គាត់កំណត់ទាំងមិនត្រឹមត្រូវលើការវិភាគរបស់ខ្លួនតែផ្នែកចោះៗនៃសាលក្រមនេះប៉ុណ្ណោះ។

[១១:៤២:១០]

ការពិនិត្យយ៉ាងត្រឹមត្រូវលើផ្នែកទាំងមូលនៃសាលក្រមធ្វើឲ្យយើងច្បាស់ថា សម្អាងហេតុគឺគ្រប់ជ្រុងជ្រោយនិងត្រឹមត្រូវ ដែលត្រូវចងចាំថា អង្គជំនុំជម្រះសាលាដំបូងមិនតម្រូវឲ្យបញ្ជាក់ការអះអាងគ្រប់ជំហាននៃការផ្តល់សម្អាងហេតុរបស់ខ្លួនឲ្យបានលម្អិតនោះឡើយ។ ហើយអង្គជំនុំជម្រះត្រូវបានសន្មតថា បានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវរាល់ភស្តុតាងទាំងអស់នៅចំពោះមុខខ្លួន។ ស្រដៀងគ្នានេះពេលធ្វើការវាយតម្លៃភស្តុតាងដែលគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ម្ចាស់បណ្តឹងសាទុក្ខប្រើអភិក្រមជាចំណែកៗមិនត្រឹមត្រូវដូចគ្នា ជាងការពិនិត្យលើភស្តុតាងទាំងមូលដូចបានតម្រូវដោយអង្គជំនុំជម្រះនេះ និងតុលាការអន្តរជាតិដទៃទៀត ដែលដោះស្រាយករណីមានលក្ខណៈស្រដៀងគ្នា។ កំហុសដ៏សំខាន់មួយទៀតនៅក្នុងការតវ៉ា នៅក្នុងរបស់ម្ចាស់បណ្តឹងសាទុក្ខ ខៀវ សំផន ចំពោះសាលក្រមគឺការអះអាងរបស់គាត់ដែលថា គ្រប់អង្គហេតុត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យក្នុងការបញ្ជាក់ពីធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ។ ដូចអង្គជំនុំជម្រះនេះបានបញ្ជាក់ច្បាស់ហើយថា មិនមែនគ្រប់អង្គហេតុនៅក្នុងរឿងក្តីមួយត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យនោះទេ ផ្ទុយទៅវិញគ្រប់អង្គហេតុដែលពាក់ព័ន្ធទាំងអស់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលដូចបានចោទប្រកាន់ទើបត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យ។ ចំពោះមូលហេតុនឹងផ្តល់អំណះអំណាងលម្អិតបន្ថែមទៀត ដោយសហការីរបស់ខ្ញុំ និងមូលហេតុបានដាក់នៅក្នុងចម្លើយរបស់យើងខ្ញុំ មូលដ្ឋាននៃបណ្តឹងសាទុក្ខទាំង២៥៦ គួរត្រូវបានបដិសេធ ហើយការកាត់ទោស និងការផ្តន្ទាទោសដែលម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន បានទទួលតាមរយៈអំពើប្រព្រឹត្តទាំងនេះ គួរតែត្រូវបានតម្កល់។

ខ្ញុំសូមប្រគល់វេទិកានេះទៅឲ្យសហការីរបស់ខ្ញុំគឺលោក ស្មីត ដើម្បីបន្តនូវសារណារបស់យើងខ្ញុំទាក់ទងនឹងការតវ៉ារបស់ម្ចាស់បណ្តឹងសាទុក្ខជនជាប់ចោទ ខៀវ សំផន អំពីភាពត្រឹមត្រូវ យុត្តិធម៌នៃសវនាការជំនុំជម្រះនេះ។ សូមអរគុណ។

[១១:៤៥:៤៥]

**លោក វីល្មៀម ស្មីត៖**

សូមគោរពឯកឧត្តមប្រធាន ឯកឧត្តម លោក លោកស្រី ចៅក្រម ឯកឧត្តម លោក លោកស្រី ភាគី។ នៅពេលដែលយើងពិនិត្យទៅលើមូលដ្ឋានទាំងអស់ដែលចោទប្រកាន់ថា គាត់ទទួលរងការប្រព្រឹត្តដោយមិនត្រឹមត្រូវយុត្តិធម៌ អង្គជំនុំជម្រះគឺមានការកំណត់តិចតួចបំផុត។ ដំណើរការគឺគាំទ្រថា អង្គជំនុំជម្រះគឺគោរព ហើយធានានូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់នៅក្នុងសាលក្រមដែលមាន ២២៥៩ទំព័រ ផ្អែកទៅលើឯកសារចំនួន១៤៤៧៦ រួមទាំងភស្តុតាងជទៃផងនោះ អង្គជំនុំជម្រះបានផ្តល់ព័ត៌មានលម្អិតអំពីដំណើរការនិងការផ្តល់សម្អាងហេតុដែលផ្តល់នូវភស្តុតាងលម្អិតនៃភាពយុត្តិធម៌របស់ការជំនុំជម្រះ។

ថ្ងៃនេះ ដោយមានមូលដ្ឋានបណ្តឹងសាទុក្ខចំនួន៣៥ ទាក់ទងទៅនឹងភាពយុត្តិធម៌របស់អង្គជំនុំជម្រះ ភាពយុត្តិធម៌នៃការជំនុំជម្រះ បទដ្ឋានគតិយុត្ត នីតិវិធីនៃការវាយតម្លៃ ខ្ញុំសូមផ្តោតទៅលើមូល-ដ្ឋានចម្បងរបស់អ្នកម្ចាស់បណ្តឹងសាទុក្ខដែលស្នើឲ្យធ្វើមោឃភាពដោយសារតែភាពអយុត្តិធម៌របស់អង្គជំនុំជម្រះ។ ទីមួយ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខគឺថា សាលក្រមគួរត្រូវធ្វើមោឃភាពដោយសារវាត្រូវបានចេញនៅថ្ងៃផ្សេងគ្នា ការណ៍គឺមិនមានអង្គសេចក្តីឡើយ ហើយក៏មិនមែនជាការរំលោភបំពានទៅលើវិធាននីតិវិធី ឬក៏ការអនុវត្តអន្តរជាតិឡើយ។ អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើការងារពីរ ទីមួយ គឺប្រកាសជាសាធារណៈអំពីសេចក្តីសង្ខេបនៃផ្នែកសម្រេចសេចក្តី និងការសម្រេចរបស់ខ្លួន ទីពីរ គឺការចេញសាលក្រមពេញលេញដែលមានសម្អាងហេតុ។

[១១:៤៧:០៩]

អង្គជំនុំជម្រះធ្វើដូច្នេះ វិធាន១០១ នៃវិធានផ្ទៃក្នុងនិង១០២ នៃវិធានផ្ទៃក្នុង នៅពេលដែលអានរួមគ្នា គឺមិនមានលក្ខខណ្ឌតម្រូវណាមួយដែលថា កិច្ចទាំងពីរហ្នឹងត្រូវធ្វើនៅថ្ងៃតែមួយគ្នានោះឡើយ។ នៅពេលដែលមានបញ្ហាទាក់ទងទៅនឹងសង្គតភាពនៃនីតិវិធីរបស់ អ.វ.ត.ក និងបទដ្ឋានអន្តរជាតិមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានអនុញ្ញាតឲ្យអង្គជំនុំជម្រះស្វែងរកគោលការណ៍ណែនាំនៅកម្រិតអន្តរជាតិ។ នៅកម្រិតអន្តរជាតិគឺមិនមានលក្ខខណ្ឌតម្រូវថា ត្រូវតែចេញនៅថ្ងៃតែមួយដូចគ្នានោះទេ។ ដូចដែលយើងបានឆ្លើយតបនៅក្នុងចម្លើយតបរបស់យើងទៅនឹងបណ្តឹងសាទុក្ខកន្លងមករបស់ម្ចាស់បណ្តឹងសាទុក្ខនៅលើបញ្ហា គឺនីតិវិធីនៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ, អឹម.អាយ.ស៊ី.ធី និង អេស.ធី.អិល គឺបានអនុញ្ញាតយ៉ាងច្បាស់លាស់ឲ្យមានការអនុវត្តបែបនេះ។

អង្គជំនុំជម្រះនៅតុលាការយូហ្គោស្លាវី តុលាការរវ៉ាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន គឺមានការប្រកាសសាលក្រមរួមជាមួយនឹងសេចក្តីសង្ខេបសាលក្រមមុនពេលដែលចេញសាលក្រមជាលាយលក្ខណ៍អក្សរ។ សំខាន់បំផុតម្ចាស់បណ្តឹងសាទុក្ខមិនទទួលរងព្យសនកម្មដោយសារនីតិវិធីនេះទេ។ ពេលវេលានៃការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់មិនចាប់ផ្តើមឡើយ រហូតដល់ពេលសាលក្រមដែលមានសម្អាងហេតុត្រូវបានចេញ។ ប៉ុន្តែនីតិវិធីនេះមិនបានធ្វើឲ្យខូចខាតដល់គាត់ទេ វាគឺផ្តល់ប្រយោជន៍ទៅគាត់វិញទេ ដោយសារតែវាផ្តល់ឲ្យពួកគាត់នូវពេលវេលាបន្ថែមបួនខែទៀត ដើម្បីចាប់ផ្តើមការត្រៀមរៀបចំបណ្តឹងសាទុក្ខ។ តាមរយៈទំហំនិងភាពស្មុគស្មាញនៃបណ្តឹងសាទុក្ខរបស់គាត់ គឺថា -- ឃើញថាពេលវេលាបួនខែហ្នឹងគាត់ប្រើប្រាស់ដោយអស់លទ្ធភាពល្អតែម្តង។

[១១:៥៩:០៥]

ឥឡូវនេះ យើងនិយាយពីបញ្ហាអយុត្តិធម៌លម្អៀង។ ទទ្ទឹករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ដោយសារតែមិនបានឆ្លើយតបទៅនឹងបញ្ហាលម្អៀងដែលលើកឡើងដោយពួកគាត់នៅក្នុងសាលក្រមនោះ គឺមិនមានការកំណត់ឡើយ ដោយសារហេតុផលបី ទីមួយ នៅកថាខណ្ឌ១១៤ និង១១៥ នៃសាលក្រម។ អង្គជំនុំជម្រះបានសម្រេចថា នីតិវិធីត្រឹមត្រូវដើម្បីលើកឡើងអំពីការចោទប្រកាន់ពីភាពលម្អៀងគឺត្រូវអនុលោមទៅតាមវិធាន៣៤ នៃវិធានផ្ទៃក្នុងដែលតម្រូវឲ្យម្ចាស់បណ្តឹងសាទុក្ខដាក់នូវភ្លាមៗនៅពេលដែលមានបញ្ហានេះកើតឡើង។ ទីពីរ ទោះក្នុងករណីណាក៏ដោយបញ្ហាខ្លះដែលម្ចាស់បណ្តឹងសាទុក្ខបានលើកឡើង គឺត្រូវបានបដិសេធរួចមកហើយ ដោយក្រុមប្រឹក្សាជំនុំជម្រះពិសេសនៅក្នុងសំណើសុំប្តឹងជិតចិត្តចៅក្រមអង្គជំនុំជម្រះតាមវិធាន៣៤ របស់គាត់កន្លងមក ហើយទីបី ចំពោះអង្គសេចក្តីនៃនីតិវិធីនៃការប្តឹងរបស់ពួកគេ គឺអង្គជំនុំជម្រះបានយោងពួកគេទៅលើសម្អាងហេតុដែលបានផ្តល់នៅពេលដែលមានការរិះគន់ទៅលើកិច្ចតាមនីតិវិធី។ជាលទ្ធផលម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់អំពីកំហុសឆ្គងរបស់អង្គជំនុំជម្រះឡើយ។ ប្រសិនបើម្ចាស់បណ្តឹងសាទុក្ខចង់លើកបញ្ហាបន្ថែមទៀតអំពីភាពលម្អៀងរបស់អង្គជំនុំជម្រះ ពួកគាត់គួរតែធ្វើនៅពេលដែលបញ្ហាហ្នឹងកើតឡើងភ្លាមៗដែលអនុលោមទៅតាមវិធាន៣៤ នៃវិធានផ្ទៃក្នុង។ ចំពោះធាតុផ្សំនៃមូលដ្ឋានដែលថាអង្គជំនុំជម្រះសាលាដំបូងមិនមានភាពអព្យាក្រឹតនោះ គឺថានៅបញ្ហានេះត្រូវបានដោះស្រាយជំនុំជម្រះរួចហើយដោយក្រុមប្រឹក្សាជំនុំជម្រះ នៅថ្ងៃ៣០ មករា ២០១៥ ដែលច្រានចោលសំណើសុំប្តឹងជិតចិត្តក្រោយពីមានការវិភាគយ៉ាងច្រើន ហើយបានសម្រេចថាមិនមានភាពលម្អៀងជាក់លាក់ណាមួយ ឬមាន

ភាពលម្អៀងណាអាចកើតមានឡើង។ ចំពោះភាពអាចទទួលយកបានគឺមិនមានសិទ្ធិក្នុងការប្តឹងចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសឡើយ ដែលអនុលោមទៅតាមវិធាន៣៤(៨) នៃវិធានផ្ទៃក្នុង។ ហើយចំពោះការប្តឹងសាទុក្ខទៅនឹងពិរុទ្ធភាព និងការផ្តន្ទាទោសតាមវិធាន១១៤ហ្នឹង គឺផ្អែកទៅលើកំហុសឆ្គងអង្គច្បាប់ ឬអង្គហេតុ ហើយមូលហេតុនេះមិនអាចទទួលយកបានទេ។ ទោះជាក្នុងករណីណាក៏ដោយ ចំពោះអង្គសេចក្តី ម្ចាស់បណ្តឹងសាទុក្ខមិនបានកំណត់អំពីការមិនមានភាពអព្យាក្រឹតរបស់អង្គជំនុំជម្រះឡើយ។

[១១:៥១:៤២]

ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខគឺថា វាមិនអាចនោះឡើយដែលមិនគិតអំពីការសម្រេចអង្គហេតុនិងអង្គច្បាប់ដែលធ្វើឡើងនៅក្នុងសំណុំរឿង០០២/០១ ដែលធ្វើឲ្យមានឥទ្ធិពលទៅដល់០០២/០២។ ការពិតទៅគឺម្ចាស់បណ្តឹងសាទុក្ខបានប្រើប្រាស់នូវបទដ្ឋានវិនិច្ឆ័យខុស ដើម្បីកំណត់អំពីភាពអយុត្តិធម៌ ឬក៏ភាពលម្អៀង។ គាត់មិនបានទទួលស្គាល់ឲ្យបានគ្រប់គ្រាន់នូវសច្ចធារណ៍នៃភាពអព្យាក្រឹតរបស់ចៅក្រមដែលមានលក្ខណៈខ្ពស់នោះឡើយ ហើយវិធានការដែលធ្វើដោយអង្គជំនុំជម្រះ ដើម្បីធានាអំពីភាពអព្យាក្រឹតរបស់ខ្លួន។ ដូច្នេះថាតើអ្វីជាវិធានការទាំងអស់នេះ។ ទីមួយ គឺអង្គជំនុំជម្រះបានទាញយកតែភស្តុតាងសំខាន់ៗពីសំណុំរឿងចូលមកក្នុងសំណុំរឿង០០២ ប៉ុណ្ណោះ។ នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចៅក្រមបានទទួលស្គាល់ថា នេះគឺជានីតិវិធីសមស្រប ដើម្បីកុំឲ្យមានការជាន់គ្នានូវភស្តុតាងពាក់ព័ន្ធ ហើយកុំឲ្យមានការប្រើប្រាស់ភស្តុតាងដូចគ្នាដោយភាគីនានា។ ទីពីរ អង្គជំនុំជម្រះបានសម្រេចថា ភស្តុតាងដែលនាំយកមកហ្នឹង គឺត្រូវវាយតម្លៃឡើងវិញនៅគ្រប់ភស្តុតាងទាំងអស់ដែលទទួលទៅក្នុងសំណុំរឿង០០២/០២ លើកលែងតែថា ពួកគេអាចឈានទៅដល់ការសន្និដ្ឋានផ្សេង។ ទីបី គឺថាការនាំយកនូវការសម្រេចអង្គហេតុ អង្គច្បាប់ រួមទាំងការសម្រេចទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ម្ចាស់បណ្តឹងសាទុក្ខពីសំណុំរឿងពីឧក្រិដ្ឋកម្មសំណុំរឿង០០២/០១ ទៅសំណុំរឿង០០២/០២ ហ្នឹង ក៏មិនមានការនាំចូលដែរ -- មិនមានការទាញចូលដែរ។ បញ្ហាកើតឡើងនៅពេលដែលមានការសម្រេចនៅក្រុមប្រឹក្សាជំនុំជម្រះដែលទាញយកនូវនេះ។ ឧក្រិដ្ឋកម្មជាច្រើនគឺបានកើតឡើង ហើយវាមានជនរងគ្រោះ វាមានទីកន្លែង ហើយកាលៈទេសៈជាច្រើន។ ហើយគោលនយោបាយដែលបានប្រើប្រាស់ឡើង គឺវាមានលក្ខណៈខុសគ្នាដែរ។ ប្រហែលគ្នានេះ លក្ខណៈនៃការចូលរួមនៅក្នុងគោលនយោបាយនេះ គឺវាមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រហាក់ប្រហែលគ្នាទៅលើការសម្រេចខុសៗគ្នា។

ឧទាហរណ៍ ទឡ្ហីករណ៍ដែលថា ប្រសិនបើអង្គជំនុំជម្រះធ្វើអំពីគោលនយោបាយផ្សេងៗគ្នានៅក្នុងសំណុំរឿង០០២/០១ គឺថា ពួកគេនឹងសម្រេចដដែលដូចគ្នាចំពោះសំណុំរឿង០០២/០២។ ទីមួយ គឺថាទោះបីជាអង្គជំនុំជម្រះយល់ឃើញអំពីការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿង០០២/០១ គឺមិនធ្វើឲ្យមានការខុសគ្នាណាឡើយ ទោះបីថាមាន ឬក៏មិនមានគោលនយោបាយទាំងអស់នេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។

[១១:៥៤:៥៥]

ចំពោះលក្ខណៈរបស់គោលនយោបាយ គឺការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍ គឺជាកម្មវត្ថុនៃសំណុំរឿង០០២/០២ គឺនៅក្នុងឯកសារ E313។ ចំពោះការជំនុំជម្រះ គឺនៅក្នុងសំណុំរឿងប្រហែលគ្នានេះចំពោះការចោទប្រកាន់អំពីភាពលម្អៀង គឺម្ចាស់បណ្តឹងសាទុក្ខអាចបង្ហាញផងដែរ ដែលផ្អែកទៅលើអង្គហេតុ។ ការកំណត់ប្រភេទនៃបទល្មើសគឺជាឧទាហរណ៍ដ៏ល្អមួយ។ ទឡ្ហីករណ៍បានបង្ហាញថា ឥតមានលទ្ធភាពដែលថាអង្គជំនុំជម្រះអាចកំណត់ដោយស្របច្បាប់ទៅលើឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ក៏ដូចជាការធ្វើឧក្រិដ្ឋកម្មផ្សេងៗ ឬការសម្លាប់ដែលកើតឡើងដោយមានការនេះឡើយ។ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខមិនបានទទួលស្គាល់ដោយត្រឹមត្រូវ។

**អ្នកបកប្រែ៖**

ឯកឧត្តមប្រធានស្នើឲ្យសហព្រះរាជអាជ្ញាគាត់ធ្វើការអានឲ្យបានយឺតៗបន្តិច។ សូមអរគុណ។

**លោក វីល្លៀម ស្មីត៖**

នៅពេលដែលមានការជូនដំណឹងអំពីការកំណត់ប្រភេទបទល្មើសនៃបទចោទសម្លាប់រង្គាលនៅក្នុងសំណុំរឿង០០២/០២ ការជូនដំណឹងបែបនេះគឺត្រឹមត្រូវដូចគ្នាទៅនឹងសំណុំរឿង០០២/០១ មុនពេលដែលមានការកំណត់ប្រភេទបទល្មើសដូចគ្នា នៅក្នុងកាលៈទេសៈដូចគ្នាដែលធ្វើឡើងនៅអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០២។ នៅពេលដែលយើងគិតអំពីធាតុផ្សំអត្តនោម័តិដែលរួមបញ្ចូលនៅក្នុងធាតុផ្សំនោះផងដែរ។ ម្ចាស់បណ្តឹងសាទុក្ខមិនអាចប្តឹងដែលថាខ្លួនមិនមានឱកាសនៅក្នុងការដោះស្រាយលើបញ្ហានេះឡើយ ព្រោះពួកគេមិនបានទទួលយកនូវឱកាស ដែលសាលាដំបូងបានផ្តល់នៅក្នុងសំណុំរឿង០០២/០២ នៅពេលដែលពួកគេអាចលើកឡើងនូវបញ្ហាណាមួយក៏បានដែលកើតឡើងនៅក្នុងសំណុំរឿង០០២/០១។

**ចៅក្រម ម៉ូរីន ហាខឹង ក្លាក៖**

សុំទោស ខ្ញុំសុំកាត់បន្តិច។ តើវាជាករណីរបស់ព្រះរាជអាជ្ញា ឬក៏សាលក្រមដែលចេញ ឬមួយក៏ភាគីត្រូវធ្វើឡើងដែលថា មានការជូនដំណឹងឲ្យបានត្រឹមត្រូវអំពីលទ្ធភាពនៃការកំណត់ប្រភេទនៃបទល្មើស។ ខ្ញុំគ្រាន់តែចង់ដឹង ហើយចង់ឲ្យលោកពិនិត្យឲ្យបានច្បាស់ ថាតើមួយខែហ្នឹងសំដៅទៅលើអ្វី? ការឈានទៅដល់ ការសម្រេចជាឯកច្ឆន្ទ ឬក៏យ៉ាងម៉េច? វាមិនមានការណែនាំច្បាស់លាស់ណាមួយទាក់ទងទៅនឹងការជូនដំណឹងពីសាលាដំបូងដែលថាចំណុចជាក់លាក់ណាមួយនៃបណ្ដឹងសាទុក្ខដែលពួកគេពិចារណាហ្នឹងអាចមានបញ្ហាអំពីលទ្ធភាពនៃការកំណត់ប្រភេទនៃបទល្មើស។ ខ្ញុំចង់ឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់ឲ្យច្បាស់លើចំណុចនេះ។

[១១:៥៨:៥០]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមអភ័យទោសដោយសារខ្ញុំមិនបានបើកមីក្រូហ្វូន។ ក្នុងនាមជាអ្នកអនុវត្តវិជ្ជាជីវៈនៅក្នុងតុលាការនេះ នៅពេលដែលសាលាក្រមសំណុំរឿង០០២/០១ បានចេញ គឺជាការត្រឹមត្រូវដែលភាគីទាំងអស់ រួមទាំងម្ចាស់បណ្ដឹងសាទុក្ខផង ហោចណាស់ក៏ត្រូវមានការពិនិត្យដោយសមហេតុផលទៅលើសាលក្រមថាតើវាមានផលប៉ះពាល់ ឬក៏មានឥទ្ធិពលបែបណាទៅដល់សំណុំរឿង០០២/០២។ ហើយសាលាដំបូងក៏បានបញ្ជាក់ច្បាស់ដែរដោយមានការទុកឲ្យមានការសម្រេចចិត្តបន្ថែមទៀតដែលថា ដើម្បីឲ្យភាគីអាចលើកបញ្ហាណាមួយដែលកើតចេញពីសាលាក្រមនោះ។ អង្គជំនុំជម្រះបានដឹងអំពីបញ្ហាដែលថាភាគីអាចពិនិត្យទៅលើសាលក្រម ហើយជាការសមស្របដែលថាទទួលយកនូវទស្សនៈ ឬក៏គំនិតបែបនេះ។

ប៉ុន្តែទោះក្នុងករណីណាក៏ដោយ ម្ចាស់បណ្ដឹងសាទុក្ខមិនចាប់យកឱកាសនោះទេ នៅពេលដែលពួកគេមានឱកាសបែបនេះ ប្រាកដជាមានការកំណត់កម្រិតណាមួយទាក់ទងទៅនឹងបញ្ហាដែលពួកគេត្រូវប្ដឹងនៅពេលក្រោយ មិនមានព្យសនកម្មណាមួយចំពោះម្ចាស់បណ្ដឹងសាទុក្ខឡើយនៅពេលដែលគេប្ដឹងសាទុក្ខទៅលើសំណុំរឿង ០២/០១នោះ។ ហើយភាគីទាំងអស់គឺពឹងផ្អែកទៅលើការងារទាំងអស់នេះទាក់ទងទៅនឹងធាតុផ្សំសត្យានុម័តសម្រាប់ការសម្លាប់រង្គាល ហើយនៅក្នុងដំណាក់កាលបែបនេះ គឺមេធាវីការពារក្ដីមិនមានព្យសនកម្មឡើយនៅក្នុងពេលដែលគេជំទាស់ទៅលើរឿងក្ដីទាំងអស់នោះ។

[១២:០៣:៥៣]

បន្ថែមពីលើនេះទៀត ការសម្លាប់រង្គាលដែលមានចេតនាច្បាស់លាស់ ដូចដែលមានការណែនាំ

ដោយសាលាកំពូលគឺថា ម្ចាស់បណ្តឹងសាទុក្ខមិនទទួលនូវព្យសនកម្មណាមួយឡើយ។ ឧទាហរណ៍បន្ថែមទៀតដែលនិយាយអំពីការមិនគាំទ្រ ការចោទប្រកាន់ គឺតាមរយៈសារណារបស់គាត់ ប៉ុន្តែខ្ញុំនឹងលើកបញ្ហាសំខាន់ដែលគាត់បានលើកឡើងទាកទងទៅនឹងការប្រព្រឹត្តទៅលើភស្តុតាងដោះបន្ទុក។ ម្ចាស់បណ្តឹងសាទុក្ខបានលើកទឡ្ហីករណ៍ដោយខុសឆ្គងថា អង្គជំនុំជម្រះលុបចោល ឬក៏ចាត់ទុកភស្តុតាងដោះបន្ទុកដោយមិនត្រឹមត្រូវធៀបទៅនឹងភស្តុតាងដាក់បន្ទុក។ ទីមួយ គឺជាចំណុចចាប់ផ្តើមនៅក្នុងសាលក្រមអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការវាយតម្លៃទៅលើភស្តុតាងគឺថា អង្គជំនុំជម្រះមានកាតព្វកិច្ចកំណត់អត្តសញ្ញាណ និងពិចារណាទៅលើភស្តុតាងទាំងដោះ និងដាក់បន្ទុក។ នៅពេលដែលពិនិត្យទៅលើសាលក្រមទាំងមូលគឺច្បាស់ណាស់ថា អង្គជំនុំជម្រះបានវាយតម្លៃទៅលើភស្តុតាងពាក់ព័ន្ធទាំងអស់រួមទាំងទឡ្ហីករណ៍ទាំងអស់ ទាំងដោះ និងដាក់បន្ទុក ដើម្បីឈានទៅដល់ការសន្និដ្ឋានបែបនេះ។ អ្នកខ្លះអាចសង្កេតឃើញសាលក្រមហ្នឹង ហើយចោទសួរថា ហេតុអីបានវាវែងម្ល៉េះ? សាលក្រមហ្នឹងច្បាស់ណាស់ ថានៅពេលដែលពិនិត្យឲ្យបានលម្អិត គឺជាការថ្លឹងថ្លែងរវាងភស្តុតាងនិងបញ្ហាដោយសារតែមានការថ្លឹងថ្លែងច្រើនអ៊ីចឹងហើយ ទើបមានទំហំធំ។ ប៉ុន្តែទឡ្ហីករណ៍របស់ម្ចាស់បណ្តឹង សាទុក្ខគឺថា អង្គជំនុំជម្រះលម្អៀងប្រឆាំងគាត់ទៅវិញ ដោយធ្វើឲ្យដោយឲ្យព្រះរាជអាជ្ញាដាក់បង្ហាញនូវឯកសារដែលទើបបានថ្មីៗពីសំណុំរឿង ០៣, ០៤ ដោយផ្អែកលើមូលហេតុថា ឯកសារពី០៣,០៤ ហ្នឹង មានភស្តុតាងដាក់បន្ទុក។ គឺខុសទាំងស្រុង ការចោទប្រកាន់បែបនេះ។ អង្គជំនុំជម្រះគឺទទួលស្គាល់តួនាទីរបស់ព្រះរាជអាជ្ញាក្នុងការបំពេញតួនាទីរបស់ខ្លួន។ តួនាទីនេះគឺ បញ្ជាក់ដោយអង្គជំនុំជម្រះ គឺការសម្រេចថា ព្រះរាជអាជ្ញាមានកាតព្វកិច្ចដាក់បង្ហាញជូនអង្គជំនុំជម្រះនិងភាគីនូវសម្ភារៈ ឬក៏ឯកសារណាមួយដែលអាចបង្ហាញអំពីភាពត្រឹមត្រូវ ឬក៏សម្រាលទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ ឬក៏ប៉ះពាល់ទៅដល់ភាពអាចជឿទុកចិត្តបាននៃភស្តុតាង។

តួនាទីបែបនេះគឺវាស្របទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្នុងការស្វែងរកការពិត។ ការពិតទៅព្រះរាជអាជ្ញាក៏ព្យាយាមទទួលយកនូវឯកសារជាច្រើនតាមវិធាន ៨៧(៣) និង ៨៧(៤) ដើម្បីជួយតុលាការក្នុងការស្វែងរកការពិត។ គឺការបំពេញនេះ គឺវាមិនផ្អែកទៅលើកាតព្វកិច្ចតាមវិធាន៥៣(៤) របស់ខ្លួនឡើយ។ តាមពិតទៅ គឺវាជាការកម្រដែលជនជាប់ចោទជំទាស់ទៅនឹងការបង្ហាញភស្តុតាងដែលច្បាស់ណាស់ថា ពាក់ព័ន្ធទៅនឹងរឿងក្តីរបស់គាត់។

[១២:០៣:៤៦]

បន្ថែមពីលើនេះទៀត មូលដ្ឋានដែលលើកឡើងអំពីបញ្ហាជាសារវន្តនៃវិសាលភាពធំទូលាយនៃភស្តុតាងដោះបន្ទុកក្នុងសំណុំរឿងដែលមានទំហំដ៏ធំធេងបែបនេះ ព្រមទាំងកាតព្វកិច្ចនៃការដកបង្ហាញឯកសារដ៏ធំបែបនេះ។ ចំពោះចម្លើយរបស់សាក្សីជាពិសេសចម្លើយដែលមាន ដែលធ្វើឡើង ដែលមានរយៈពេលយូរណាស់មកហើយ ប្រាកដណាស់ថា គឺវាមានភាពខុសគ្នាទៅលើការចងចាំរបស់សាក្សី ការផ្តល់ព័ត៌មានលម្អិតអំពីហេតុការណ៍ឧក្រិដ្ឋកម្ម ឬក៏ការអនុវត្តគោលនយោបាយ ព្រមទាំងរចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនង គឺថា សាក្សីមានឱកាស និងមានសមត្ថភាពនៅក្នុងការកត់សម្គាល់ រំឭក ឬក៏អនុវត្តណាមួយ។ ក៏ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខបែរជាទទួលស្គាល់ថា ឯកសារទាំងអស់នេះ គឺជាឯកសារ -- ទោះបីជាម្ចាស់បណ្តឹងសាទុក្ខ ទទួលស្គាល់ថា ឯកសារនេះជាឯកសារដោះបន្ទុក ឬក៏ដាក់បន្ទុកក៏ដោយ ប៉ុន្តែវាពិបាកណាស់សម្រាប់គាត់ក្នុងការទទួលស្គាល់នៅក្នុងសារណារបស់គាត់ ដូចថាការដាក់ភស្តុតាងថ្មីហ្នឹង គឺជាភស្តុតាងដាក់បន្ទុកច្រើនជាងដោះបន្ទុក។

ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯង គឺត្រូវវាយតម្លៃថាតើគាត់គិតថាអ្វីដែលជាដាក់បន្ទុក ឬក៏អ្វីដែលជួយសម្រាលទៅលើគាត់។ ដូច្នេះ ជាជាងការបង្ហាញឯកសារណាមួយនោះ វាគឺជាការការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ទៅវិញទេ។ ដូច្នេះ ការទទួលបាននូវព័ត៌មានផ្សេងៗហ្នឹងគឺជួយទៅដល់ពួកគាត់ក្នុងការការពាររឿងក្តីរបស់គាត់ទៅវិញនោះទេ។

[១២:០៥:៣២]

ឯកឧត្តម លោក លោកស្រីចៅក្រម ខ្ញុំសូមលើកបន្តទៅលើបញ្ហាគឺកំហុសឆ្គងដែលម្ចាស់បណ្តឹងសាទុក្ខនិយាយអំពីការរំលោភទៅលើគោលការណ៍នីត្យានុកូលភាព គាត់បាននិយាយថា នៅពេលដែលពិនិត្យទៅលើឧក្រិដ្ឋកម្មដែលគាត់ទទួលខុសត្រូវ សុំទោសគឺ ការរំលោភបំពានរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើគោលការណ៍នីត្យានុកូលភាពនោះ គឺម្ចាស់បណ្តឹងសាទុក្ខបកស្រាយដោយខុសឆ្គង គឺវាមិនមានការពន្លើសដែលថា ដោយសារតែគាត់មិនទទួលបានសៀវភៅអំពីឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ គាត់គួរតែបានលើកលែងទោសនោះគឺជាការមិនត្រឹមត្រូវនោះទេ។ មានការលើកលែងតិចតួច គឺថាម្ចាស់បណ្តឹងសាទុក្ខគាត់មិនអាចបដិសេធថា គាត់មិនបានដឹងឮអំពីច្បាប់ទំនៀមទំលាប់អន្តរជាតិនៅឆ្នាំ១៩៧៥ ឡើយ។ តាមរយៈសារណារបស់គាត់ គាត់គ្រាន់តែនិយាយថា គាត់មិនអាចដឹងថាមានច្បាប់ និងមិនអាចប្រមើលមើលដឹងថាជាបទល្មើសការអះអាង។ បែបនេះគឺមិនត្រឹមត្រូវឡើយនៅពេលដែលយើងធ្វើការវិនិច្ឆ័យដោយសារធាតុផ្សំ ឬក៏ដោយសារហេតុផលជាច្រើន។ ទីមួយ គឺភាពអាចដឹងថាមាន

ច្បាប់ គឺថា នេះគឺជាឧក្រិដ្ឋកម្មដែលគាត់អាចដឹងច្បាស់ ហើយគាត់អាចមើលជាភាសាដែលគាត់ដឹង។ ប៉ុន្តែគាត់ធ្វើជាមិនដឹង។ ហើយតុលាការនៅអង្គជំនុំជម្រះ និងតុលាការជាច្រើនដូចជាតុលាការអង្គជំនុំជម្រះ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ឬក៏តុលាការ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ ជាដើមបាន គាំទ្រថា ឧក្រិដ្ឋកម្មទាំងអស់នេះ គឺមាននៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិ ហើយជនជាប់ចោទអាចដឹង ហើយកម្ពុជាគឺជាហត្ថលេខី នៃអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ប្រាកដណាស់ពួកគាត់ដឹង។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីការប្រមើលមើលដឹង ពួកគាត់អះអាងថា ពួកគាត់មិនបានដឹងអំពី មិនអាចប្រមើលមើលដឹងថាជាបទល្មើស មិនអាចប្រមើលមើលដឹងថា មានការសម្លាប់រង្គាល ឬក៏មានស្ថានភាពជាច្រើនជាដើម។--

**អ្នកបកប្រែ៖**

ឯកឧត្តមប្រធាន ស្នើសុំឲ្យលោកមេធាវី គាត់អាចឲ្យបានយឺតៗបន្តិច។ សូមអរគុណ។

**លោក វីល្លៀម ស្មឺត៖**

--គឺថាអាចមានការឆ្លើយតបទៅនឹងការទទួលខុសត្រូវ។

បាទសូមអរគុណឯកឧត្តមប្រធាន ខ្ញុំនឹងអានឲ្យបានយឺតៗ។

លោក លោកស្រីចៅក្រម ខ្ញុំសុំលើកឡើងអំពីនិយមន័យនៃឧក្រិដ្ឋកម្ម ដែលម្ចាស់បណ្តឹងហាក់បីដូចជាយល់ច្រឡំ គឺថាយើងមិនមានការធានា ថាមិនមានការផ្តន្ទាទោសនោះទេ នៅពេលដែលការទទួលខុសត្រូវខាងព្រហ្មទណ្ឌគឺថា អាចប្រមើលមើលជាមុនបាន។ នៅក្នុងឧក្រិដ្ឋកម្មឃោរឃៅព្រៃផ្សៃប្រឆាំងមនុស្សជាតិ យើងខ្ញុំសុំលើកឡើងថា ចម្លើយគឺថា ត្រូវតែមានភាពច្បាស់លាស់។

លោក លោកស្រីចៅក្រម ប្រហែលជាយើងខ្ញុំអស់ពេលវេលាហើយ តើខ្ញុំសុំអនុញ្ញាតសុំ ៥ ទៅ ១០នាទីបានទេ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់ម្ចាស់បណ្តឹងទាក់ទងទៅនឹង ដែលថាមិនមានការប្រព្រឹត្តត្រឹមត្រូវនោះ។

**ប្រធានអង្គជំនុំ៖**

សុំឲ្យបន្ថែមត្រឹម ៥នាទីបានហើយ។

**លោក វីល្លៀម ស្មឺត៖**

សុំអរគុណលោកប្រធាន។ ម្ចាស់បណ្តឹងឧទ្ធរណ៍ថាគាត់ត្រូវបានប្រព្រឹត្តមិនបានត្រឹមត្រូវនោះទេ នៅពេលដែលអង្គជំនុំជម្រះពាក់ព័ន្ធនឹងភស្តុតាងដាក់បន្ទុក។ ឧទាហរណ៍មួយចំនួនដែលពាក់ព័ន្ធទៅនឹង

ទស្សនាវដ្ដីទង់បដិវត្តដែលលើកឡើងនៅក្នុងសំណុំរឿង០០២/០២នេះ គឺថាមានការដកស្រង់ពេញលេញ ដែលយើងបានយកទៅប្រើប្រាស់នៅក្នុងសំណុំរឿង០០២/០១ ដែលវាមានព័ត៌មានពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម។ ចំណុចនេះមិនបានបង្ហាញអំពីកង្វះនូវភាពអព្យាក្រឹតពីសំណាក់អង្គជំនុំជម្រះសាលាដំបូងនោះទេ ប៉ុន្តែវាបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងគឺថា នៅក្នុងសំណុំរឿង០០២/០១ ហើយព័ត៌មានដែលពាក់ព័ន្ធពីសំណុំរឿងគឺ វាពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម ដែលបានលើកឡើងនៅក្នុងសំណុំរឿង០០២/០២។

[១២:១១:៣០]

ទាក់ទងនឹងឧទាហរណ៍មួយចំនួន ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍លើកឡើងថា ជាពិសេសពាក់ព័ន្ធទៅនឹងសុន្ទរកថារបស់ ខៀវ សំផន ដែលបានថ្លែង គឺបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ហើយក៏លើកឡើងម្ដងទៀតជាសង្ខេបនៅក្នុងសំណុំរឿង០០២/០២ ហើយមេធាវីការពារក្ដីរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ថា ចៅក្រមទាំងអស់នៅអង្គជំនុំជម្រះសាលាដំបូង មានកំហុសពាក់ព័ន្ធទៅនឹងភាពអមនុស្សធម៌នេះ។ ក៏ប៉ុន្តែបណ្ដឹងឧទ្ធរណ៍នេះមិនបានបំពេញបទដ្ឋានទាំងអស់នេះទេ ហើយវានាំឱ្យមានការមិនអាចស្វែងរកយុត្តិធម៌បានទៀតផង។ យើងខ្ញុំសុំបញ្ជាក់ថា ចំណុចនេះគឺមិនត្រឹមត្រូវទេ ទាកក់ទងទៅនឹងការចោទប្រកាន់របស់ម្ចាស់បណ្ដឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម។ ពួកគាត់បានលើកឡើងក្នុងនោះគឺ មានចម្លើយពីឈ្មោះផេង វាមិនមានភាពច្បាស់លាស់ពាក់ព័ន្ធទៅនឹងព័ត៌មានរបស់ពួកគាត់នៅក្នុងបណ្ដឹងសាទុក្ខថាតើ ផេងនេះ តើនៅក្នុងដំណាក់កាលនោះត្រូវបានឃុំឃាំងយូរនៅមន្ទីរស-២១ ឬក៏យ៉ាងណានោះទេ ជាពិសេសមុនពេលគាត់ ត្រូវបានគេបញ្ជូនមកដល់មន្ទីរស-២១។ ហើយក្នុងរឿងនោះ ក៏មិនបានកោះហៅសាក្សីម្ចាស់បណ្ដឹងសាទុក្ខ គឺនៅក្នុងសំណុំរឿង០០២/០១ គឺអង្គជំនុំជម្រះបានស្ដាប់ព័ត៌មានពាក់ព័ន្ធ ទៅនឹងសំណុំរឿង០០២ ប៉ុន្តែសាក្សីទាំងអស់នេះ គឺថាមិនបានផ្ដល់ចម្លើយទៅតាមជំនាញរបស់គេនោះទេ ហើយក៏មិនមានឱកាសសាកសួរសាក្សីទាំងនោះនៅក្នុងសំណុំរឿង០០២/០២ នេះដែរ ហើយក៏ដូចជាសំណុំរឿង០០២/០១ ដែលយើងមានបំណងចង់ឱ្យសាក្សីទាំងអស់នោះត្រឡប់មកចូលកាន់ក្នុងសវនាការលើកទី២វិញ។

[១២:១៣:៥៩]

តាមពិតអង្គជំនុំជម្រះសាលាដំបូង គឺថាខិតខំប្រឹងប្រែងមែនទែន ចង់ឱ្យសាក្សី ក៏ដូចជាជំនាញ

ចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ តែនៅពេលវេលានោះ គឺពេលវេលាមិនផ្ដល់ឱកាសឲ្យទេ។ នេះមិនមែនជាកំហុសរបស់សាលាដំបូងក្នុងការប្រើប្រាស់សក្ខីកម្មរបស់អ្នកជំនាញ ហើយជាលទ្ធផលនៅពេលអ្នកជំនាញទាំងអស់នោះ គឺថាមិនត្រូវបានមកសួរតទល់ដេញដោលនោះទេ។

លោកប្រធាន លោក លោកស្រីចៅក្រម បើសិនណាជាអង្គជំនុំជម្រះមិនមានសំណួរអីមកកាន់យើងខ្ញុំទេ យើងខ្ញុំសុំបញ្ចប់នូវបទបង្ហាញប៉ុននេះ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ព្រះរាជអាជ្ញាខ្ញុំសួរមួយសំណួរ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ បើខ្ញុំនិយាយថាអ៊ីចេះ --តែសុំកែតម្រូវផងបើខ្ញុំនិយាយខុស-- តើ ប៉ុងសូដ៍ លោក ប៉ុងសូដ៍ និង លោក ហេដឌ័រ មិនបានផ្ដល់ចម្លើយជូនអង្គជំនុំជម្រះសាលាដំបូងទេឬ នៅពេលដែលអង្គជំនុំជម្រះមិនទាន់សម្រេចបំបែកសំណុំរឿងនេះជាពីរ? គឺជាពិសេស គឺថានៅពេលបញ្ហាទាំងអស់យើងទទួលបានពាក់ព័ន្ធសហព្រះរាជអាជ្ញា?

**លោក វីល្លៀម ស្មីត៖**

ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទជាក់លាក់ ខ្ញុំនឹងផ្ដល់ជូនចុងក្រោយ ក៏ប៉ុន្តែថាពួកគាត់ទាំងពីរអាចផ្ដល់ចម្លើយនៅក្នុងសំណុំរឿង០០២/០២ ឬក៏អត់នោះទេ ក៏ដូចជា០២/០១នោះ! គឺថាសំណួរបានលេចឡើងអ៊ីចេះ សាក្សីម្នាក់ក្នុងចំណោមពួកគាត់ពីរនាក់ហ្នឹងបានមានលទ្ធភាពបានផ្ដល់សក្ខីកម្មទៅលើប្រធានបទមួយជាក់លាក់ ប៉ុន្តែចម្លើយនោះមិនស្ថិតនៅក្នុងជំនាញរបស់គាត់ទេ។ ក៏ប៉ុន្តែពួកគាត់ទាំងពីរមានលទ្ធភាពផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងបញ្ហានៅក្នុងសំណុំរឿង០០២/០២ តែបើលោកស្រីចៅក្រមសួរពីកាលបរិច្ឆេទ ចាំខ្ញុំផ្ដល់ជូនជាក់លាក់តាមក្រោយ។

បាទ ចំណុចនេះគឺមាននៅក្នុងសារណារបស់យើងខ្ញុំផងដែរ។ ហើយខ្ញុំបញ្ចប់បទបង្ហាញរបស់ខ្ញុំត្រឹមនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ បើលោកចប់ហើយគឺតុលាការកំពូលនឹងសម្រេចថា ទៅសម្រាកហូបបាយថ្ងៃត្រង់។ អ៊ីចឹងគឺយើងត្រូវចូលវិញនៅម៉ោងដប់បីសាមសិបនាទី។ ហើយសូមមន្ត្រីខាងពន្ធនាគារហ្នឹង គឺសុំនាំជនជាប់ចោទហ្នឹងទៅពន្ធនាគារវិញ ហើយនិងនាំមកវិញនៅវេលាម៉ោងដប់បីម្ភៃនាទី។

អ៊ីចឹងតុលាការ ប្រកាសសម្រាក!

*(សវនាការសម្រាកពីម៉ោង១២:១៦ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ។

លោកក្រឡាបញ្ជីសូមរាយការណ៍អំពីវត្តមាន!

**ក្រឡាបញ្ជី៖**

សូមគោរពឯកឧត្តមប្រធាន សូមគោរពអស់លោក លោកស្រី ក្រុមប្រឹក្សា លោកចៅក្រម លោកស្រីចៅក្រមទាំងអស់។ វត្តមានរបស់គូភាគីគឺមានលោកជំទាវ ជា លាង, លោកព្រះរាជអាជ្ញារង វីល្យៀម ស្មីត ហើយខាងសហមេធាវីការពារក្ដីលោក ខៀវ សំផន គឺមានលោក គង់ សំអុន, លោកស្រីមេធាវី អង់តា ហ្គីសសេ និងជនជាប់ចោទលោក ខៀវ សំផន ហើយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានលោកមេធាវី ពេជ អង្គ លោកស្រីមេធាវី មេហ្គិន ហ៊ីសត៍ និងមានដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំរូប គឺមានលោក សាន វី, លោកស្រី សួស ផុន, លោកស្រី គ្រួច ពិច, លោកស្រី ប៉ូ ឌីណា និងលោក ម៉ិញ ផាន់។ បាទ សូមអរគុណ។ អ៊ីចឹងគ្រប់ភាគីមានវត្តមាន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងអង្គជំនុំជម្រះបន្តសវនាការតទៅមុខទៀត ហើយព្រឹកមិញយើងចប់ត្រឹមសារណារបស់សហព្រះរាជអាជ្ញា។ ឥឡូវជាបន្តទៅនេះ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសារណា។

**លោកស្រី មេហ្គិន ហ៊ីសត៍៖**

សូមគោរពឯកឧត្តមប្រធាន ឯកឧត្តម លោកជំទាវ លោក លោកស្រីចៅក្រមទាំងអស់ តាំងពីយើង-- ដោយសារតែនេះជាលើកដំបូងរបស់យើងនៅក្នុងសវនាការនេះ ខ្ញុំសុំលើកឡើងនូវមតិយោបល់បន្តិចបន្តួច សារណារបស់យើងនៅក្នុងសវនាការបណ្ដឹងសាទុក្ខនេះ គឺធ្វើឡើងក្នុងនាមជនរងគ្រោះ ៣៨៦៥ ដែលទទួលបានឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ហើយនិងនៅក្នុងនាមសមាជិកក្រុមប្រឹក្សាដែលនៅរស់រានមានជីវិត ដោយសារតែដើមបណ្ដឹងរាប់រយនាក់គាត់បានបាត់បង់ជីវិតនៅក្នុងដំណើរការនៃកិច្ច -- នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីសំណុំរឿងនេះ។

យើងមានដើមបណ្ដឹងរដ្ឋប្បវេណីតិចតួចដែលមានវត្តមាននៅក្នុងសវនាការនេះ ដោយសារតែកូវីដ ប៉ុន្តែមានដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនទៀតដែលមិនអាចចូលរួមដោយផ្ទាល់នៅទីនេះ។ យើង

ចង់សង្កត់ធ្ងន់ថា ពួកគាត់ទាំងអស់គឺជាភាគីនៃសំណុំរឿងនេះ ហើយសារណារបស់យើងគឺធ្វើឡើងក្នុងនាមពួកគាត់។ ដើមបណ្តឹងរដ្ឋប្បវេណី គឺស្ថិតក្នុងចំណោមអ្នកដែលទទួលរងផលប៉ះពាល់ពីឧក្រិដ្ឋកម្មដែលឯកឧត្តម លោកជំទាវ លោក លោកស្រីចៅក្រមត្រូវធ្វើការសម្រេច។ ហើយពួកគាត់នៅតែទទួលរងការឈឺចាប់រហូតមកដល់ពេលនេះ។ សម្រាប់ពួកគេឧក្រិដ្ឋកម្មមិនមែនជាការសង្ខេបផ្នែកគិតយុត្តទេ គឺជាផ្នែកនៃការរស់នៅពិតប្រាកដរបស់ពួកគេ យើងស្នើសុំឲ្យលោក លោកស្រីចៅក្រម គិតទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីផងនៅពេលដែលធ្វើការពិភាក្សាសម្រេច។ ហើយសូមធ្វើការចេញសាលដីកាឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ហើយសូមធ្វើយ៉ាងណាឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវសាលដីកានេះ គឺមិនមែនទទួលបានត្រឹមតែជាទ្រឹស្តីទេ ប៉ុន្តែជាការជាក់ស្តែងផងដែរ។

[១៣:៣៤:៣៤]

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែមានឱកាសចូលរួមនៅពេលដែលចេញសាលដីកា ហើយពួកគាត់ត្រូវតែអាចជួបជាមួយមេធាវីដើម្បីពិភាក្សាថា សាលដីកាហ្នឹងវាន័យយ៉ាងម៉េច។ នៅចំពោះមុខសាលាដំបូង គឺដើមបណ្តឹងរដ្ឋប្បវេណីបានសង្កត់ធ្ងន់ម្តងហើយម្តងទៀតថា ពួកគេចង់ឲ្យការងាររបស់តុលាការនេះ គឺក្លាយទៅជាមូលដ្ឋានសម្រាប់ការអប់រំទៅដល់ប្រជាជនកម្ពុជាជំនាន់ក្រោយ អំពីប្រវត្តិសាស្ត្រ ហើយនិងធ្វើយ៉ាងណាការពារកុំឲ្យទៅថ្ងៃអនាគតក្មេងជំនាន់ក្រោយ ទទួលរងនូវអំពើសាហាវយង់ឃ្នងដូចដែលពួកយើងបានទទួលយកអ៊ីចឹង។ យើងស្នើសុំឲ្យមានការធានាថាសាលដីកាគឺជាមូលដ្ឋានសម្រាប់ការអប់រំ ហើយធ្វើការពិចារណាឲ្យបានឆាប់រហ័សដើម្បីឲ្យមានការផ្សព្វផ្សាយទៅដល់សង្គម ដើម្បីឲ្យសាធារណជនគាត់ទទួលបានដឹងឮ យល់អំពីសាលដីកា។ នៅក្នុងវគ្គថ្ងៃនេះ យើងនឹងនិយាយអំពីបញ្ហាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

គឺដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍របស់សហចៅក្រម-- របស់ចៅក្រមរបាយការណ៍អ៊ីចឹងដែរ គឺយើងចង់ឲ្យមានសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ដើមបណ្តឹងរដ្ឋប្បវេ-ណី ទីពីរ គឺការអះអាងអំពីការប្រព្រឹត្តដោយអយុត្តិធម៌ទៅលើភស្តុតាងមួយចំនួន រួមទាំងភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទីបី គឺការអះអាងអំពីភាពលម្អៀង។

លោក លោកស្រីចៅក្រមទទ្បីករណ៍របស់ ខៀវ សំផន នៅក្នុងបណ្តឹងសាទុក្ខនេះហាក់ដូចជាសន្និដ្ឋានថាតើការសម្រេចអំពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីគឺមានទៅបាន ទាល់តែមានប្រយោ-ជន៍ដល់ជនជាប់ចោទ។ ពួកគេបានលើកឡើងនៅក្នុងសារណាថ្ងៃ១២ មីនា ២០១១ ដែលថា ដើមបណ្តឹង

រដ្ឋប្បវេណីមិនមានផលប្រយោជន៍ដោយផ្ទាល់នៅក្នុងទឡ្ហីករណ៍សវនាការនោះឡើយ។ វិធីសាស្ត្រនេះគឺធ្វើឱ្យយល់ច្រឡំទៅលើហេតុផល និងលក្ខណៈនៃការធានាអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ប្រាកដណាស់ថា ខៀវ សំផន មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចគ្នានឹង នួន ជា ដែរ ប៉ុន្តែពួកគេមិនមែនជាម្ចាស់កម្មសិទ្ធិនៃបញ្ហាទទួលបានជំនុំជម្រះដោយយុត្តិធម៌នោះទេ។ ការជំនុំជម្រះដោយយុត្តិធម៌ គឺដើម្បីប្រយោជន៍ទាំងអស់គ្នា គឺការសម្រេចបែបនេះបង្កើតឱ្យមានកន្លែងមួយដែលថា មានការជំនុំជម្រះហាក់ដូចជាមានការញែករវាងភាគីនានា។ ដូច្នេះហើយគឺថា សាលក្រមត្រូវតែមានការសម្រេចដែលអាចជឿជាក់បាន ហើយផ្តល់ដើម្បីផ្តល់ជាសិទ្ធិដល់ជនរងគ្រោះក្នុងការទទួលបានការពិតផងដែរ។

[១៣:៣៩:១២]

ការជំនុំជម្រះយុត្តិធម៌ក៏សំខាន់ដែរ ដោយសារវារក្សាភាពស្របច្បាប់និងភាពអាចជឿជាក់បាននៃស្ថាប័នមួយនេះ ហើយបើសិនជាគ្មានកត្តាទាំងអស់នេះទេ ដំណាក់កាលទាំងអស់នេះ នឹងបាត់នូវតម្លៃរបស់ខ្លួនសម្រាប់សាធារណជនកម្ពុជា និងដើមបណ្តឹងរដ្ឋប្បវេណី។

លោក លោកស្រី ចៅក្រម សាលាដំបូងបានទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺឯកសារ F26/2/2 កថាខណ្ឌ៧។ សំខាន់បំផុតចំពោះពួកគេនោះ គឺសិទ្ធិទទួលបានតម្លាភាព។ សិទ្ធិទទួលបានភាពឆាប់រហ័ស និងសិទ្ធិទទួលបានសច្ចភាព។ ហើយនៅក្នុងសវនាការទាំងអស់នេះយើងនឹងនិយាយដដែលៗយោងទៅរកសិទ្ធិទាំងអស់នេះ ជាពិសេសតែម្តង។ ហេតុអ្វីបានជាវាសំខាន់? វាសំខាន់ព្រោះថានៅពេលវាយតម្លៃថាតើកិច្ចដំណើរការនីតិវិធីយុត្តិធម៌ឬអត់ហ្នឹង លោក លោកស្រី ចៅក្រម ត្រូវតែចាំថា អង្គជំនុំជម្រះសាលាដំបូងតម្រូវមិនត្រឹមតែពិចារណាថា កិច្ចដំណើរការនីតិវិធីហ្នឹងយុត្តិធម៌ចំពោះ ខៀវ សំផន ឬក៏អត់នោះទេ ប៉ុន្តែត្រូវធានាថាវាយុត្តិធម៌ចំពោះភាគីទាំងអស់។

ខ្ញុំសូមលើកឧទាហរណ៍មួយចំនួន។ ខៀវ សំផន តវ៉ាថា សាលក្រមប្រកាសមុនពេលដែលមានសម្អាងហេតុពេញលេញ។ យើងយល់ស្របថា នេះមិនមែនជារំលោភបំពានទៅលើនីតិវិធីនោះឡើយ ប៉ុន្តែក្រៅពីនេះទៅទៀត ខៀវ សំផន មិនអាចកំណត់ថាមានព្យសនកម្មអ្វីដែលបណ្តាលមកពីបញ្ហានេះទៅលើគាត់នោះទេ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានសិទ្ធិទទួលបានសាលក្រមដែលឆាប់រហ័ស ហើយសិទ្ធិទាំងអស់ហ្នឹង គឺជំរុញដោយការប្រកាសសាលក្រមឱ្យបានឆាប់រហ័សតាមដែលអាច

ធ្វើទៅបាន។ ការពន្យារពេលប្រកាសសាលក្រមគឺមានន័យថាជាការរង់ចាំបន្ថែមទៀត ដើម្បី-- សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយពួកគាត់រង់ចាំរាប់សិបឆ្នាំមកហើយ។ ហើយមានដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនរូបបានស្ដាប់នៅក្នុងអំឡុងពេលនេះ។

[១៣:៤១:៣២]

ខៀវ សំផន កាលពីព្រឹកនេះ បានយោងទៅរកសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣១ មីនា ២០២១ នៅក្នុងរឿងក្ដីជីបាបូ។ សេចក្ដីសម្រេចហ្នឹងគាំទ្រគោលជំហររបស់យើងទៅវិញទេ គឺថាអង្គជំនុំជម្រះតុលាការកំពូលរបស់ អាយ.ស៊ី.ស៊ី បានសម្រេចថា គឺអនុញ្ញាតទៅបាន ដែលសេចក្ដីសម្រេចត្រូវប្រកាសមុនពេលមានសម្អាងហេតុ ហើយវាបានចង្អុលបញ្ជាក់យ៉ាងច្បាស់ថា សាលាដំបូងតម្រូវថាឲ្យមានការថ្លឹងថ្លែងរវាងគោលការណ៍សិទ្ធិមនុស្ស ហើយនិងដំណើរការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺកថាខណ្ឌ១៦៦។

អង្គជំនុំជម្រះតុលាការកំពូលរបស់ អាយ.ស៊ី.ស៊ី បាននិយាយថាត្រូវថ្លឹងថ្លែងទៅលើការងារពីរ ឬក៏កាតព្វកិច្ចពីរ ទីមួយ គឺផ្ដល់មតិដែលមានសម្អាងហេតុពិតប្រាកដ ដូចសម្អាងហេតុពេញលេញ ហើយម្យ៉ាងទៀតគឺកាតព្វកិច្ចត្រូវបកស្រាយ និងអនុវត្តលក្ខន្តិកៈឲ្យស្របទៅតាមគោលការណ៍សិទ្ធិមនុស្សជាអន្តរជាតិ គឺលក្ខន្តិកៈទីក្រុងរ៉ូម។

វាប្រាកដណាស់ថា ដូចដែល ខៀវ សំផន បានលើកឡើងអ៊ីចឹង គឺថានៅក្នុងករណីរបស់យើងនេះ គឺត្រូវមានការថ្លឹងថ្លែងរវាងសាលក្រម និងការចេញសម្អាងហេតុ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលរបស់ អាយ.ស៊ី.ស៊ី បានបញ្ជាក់ផងដែរថា វាត្រូវតែថ្លឹងថ្លែងរវាងសិទ្ធិមនុស្សជាមួយនឹងការចេញសាលដីកា។

អង្គជំនុំជម្រះនោះក៏បានបញ្ជាក់ថា កិច្ចដំណើរការនីតិវិធីតម្រូវឲ្យមានការគោរពទៅតាមនីតិវិធីអន្តរជាតិ មិនមែនសម្រាប់តែភាគីណាមួយទេ ប៉ុន្តែសម្រាប់គ្រប់ភាគីទាំងអស់ ជនរងគ្រោះ ព្រមទាំងសាធារណជន គឺនៅក្នុងកថាខណ្ឌ១៦១។

ទឡ្ហីករណ៍អំពីសិទ្ធិជំនុំជម្រះផ្សេងទៀតរបស់ ខៀវ សំផន គឺមានការលំបាកដូចគ្នា ដែលមិនបានផ្ដល់អំពីសិទ្ធិ និងផលប្រយោជន៍របស់ភាគីដទៃ រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ ប្រាកដណាស់ថា ទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងការដាក់បង្ហាញការទទួលភស្តុតាងថ្មី និងការចេញសេចក្ដីសម្រេចលើបុគ្គលដែលត្រូវមកផ្ដល់សក្ខីកម្ម។

[១៣:៤៤:០៧]

ចំណុចសំខាន់គឺថា អត្ថន័យនៃភាពយុត្តិធម៌គឺមិនមែនសម្រាប់តែ ខៀវ សំផន ម្នាក់ឯងនោះទេ អង្គជំនុំជម្រះមានកាតព្វកិច្ចយ៉ាងលំបាកក្នុងការថ្លឹងថ្លែងរវាងភាពយុត្តិធម៌សម្រាប់ភាគីទាំងអស់។ ហើយនេះគឺជាលក្ខខណ្ឌតម្រូវដែលចែងនៅក្នុងវិធាន២១(១) នៃវិធានផ្ទៃក្នុង។

ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីប្រធានបទទីពីរ ទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង ជាពិសេសគឺការអះអាងរបស់ ខៀវ សំផន ដែលថាគេមិនគិតពិចារណាអំពីភស្តុតាងដោះបន្ទុកនោះ។ នេះជាការអះអាងដែលធ្វើឡើងដដែលៗ ដោយនៅក្នុងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី។ ប៉ុន្តែមិនមានការបញ្ជាក់ ឬក៏ការពន្យល់អ្វីទាក់តែសោះ។ ការពិត គឺថាមេធាវីការពារក្ដី គាត់មិនយល់ស្របជាមួយលទ្ធផលនៃការសម្រេចរបស់សាលាដំបូង។ មិនមានការបង្ហាញថាសាលាដំបូងប្រើវិធីសាស្ត្រដែលមិនអាចធ្វើទៅបាន ឬក៏មិនអាចអនុញ្ញាតបានក្នុងការថ្លឹងថ្លែងភស្តុតាងនោះឡើយ។

នៅក្នុងសារណារបស់គាត់ ខៀវ សំផន បាន ដូចដែលគាត់និយាយនៅព្រឹកមិញនេះផងដែរ ហើយនៅកន្លែងដទៃទៀត គាត់និយាយថា ដើមបណ្ដឹងរដ្ឋប្បវេណី គឺភស្តុតាងរបស់ដើមបណ្ដឹងទទួលបានការផ្ដល់តម្លៃជាពិសេស។ ការណ៍នេះគឺជាការសំខាន់ ហើយខ្ញុំ -- ហើយដូចដែលចៅក្រមរបាយការណ៍បានបញ្ជាក់នៅក្នុងកថាខណ្ឌទី៩ ខ្ញុំនឹងលើកអំពីបញ្ហានេះ។

[១៣:៤៥:៤៤]

ខ្ញុំនឹងយោងទៅលើឧទាហរណ៍មួយទាក់ទងទៅនឹងការគ្រប់គ្រង ការរៀបអាពាហ៍ពិពាហ៍។ ខ្ញុំឮថាមានការតវ៉ាជាច្រើននៅក្នុងបណ្ដឹងរបស់មេធាវីការពារក្ដីទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាងនេះ។ ខៀវ សំផន បាននិយាយថា សាលាដំបូងខុសឆ្គងក្នុងការសម្រេចថាប្រជាជនត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ហើយពួកគេបាននិយាយនៅក្នុងកថាខណ្ឌ១៣៨៣ នៃបណ្ដឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមិនបានគិតអំពីភស្តុតាងដែលបង្ហាញថា វាជាភស្តុតាងដោះបន្ទុក។

ភស្តុតាងដែលផ្ដល់ -- ភស្តុតាងនេះគឺភស្តុតាងរបស់កម្មាភិបាលដែលអះអាងថាមានការស្វែងរក ការយល់ព្រមពីគូស្រករមុនពេលរៀបការ។ តាមពិតទៅ សាលាដំបូងបានកំណត់ ហើយពិចារណាយ៉ាងលម្អិតល្អន់ទៅលើភស្តុតាងរបស់កម្មាភិបាលនោះដែរ គឺថានៅក្នុងសាលក្រមមានបញ្ជាក់គឺ កថាខណ្ឌ៣៦០៥, ៣៦០៩, ៣៦១២, ៣៦១៧, ៣៦៧៣, និង ៣៦៧៥។ ប៉ុន្តែសាលាដំបូងក៏មានភស្តុតាងដាក់បន្ទុករឹងមាំនៅចំពោះខ្លួនផងដែរ មកពីដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន និងសាក្សីជាច្រើន គឺពួកគាត់

លើកឡើងផ្ទុយពីនេះទៅវិញទេ។ ពួកគេផ្តល់សក្ខីកម្មថាគេគ្មានជម្រើស ប៉ុន្តែពួកគេត្រូវរៀបការអ្វីដែលអង្គការបានរៀបចំ។

[១៣:៤៧:៣០]

លោក លោកស្រីចៅក្រម យោងទៅរកកថាខណ្ឌ ៣៦១៨ ដល់ ៣៦២២, ៣៦៧៣ នៃសាលក្រមរបស់សាលាដំបូង។ សាលាដំបូងបានថ្លឹងថ្លែង និងពិចារណាទាំងទៅលើភស្តុតាងដោះ និងដាក់បន្ទុក ហើយផ្តល់សម្អាងហេតុច្បាស់សម្រាប់ការសន្និដ្ឋាន គឺថាទោះបីថាមានការស្វែងរកការយល់ព្រមនៅក្នុងលក្ខណៈផ្លូវការមួយចំនួនក្តី ប៉ុន្តែវាមិនមែនការយល់ព្រមពិតប្រាកដទេ ព្រោះវាស្ថិតនៅក្នុងបរិបទនៃការបង្ខិតបង្ខំ។ គឺនៅក្នុងសាលក្រមកថាខណ្ឌ ៣៦២៣, ៣៦៧៣ ដល់ ៣៦៧៤, ៣៦៧៦ ជាដើម។

អង្គជំនុំជម្រះក៏បានវាយតម្លៃផងដែរថា វាមានកម្មាភិបាលខ្លះ គឺព្យាយាមធ្វើយ៉ាងណាបន្ថយការទទួលខុសត្រូវ។ ហេតុដូច្នេះហើយទើបមិនអាចជឿទុកចិត្តបាន ដូចជាកថាខណ្ឌ ៣៦០៩, ៣៦១៣, ៣៦២៣, ៣៦៧៥ ជាដើម។

ការសន្និដ្ឋានរបស់សាលាដំបូងគឺផ្តល់សម្អាងហេតុយ៉ាងច្បាស់លាស់ ដោយចំណាយជាច្រើនទំព័រ ហើយមានការវាយតម្លៃសមហេតុផលទាំងស្រុង ទាំងទៅលើភស្តុតាងដោះ និងដាក់បន្ទុក។ កថាខណ្ឌទាំងអស់ហ្នឹងគឺមានការវាយតម្លៃប្រកបដោយសម្អាងហេតុទាំងទៅលើភស្តុតាងដោះ និងដាក់បន្ទុក។

[១៣:៤៩:១៣]

ខៀវ សំផន ជំទាស់ទៅលើការពិត ដែលថាសាលាដំបូងបានពិចារណាផងដែរទៅលើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់កម្មាភិបាល នៅពេលដែលពួកគាត់ហ្នឹងកាត់បន្ថយការទទួលខុសត្រូវ ហើយមេធាវីហាក់ដូចជាជំទាស់ថា សាលាដំបូងមិនបានពិចារណាទៅលើសម្អាងហេតុសមស្របមួយចំនួនសម្រាប់ភាពមិនស្មោះត្រង់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងបានឆ្លើយតបអំពីការអះអាងទាក់ទងទៅនឹងភស្តុតាងទាំងអស់នេះ គឺនៅក្នុងកថាខណ្ឌ១៨៥ ដល់ ១៩៥។

ដូចដែលយើងនឹង -- ពន្យល់នៅទីនោះ ដើមបណ្តឹងរដ្ឋប្បវេណីប្រាកដណាស់ គឺមានផលប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធី ប៉ុន្តែផ្នែកសំខាន់នៃផលប្រយោជន៍នេះ គឺស្ថិតនៅត្រង់ការស្វែងរកការពិតអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងទៅលើពួកគេគាត់ ហើយធ្វើយ៉ាងណាឲ្យគេដឹង និងយល់អំពីការពិត។ ការកុហក គឺជាការក្បត់ទាំងស្រុងទៅលើគោលបំណងទាំងអស់នេះ។ យើងមិនអាចសន្មតថា ដោយគ្រាន់តែមានផលប្រយោជន៍គឺធ្វើឲ្យយើងយល់ថា ជាការមិនស្មោះត្រង់នោះទេ។ គឺថា

ភស្តុតាងនីមួយៗគឺថា ទៅមើលជាផ្ទាល់តែម្តង។ ប៉ុន្តែយើងទៅមើលថាតើប្រជាជនពួកគាត់ទាំងអស់ហ្នឹងមានមូលហេតុអីដើម្បីកុហកអំពី បទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬក៏អត់ ការសម្រេចរបស់សាលាដំបូងពាក់ព័ន្ធទៅនឹងកម្មាភិបាលគឺផ្ទុះបញ្ចាំងការពិតដែលថា មនុស្សពេលខ្លះ គឺនិយាយកុហកមែន ដើម្បីការពារខ្លួនគេ។ បានន័យថាការពារពីការវាយតម្លៃពីសហគមន៍ផងដែរ។

[១៣:៥០:៥៧]

ការលើកឡើងថាដើមបណ្តឹងរដ្ឋប្បវេណីកុហក ដើម្បីគ្រាន់តែអះអាងដោយកុហកថា ការរៀប-ការរបស់គេគឺបង្ខំហ្នឹង គឺជារឿងផ្សេង។ ការនិយាយអំពីការត្រូវគេបង្ខំហ្នឹង ការនិយាយអំពីការមិនអាចរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីគឺជាការ គឺជាបញ្ហាលំបាក ជាលក្ខណៈបុគ្គលដើម្បីឲ្យប្រជាជនគាត់លើកមកនិយាយ។ វាអាចទាំងជារឿងអាម៉ាសផងដែរ។ និយាយម្យ៉ាងវិញទៀត វគ្គណាដែលគាត់ចង់ការពារខ្លួនប្រាកដណាស់ គឺនៅស្ងៀមមិនប៉ាននិយាយទេ មិនមែនទៅប្រឌិតអំពីបទពិសោធន៍ទាំងអស់នេះទេ និយាយឲ្យទូទៅទៀតទៅ គឺយើងប្រឆាំងដាច់ខាតជាមួយនឹងការលើកឡើងរបស់មេធាវីការពារក្តីដែលថាភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺទទួលបានការឲ្យតម្លៃពិសេស។ នៅក្នុងកថាខណ្ឌ៥៩នៃសាលក្រមគឺបាននិយាយថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានវាយតម្លៃម្តងមួយៗដូចតែភស្តុតាងរបស់សាក្សីផងដែរ។ ហើយនេះគឺជាអ្វីដែលសាលាដំបូងធ្វើជាការ ជាជាក់ស្តែង។

នៅក្នុងកថាខណ្ឌ៣១៤ ដល់៣១៦ នៅក្នុងសំណុំរឿង០២/១ គឺចៅក្រុមតុលាការកំពូលបានប្រើប្រាស់វិធីសាស្ត្រត្រឹមត្រូវ។

ចំណុចមួយចុងក្រោយគឺខ្ញុំចង់និយាយនៅថ្ងៃនេះ គឺដូចដែលនៅក្នុងរបាយការណ៍របស់សហចៅក្រមរបាយការណ៍ គឺមានការចោទប្រកាន់អំពីលម្អៀង ដោយសារតែមានទំនាក់ទំនងរវាង ០២/១ និង០២/២ ហើយនិងការប្រើប្រាស់ចៅក្រមសឹងតែដូចគ្នាដដែលក្នុងការជំនុំជម្រះរឿងក្តីទាំងពីរនេះ។ ព្រឹកនេះ ខៀវ សំផន បានយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស គឺសេចក្តីសម្រេចលេខ១១ គឺចំពោះយើងច្បាស់ណាស់ទៅហើយ ខ្ញុំសូមអភ័យទោសចំពោះមេធាវីការពារក្តីប្រសិនបើខ្ញុំបកស្រាយផ្សេង គឺចំពោះយើង គឺគោលជំហររបស់យើងគឺថា សេចក្តីសម្រេចហ្នឹង គឺអត់មានពាក់ព័ន្ធទៅនឹងបញ្ហាដែលលោក លោកស្រីចៅក្រម ត្រូវជំនុំជម្រះនៅពេលនេះទេ។ ឯកសារ១១ គឺពាក់ព័ន្ធទៅនឹងលម្អៀងរបស់ចៅក្រមតុលាការកំពូលនោះទេ។ ប៉ុន្តែនៅក្នុងបណ្តឹងសាទុក្ខនេះ គឺលោក លោកស្រីចៅក្រម ត្រូវជំនុំជម្រះពីភាពលម្អៀងរបស់ចៅក្រមសាលាដំបូងនោះទេ។ ដូច្នេះបញ្ហាលម្អៀង

គឺរបស់ចៅក្រមសាលាដំបូង ហើយការចោទប្រកាន់នេះ គឺចោទប្រកាន់ទៅលើសាលាដំបូងទេ។ បញ្ហានេះ គឺនៅក្នុងសេចក្ដីសម្រេចថ្ងៃ៣០ មករា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសគឺនិយាយអំពីសាលាដំបូង។ យើងមានការព្រួយបារម្ភខ្លាំងពីការលើកបញ្ហានេះមកឡើងវិញនៅដំណាក់កាលនេះ។ ហើយគោលការណ៍សច្ចភាពនៃដំណើរការនីតិវិធី គឺជាគោលការណ៍ដ៏សំខាន់។ ហើយនៅក្នុងវិធាន២១ កថាខណ្ឌ១ គឺបានន័យថា បញ្ហាត្រូវធ្វើការសម្រេចតាមផ្លូវតុលាការក្នុងករណីពិសេសដែលមានភាគីនៃសំណុំរឿងក្តី។ វាគឺជាបញ្ហាអាជ្ញាអស់ជំនុំ មិនអាចបើកធ្វើការជំនុំជម្រះឡើងវិញនោះទេ។ ប្រសិនបើយើងទុកគោលការណ៍នេះ ចោលមួយដុំសិន គឺវានឹងបណ្ដាលឲ្យមានភាពរញ៉េរញ៉ៃទាំងនៅក្នុងដំណើរការ ក៏ដូចភាពយុត្តិធម៌នៃប្រព័ន្ធ ព្រោះថា ភាគីចាំបាច់ត្រូវតែពឹងផ្អែកទៅលើការសម្រេចរបស់តុលាការដើម្បីឲ្យពួកគេអាចចាត់វិធានការបន្ត។

[១៣:៥៥:០៨]

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេសទៅលើបញ្ហានេះ គឺជាដំណាក់កាលដំបូងនៃសវនាការលើភស្តុតាងនៅក្នុងសំណុំរឿងនេះ គឺមានការជំនុំជម្រះតែ៧ថ្ងៃ ស្ដាប់ទៅលើភស្តុតាង ហើយមានមនុស្សតែប្រាំនាក់ប៉ុណ្ណោះ ក្នុងនោះមានដើមបណ្ដឹងរដ្ឋប្បវេណីតែពីរនាក់ដែលមកផ្តល់សក្ខីកម្មនៅទីនេះ។ នៅពេលនោះ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្សេង គឺបានន័យថាវាត្រូវតែនឹងការបង្កើតអង្គជំនុំជម្រះសាលាដំបូងថ្មី។ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះពិសេសបានសម្រេចផ្សេងពីនេះ ហើយផលវិបាកនៃការសម្រេចនេះ គឺថាការជំនុំជម្រះត្រូវបន្តជាមួយនឹងចៅក្រមដដែល។ ហើយដំណាក់កាលបន្តនៃការជំនុំជម្រះគឺបន្តផ្អែកលើសពីនេះ ហើយក្រោយពីហ្នឹងមក គឺមានមនុស្ស១៨០នាក់ក្នុងនុំងមានទាំងដើមបណ្ដឹងរដ្ឋប្បវេណី៦១នាក់ដែលបានមកផ្ដល់ភស្តុតាងគឺសឹងតែចំណាយពេលវេលាយ៉ាងច្រើន។មែនទែន។ ហើយមានការជំនុំជម្រះដើម្បីផ្អែកទៅលើភាពការពិត។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញខ្លួនហើយនិយាយប្រាប់សាធារណជនអំពីបញ្ហាដែលមានសារៈសំខាន់ជាបុគ្គលបំផុតចំពោះពួកគេ ដែលពឹងផ្អែកដែលថាចៅក្រមទាំងអស់នេះគឺមានសិទ្ធិក្នុងការស្ដាប់ និងសម្រេចទៅលើបញ្ហាទាំងអស់នេះ។

ប្រាកដណាស់ថា កាលៈទេសៈមួយដែលបញ្ហានេះអាចលើកឡើងសាជាថ្មីនោះគឺថា ប្រសិនបើមានឯកសារ ឬក៏ភស្តុតាងផ្សេងដែលអាចបង្ហាញថាវាមានភាពលម្អៀង ហើយឯកសារទាំងអស់នោះគឺមិនបានលើកយកមកចំពោះក្រុមប្រឹក្សាជំនុំជម្រះពិសេស។ ប៉ុន្តែមិនមានឯកសារសម្ភារៈថ្មីនោះទេ។ មេធាវីការពារក្តីមិនបានលើកអ្វីថ្មីនោះទេ ការយោងតែមួយដែលអាចថាជាការយោងថ្មីហ្នឹងគឺការយោង

ដោយមិនច្បាស់លាស់នៅក្នុងកថាខណ្ឌ១២៩ នៃបណ្តឹងសាទុក្ខទៅលើសាលក្រមសំណុំរឿង០០២/០១ គឺគ្រាន់តែថា ខៀវ សំផន គ្រាន់តែអះអាងថា សាលាដំបូងបានបញ្ជាក់ថា អនុវត្តទៅតាមការសម្រេចពីសំណុំរឿង០០២/០១។ នៅព្រឹកនេះគឺខ្ញុំបានឮថា មេធាវីការពារក្តី ខៀវ សំផន លើកបញ្ហាជាច្រើន អានោះមិនមែនជាបញ្ហាអីទេ គ្រាន់តែជាការយោងទៅលើសំណើរឿង០០២/០១ មកប៉ុណ្ណោះ។ ដូច្នេះចំពោះយើងៗពិបាកក្នុងការស្រមៃមើលថា តើភាពដែលយោងតែពីមួយកថាខណ្ឌនៅក្នុងសំណុំរឿងហ្នឹងធ្វើយ៉ាងណាអាចឲ្យមានការបើកជំនុំជម្រះឡើងវិញទៅលើរឿងដែលគេជំនុំជម្រះរាប់ឆ្នាំមកហើយនោះៗ។ យើងយោងទៅលើសំណុំ -- ទៅលើអ្វីដែល ខៀវ សំផន បានអះអាងនេះ គឺថាគាត់មិនអាចលើកយករឿងតិចតួចមកដើម្បីឲ្យបើកសំណុំរឿងចុងក្រោយនេះនោះ។

[១៣:៥៨:៣៥]

ជាចុងក្រោយទៅលើការចោទប្រកាន់ពីភាពលម្អៀងនោះគឺយើងបានលើកនៅក្នុងសារណារបស់យើងរួចមកហើយ គឺនៅក្នុងកថាខណ្ឌ៨៦ ដល់ ៨៧។ យើងមានការព្រួយបារម្ភអំពីការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរ ដែលលើកឡើងដោយមនុស្សម្នាក់ដែលគ្រាន់តែមានអ្វីជារឿងលេងសើចប៉ុណ្ណោះ។ ការអះអាងនេះអាចមានផលប៉ះពាល់ទៅដល់ការធ្វើឲ្យប៉ះពាល់ទៅដល់ភាពជឿជាក់បាននៃស្ថាប័ននេះ ដោយគ្មានមូលដ្ឋានអ្វីទាំងអស់។ ដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យកិច្ចដំណើរការនេះយុត្តិធម៌ ហើយមានប្រសិទ្ធភាព ហើយលក្ខណៈនេះ គឺធានាអំពីនីត្យានុកូលភាពរបស់តុលាការនេះ។

ដើម្បីការពារស្របច្បាប់ យើងស្នើសុំដល់ លោក លោកស្រី ចៅក្រម ឲ្យបញ្ជាក់ឲ្យបានច្បាស់ថា ទោះបីថាយកចិត្តទុកដាក់ខ្លាំងក្លាទៅលើការចោទប្រកាន់ពីភាពលម្អៀងក៏ដោយ ប៉ុន្តែករណីទាំងអស់នេះគឺចង់បញ្ជាក់ថា ការលើកឡើងអំពីភាពលម្អៀងនេះ គឺគ្មានអ្វីគាំទ្រឡើយ។ ហើយខ្ញុំសូមបញ្ចប់ការលើកជាសារណារបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តទៀត ជាសំណួររបស់អង្គជំនុំជម្រះ។ ខ្ញុំសូមអញ្ជើញលោកចៅក្រមដែលមានសំណួរ សូមអញ្ជើញលើកឡើងបាទ។

អ៊ីចឹងអង្គជំនុំជម្រះអត់មានសំណួរទេ អ៊ីចឹងខ្ញុំឆ្លងចូលដល់របាយរបស់ចៅក្រមរបាយការណ៍។ សូមអញ្ជើញលោកសហចៅក្រមរបាយការណ៍ធ្វើរបាយការណ៍។

[១៤:០១:១០]

**ចៅក្រម សោម សិរិវឌ្ឍ៖**

របាយការណ៍របស់សហចៅក្រមរបាយការណ៍ សម្រាប់វគ្គស្ដីពីទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។ ជនជាប់ជាប់ចោទបានលើកទឡ្ហីករណ៍មួយចំនួននៃបណ្ដឹងសាទុក្ខជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងជំទាស់ទៅនឹងការយល់ឃើញដែលពាក់ព័ន្ធ។ សារណារបស់គាត់ត្រូវបានសង្ខេបជាបួនចំណុចសំខាន់ៗដូចខាងក្រោម៖

ទីមួយ ជនជាប់ចោទបានលើកឡើងថា អង្គហេតុមួយចំនួនដែលបានផ្អែកទៅលើក្នុងការបង្ហាញពីបទឧក្រិដ្ឋ គឺពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ការបញ្ចូលសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតដោយសារអង្គហេតុទាំងនេះពុំត្រូវបានបញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាឡើយ។ ជនជាប់ចោទបានអះអាងថា រួមទាំងអង្គហេតុដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម និងការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខភ្នំក្រោល ក្រាំងតាចាន់ និងអូរកន្សែង។ សារណាក៏បានរួមបញ្ចូលផងដែរនូវការបោសសម្អាតផ្ទៃក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យលើកលែងតែអង្គហេតុដែលបានកើតឡើងក្នុងភូមិភាគឧត្តរនៅក្នុងឆ្នាំ១៩៧៦ និងភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨។

[១៤:០៣:១៤]

ការប្រព្រឹត្តទៅលើអ្នកកាន់ពុទ្ធសាសនានៅសហករណ៍ត្រាំកក់ និងអង្គហេតុពាក់ព័ន្ធទៅនឹងគោលនយោបាយទូទាំងប្រទេសចំពោះអ្នកកាន់ពុទ្ធសាសនា និងការប្រព្រឹត្តទៅលើជនជាតិចាមដែលចេញឆ្ងាយពីអង្គហេតុដែលបានកើតឡើងបន្ទាប់ពីឆ្នាំ១៩៧៧ ក្នុងស្រុកកងមាស និងក្រូចឆ្មារ។ អំណះអំណាងដដែល បានលើកឡើងនូវការប្រព្រឹត្តទៅលើជនជាតិវៀតណាម ដែលពុំស្ថិតក្នុងខេត្តស្វាយរៀងព្រៃវែង និងការឈ្លានពានចូលប្រទេសវៀតណាម។ ជនជាប់ចោទបានជំទាស់ទៅនឹងការពិចារណាលើអង្គហេតុទាំងអស់សម្រាប់បទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃព្រឹត្តការណ៍នីមួយៗ នៃបទឧក្រិដ្ឋនិងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដែលត្រូវបានចោទប្រកាន់ថា ពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរមានដូចជា៖ បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការនិរទេស ការដាក់ឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតដូចជា ការ

ធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ នៅក្នុង -- នៅចំណុចបន្ទាប់នៃទឡ្ហីករណ៍បណ្តឹងសាទុក្ខ ជនជាប់ចោទបានជំទាស់ទៅនឹងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថាការជំទាស់របស់គាត់ ទៅនឹងការបញ្ជូនសំណុំរឿងយុត្តាធិការនៃបទចោទដែលបានលើកឡើងនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ បានធ្វើឡើងយឺតពេល។

[១៤:០៥:២៨]

ជនជាប់ចោទបានជំទាស់ទៅនឹងការបកស្រាយវិធាន៨៩ នៃវិធានផ្ទៃក្នុង និងលើកឡើងថា ការបកស្រាយពុំត្រឹមត្រូវលើវិធាន៨៩នៃវិធានផ្ទៃក្នុង។ មានន័យថា ការយល់ឃើញណាមួយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធទៅនឹងទីកន្លែង និងព្រឹត្តិការណ៍ប្រព្រឹត្តបទឧក្រិដ្ឋខាងលើ ត្រង់ចំណុចពាក់ព័ន្ធទៅនឹងអង្គហេតុដែលពុំស្ថិតក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមត្រូវបដិសេធចោល។

អង្គជំនុំជម្រះស្នើជនជាប់ចោទពន្យល់ពីមូលហេតុដែលខ្លួនពុំបានលើកការជំទាស់ទាំងនេះតាំងពីដំបូងនៅមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ។ បន្ទាប់មកទៀត នៅពេលសវនាការចាប់ផ្តើមលើអញ្ញត្រកម្មបឋម និងផ្តល់សេចក្តីយោងជាក់លាក់ត្រង់ចំណុចដែលជនជាប់ចោទបានលើកនៅដំណាក់កាលមុនកាលជំនុំជម្រះ និងថាបញ្ហានេះពុំត្រូវបានសម្រេចពិតប្រាកដដូចដែលបានអះអាងនៅក្នុងសារណាបណ្តឹងសាទុក្ខ។

[១៤:០៦:៤៩]

ទីពីរ ជនជាប់ចោទបានលើកឡើងថា បទចោទមួយចំនួននៅក្នុងដីកាដំណោះស្រាយខ្វះភាពច្បាស់លាស់ និងគ្រប់គ្រាន់ដើម្បីបំពេញតាមបទដ្ឋានអប្បបរមាស្តីពីការបង្ហាញភស្តុតាងចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋទាំងនេះ និងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលដែលអង្គជំនុំជម្រះបានបដិសេធសារណារបស់ខ្លួនដែលជំទាស់ទៅនឹងកង្វះភស្តុតាងដែលអាចជឿជាក់រឹងមាំ និងស៊ីសង្វាក់គ្នាដែលជាមូលដ្ឋាននៃបទចោទ។ អង្គជំនុំជម្រះស្វាគមន៍ការបំភ្លឺ អំពីការយល់ឃើញនៃដំណាក់កាលជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតដែលពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងដីកាដំណោះស្រាយ និងបន្ទាប់មក ការយល់ឃើញអំពីពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូងនៃបទចោទមួយចំនួននៅក្នុងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យមានការបំភ្លឺលើចំណុចនេះ ដូច

ដែលបានលើកឡើង និងសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ។

[១៤:០៨:០៩]

ទីបី អង្គជំនុំជម្រះសាលាដំបូង បានបកស្រាយដីកាដំណោះស្រាយពុំត្រឹមត្រូវ ដោយពិចារណាលើបទឧក្រិដ្ឋដែលពុំស្ថិតក្នុងវិសាលភាពយុត្តាធិការដែលជាកម្មវត្ថុនៃរឿងក្ដីរបស់ខ្លួន។ កំហុសអង្គច្បាប់នេះនាំឲ្យអង្គជំនុំជម្រះសាលាដំបូង ជំនុំជម្រះអង្គហេតុនៅក្រៅវិសាលភាពរបស់ខ្លួន និងឈានដល់ការ យល់ឃើញដែលគប្បីត្រូវបដិសេធចោលនាពេលនេះ។ ការយល់ឃើញនេះបានរួមបញ្ចូលអង្គហេតុពាក់ ព័ន្ធទៅនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មី ទាហាននៃរបបសាធារណរដ្ឋខ្មែរ និងសត្រូវពិតប្រាកដ និងតាមការសន្មតនៅ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខផ្សេងៗ។ ការយល់ឃើញផ្នែកអង្គហេតុទាំងអស់ទាក់ទងទៅនឹងអំពើ ប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល កំណត់គោលដៅលើជនជាតិវៀតណាមនៅក្នុងទឹកដីនៃរបបកម្ពុជាប្រជាធិបតេយ្យ និង អំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម ត្រូវបានជំទាស់ក្រោមយុត្តា-ធិការដែលជាកម្មវត្ថុនៃរឿងក្ដី។

ទីបួន អង្គហេតុដែលត្រូវបានដកចេញតាមរយៈ ដីកាបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានដាក់បញ្ចូលមកវិញដោយអង្គជំនុំជម្រះសាលាដំបូង ដែលបន្ទាប់មកបានជំនុំជម្រះលើអង្គហេតុដែលស្ថិតនៅក្រៅយុត្តាធិការរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូង ពុំមានសមត្ថកិច្ចស្ដាប់អង្គហេតុដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោ-បាយ អំពើអមនុស្សធម៌ដទៃទៀតពាក់ព័ន្ធទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំនៅជនជាតិវៀតណាម។ ដូចគ្នានេះដែរ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំគប្បីឲ្យជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទី២ ដោយសារជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពរួចហើយ ពីបទឧក្រិដ្ឋតែមួយដូចគ្នាក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលស្នើផ្ដល់សេចក្ដីយោងជាក់លាក់ទៅលើផ្នែកនៃសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលចោទថាបកស្រាយពុំត្រឹមត្រូវនោះ។

ជាចុងក្រោយ ខ្ញុំសូមបញ្ចប់នូវរបាយការណ៍ស្ដីពីទឡ្ហីករណ៍បណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹង

យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងតាមកម្មវិធី គឺយើងត្រូវសម្រាក គឺត្រូវសម្រាក ហើយបន្ទាប់មកបានសារណារបស់មេធាវីការពារក្តី ខៀវ សំផន។ អ៊ីចឹងក្នុងការសម្រាកនេះគឺ ខ្ញុំសូមបញ្ជាក់ថា យើងនឹងចូលវិញនៅវេលាម៉ោងដប់បួន និង សែសិបនាទី។ អ៊ីចឹងសូមសម្រាក!

*(សវនាការសម្រាកពីម៉ោង ១៤:១២ នាទី ដល់ម៉ោង ១៤:៣៧ នាទី)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត សូមអញ្ជើញខាងសហមេធាវីការពារក្តី ខៀវ សំផន ធ្វើសារណា។

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន!

ដូចដែលចៅក្រមរបាយការណ៍បានលើកឡើងមកហើយគឺថា មូលដ្ឋានបណ្តឹងសាទុក្ខរបស់យើងស្ថិតនៅក្នុងការអនុវត្តហួសបណ្តឹងទាំងមូល ដែលជះឥទ្ធិពលទៅលើរបៀបនៃអង្គហេតុត្រូវបានស្តាប់ និងវិភាគដោយអង្គជំនុំជម្រះ។ យើងយោងទៅសារណារបស់យើងអំពីព័ត៌មានលម្អិត ហើយដោយសារពេលវេលាយើងមាននេះ គឺថាយើងនឹងសុទ្ធផ្តោតទៅលើចម្លើយទៅនឹងសំណួររបស់អស់លោក លោកស្រី ហើយនិងឆ្លើយតបទៅព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយខ្ញុំសូមថ្លែងបឋមមុន ជាមុនសិន តបទៅនឹងសហភាគាមកពីដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងថា -- សូមរំឭកទៅដល់សារណារបស់យើងចុះថ្ងៃទី១២ មីនា ឆ្នាំ២០១២ F60/1។ ខ្ញុំសូមបញ្ជាក់ថា យើងមិនដែលបានពិភាក្សាជាមួយគាត់អំពីយុត្តិធម៌នៃការជំនុំជម្រះនោះទេ ក៏ប៉ុន្តែអ្វីដែលមិនត្រូវពន្យល់ទៅគាត់នោះគឺថានិយាយពីបណ្តឹងទាំងមូល គឺវាជាបញ្ហាជាក់លាក់របស់ពួកគាត់ ហើយមិនត្រូវនិយាយអំពីបញ្ហាទូទៅដែលការពារដោយព្រះរាជអាជ្ញាហើយនោះទេ។ ខ្ញុំជាមេធាវីជនជាតិបារាំង គឺខ្ញុំអនុវត្តច្បាប់ស៊ីវិល ដូចសហភាគាខ្ញុំក៏អ៊ីចឹងដែរ។ ដូច្នេះលើគោលការណ៍នេះយើងមិនមានការលំបាកអ្វីទេ ក្នុងការធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនីតិវិធីបាន។

[១៤:៤០:៥៤]

ក៏ប៉ុន្តែផ្ទុយទៅវិញ មានលក្ខខណ្ឌមួយចំនួនក្នុងការចូលរួមរបស់ពួកគេ ជាពិសេសនៅចំពោះ អ.វ.ត.ក នេះ គឺជាដែនកំណត់ដែលអង្គជំនុំជម្រះកំណត់ហើយ។ ចំណុចមួយដែលយើងបានលើកឡើង នេះ នៅពេលដែលយើងធ្វើការកត់សម្គាល់ទាក់ទងទៅនឹងកាលវិភាគសវនាការ ក៏ប៉ុន្តែយើងមើលទៅ ឃើញថាមានការប្រាស់ចាកចេញពីវិសាលភាព គឺថាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបទៅដល់ការ ដាក់ទោស ដែលជាបុព្វសិទ្ធិរបស់សហព្រហរាជអាជ្ញា។ គង់ សំអុន គាត់នឹងនិយាយអំពីបញ្ហានេះនៅ ពេលក្រោយ។

ខ្ញុំសូមរំឭកថា ដើម្បីឲ្យច្បាស់លាស់ជាងហ្នឹង គឺរំឭកពីក្របខ័ណ្ឌដែលអស់លោក លោកស្រី ចៅក្រមសម្រេចនៅក្នុងឯកសារពី F10/2 ដែលចេញនៅក្នុងសំណុំរឿង០០២/០១ ដែលអស់លោក លោកស្រី ចៅក្រម បានរំឭកនៅក្នុងសេចក្តីសម្រេចនៅក្នុងថ្ងៃទី០៦ ខែ១២ ឆ្នាំ២០១៩ សេចក្តីសម្រេច F52/1។

[១៤:៤២:០៧]

បើតាមយុត្តិសាស្ត្រ គឺថាសិទ្ធិឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងគឺមានភាពរឹតត្បិត គឺ រឹតត្បិតដោយមានមូលដ្ឋានគាំទ្រត្រឹមត្រូវ ហើយនិងមានភាពចាំបាច់ត្រូវគោរពសិទ្ធិរបស់ជនជាប់ចោទ ដូចជា គោលការណ៍សមភាពនៃគូភាគីជាដើម។ ហើយនៅក្នុងសេចក្តីសម្រេច F10/2 កថាខណ្ឌ១៧ គឺ បានសម្រេចថា អំណះអំណាងដែលបានលើកឡើងក្នុងចម្លើយនោះ គឺត្រូវតែទាក់ទងនឹងមធ្យោបាយ -- ទាក់ទងទៅនឹងមូលដ្ឋានដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្ប -- សិទ្ធិរបស់ និងផលប្រយោជន៍របស់ដើម បណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ ហើយកុំនិយាយអំពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយ កុំ ឲ្យនិយាយជាន់គ្នា។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺត្រូវតែចូលអន្តរាគមន៍បំពេញបង្គ្រប់ទៅលើកិច្ច ការរបស់ព្រះរាជអាជ្ញាចំពោះតែបញ្ហាណាដែលទាក់ទងដោយផ្ទាល់នូវសិទ្ធិ ហើយនិងផលប្រយោជន៍ របស់គាត់ជាក់លាក់ ហើយមិនត្រូវអន្តរាគមន៍បន្ថែមលើព្រះរាជអាជ្ញាទៀតទេ។ ហើយមុននេះយើង ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺគាត់អនុវត្តទៅការពារសិទ្ធិជាទូទៅ ហើយជាការពិតណាស់គឺ យើងឃើញថាមានចេតនាបែបនេះនៅក្នុងចម្លើយការឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ យើង គឺឃើញថាចេតនាទាំងនេះវាឃើញ វាស្តែងឡើងយ៉ាងច្បាស់ ព្រោះថាគាត់បានធ្វើឡើងហួសពី ដែនកំណត់ដែលអស់ លោក លោកស្រី ចៅក្រម បានធ្វើ។ ឧទាហរណ៍ ដូចជាឆ្លើយតបទៅនឹងមូលដ្ឋាន

ណ្តឹងឧទ្ធរណ៍របស់យើង ដែលមិនពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់នោះទេ។ ដូច្នេះ -- ហើយមូលហេតុដែលគាត់លើកឡើងនោះគឺថា មិនច្បាស់ទេដែលនៅកថាខណ្ឌ នៅក្នុងចម្លើយរបស់គាត់នោះ ដើមបណ្តឹងរដ្ឋប្បវេណីនោះបានឆ្លើយថា សិទ្ធិរបស់គាត់គឺត្រូវបានបំពេញ។ ការលើកឡើងពីអ្វីដែលឆ្លងកាត់ដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ គឺវាមិនគោរពតាមយុត្តិសាស្ត្ររបស់លោកលោកស្រីចៅក្រមនោះទេ ហើយខ្ញុំសុំយកទៅលើដីការបស់ លោក លោកស្រី។ ទោះយ៉ាងណាក្តី ទាក់ទងទៅនឹងបណ្តឹងទាំងមូលតែម្តង ខ្ញុំនឹងត្រឡប់មកបញ្ហានេះ។ គោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺវាផ្ទុយពីអ្វីដែលបានលើកឡើង។ គាត់និយាយដដែលៗអំពីអ្វីដែលព្រះរាជអាជ្ញាបានលើកហើយ ហើយបន្ទាប់មកគាត់បន្ថែមទឡ្ហីករណ៍ទៅទៀត ដោយកាន់ -- ប្រកាន់គោលជំហរគតិយុត្តប្រឆាំង និងផ្ទុយពីសហព្រះរាជអាជ្ញាទៀតផង។

[១៤:៤៥:២១]

ការលើកឡើងដ៏តិចតួចបំផុតពាក់ព័ន្ធទៅនឹងផលប្រយោជន៍ និងការការពារទាក់ទងទៅនឹងការបណ្តឹងទាំងមូលនេះ ពាក់ព័ន្ធនឹងអង្គហេតុដែលយើងជំទាស់នោះ ដែលយើងថា-- ដែលថាបណ្តឹងទាំងអស់នេះមិនបានបញ្ជូនមកដោយស្របច្បាប់នោះទេ ដែលថាកាលណាបើអង្គហេតុទាំងអស់នេះវាមិនបានបញ្ជូនមកឱ្យស្របច្បាប់ទេ ត្រឹមត្រូវទេ គឺការលើកឡើងពីអង្គហេតុទាំងអស់នេះវាមិនមានប្រយោជន៍ទេ។ ប៉ុន្តែចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ យើងនិយាយថាវាមិនមែនអត់ប្រយោជន៍ទាំងអស់ទេ នៅពេលដែលពួកគាត់ត្រូវបានចោទសំណួរ ហើយរំឭកពីចំណុចណាមួយ គឺអង្គជំនុំជម្រះតែងតែប្រើចម្លើយរបស់គាត់នៅក្នុងសាលក្រមទាំងអស់ អ៊ីចឹងមានព្យសនកម្មអីនោះទេ។ បន្ទាប់ទៀតគឺទាក់ទងនឹងបណ្តឹងទាំងមូលនេះ យើងសូមរំឭកថាព្រះរាជអាជ្ញាត្រូវតែការពារផលប្រយោជន៍រួម ហើយត្រូវគោរពសមភាពនៃគូភាគី។ ហើយយើងជាមួយ ខៀវ សំផន យើងមានគ្នាតិច ហើយខាងព្រះរាជអាជ្ញានុំងមានគ្នាច្រើន អ៊ីចឹងហើយធ្វើយ៉ាងណាធ្វើឱ្យមិនមានសមភាពនៃគូភាគីហ្នឹងកាន់តែខ្លាំងទៅៗ។ ហើយឥឡូវនេះខ្ញុំនឹងសុំចូលទៅនិយាយអំពីជំពូកអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលដោយត្រឹមត្រូវតាមច្បាប់។ យើងបានលើកឡើងអំពីមូលដ្ឋានទាក់ទងទៅនឹងការផ្តន្ទាទោសដែលយើងថា អង្គជំនុំជម្រះមិនបានទទួលអង្គហេតុមួយចំនួននោះមិនត្រឹមត្រូវតាមច្បាប់ គឺថាមានអង្គហេតុចំនួនបួន គឺថាអង្គហេតុដែលនៅក្រៅពាក្យបណ្តឹងរបស់ចៅក្រមស៊ើបអង្កេត ហើយនិងអង្គហេតុដែលបន្ទុកនុំងមិនគ្រប់គ្រាន់ទេដើម្បីបញ្ជូនទៅជំនុំជម្រះ។ ហើយប្រភេទទីបីនោះគឺអង្គហេតុដែលមិនត្រូវបានកំណត់ជាប្រភេទ

បទល្មើសនៅក្នុងដីកាដំណោះស្រាយ។

[១៤:៤៧:៤១]

ចំណុចទីបួន គឺអង្គហេតុដែលត្រូវបានដកចេញដោយអង្គជំនុំជម្រះ នៅពេលដែលខ្លួនបានបំបែកកិច្ចដំណើរការនីតិវិធី។ ដូច្នេះគឺកាត់បន្ថយការចោទប្រកាន់។ ដូច្នេះ យើងនិយាយអំពីពាក្យប្តឹងទាំងមូលតែម្តង គឺប្រភេទអង្គហេតុទាំងបួននេះបានត្រូវបែងចែកជាពីរជំពូក គឺកំហុសរបស់សហចៅក្រមស៊ើបអង្កេតតាំងពីដើមមក គឺមានវិការៈនៅក្នុងដីកាដំណោះស្រាយ ដែលយើងហៅថាជំពូក“ក” ហើយបន្ទាប់ទៀតគឺជាកំហុសនៃការបកស្រាយរបស់អង្គជំនុំជម្រះ ហៅថាជំពូក“ខ” ដែលរួមបញ្ចូលកំហុសទាំងឡាយពាក់ព័ន្ធនឹងការបកស្រាយលើដីការដំណោះស្រាយ និងដីកាបំបែកកិច្ចសំណុំរឿង។ អ៊ីចឹងការបកស្រាយនេះ គឺនៅពេលស៊ើបអង្កេតនោះគឺគាត់បានធ្វើហួស អនុវត្តហួសពីវិសាលភាពនៃបណ្តឹង។

ឥឡូវនេះ ខ្ញុំនឹងលើកឡើងអំពីពេលវេលា និងពេលដែលយើងត្រូវធ្វើការតវ៉ា។ នៅក្នុងពិភពមួយដ៏ឥតខ្ចោះនោះដែលវិធានផ្ទៃក្នុងមិនមានកម្រិតដូចសព្វថ្ងៃនេះ គឺយើងប្រហែលជាអាចលើកការតវ៉ារបស់យើងមុនការជំនុំជម្រះសេចក្តីបាត់ទៅហើយ។ នេះគឺជាបញ្ហាមួយដ៏សំខាន់ណាស់ ពីព្រោះថាអង្គជំនុំជម្រះបានលើកឡើងថា ការតវ៉ារបស់យើងមិនអាចទទួលយកបានក្រោមមូលហេតុថា លើកឡើងយឺតយ៉ាវពេក អ្វីដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់យើង។ ព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយដ៏វែងលើចំណុចនេះ ហើយអង្គជំនុំជម្រះក៏ចោទសំណួរមួយដែរពាក់ព័ន្ធនឹងប្រធានបទ។ ខ្ញុំនឹងលើកមកនិយាយពីចំណុចនេះនៅពេលក្រោយ អំពីការតវ៉ារបស់យើងនេះ។

[១៤:៤៩:៥២]

និយាយអំពីពេលវេលានិងការតវ៉ារបស់យើងទាក់ទងនឹងអង្គហេតុជំពូក“ខ” -- ហើយនិងជំពូក“ខ”។ ឥឡូវចំណុចទីមួយ បញ្ហាទីមួយ គឺថា តើហេតុអ្វីបានយើងមិនបានលើកការតវ៉ានេះចំពោះមុខអង្គជំនុំជម្រះ ហើយនិងអង្គបុរេ? គឺជាសំណួរដែលអស់លោក លោកស្រីចៅក្រមបានចោទនៅកថាខណ្ឌ១៤នៃរបាយការណ៍របស់លោកស្រីចៅក្រម ហើយយើងនឹងឆ្លើយតបនឹងសំណួរនេះ។ នៅក្នុងសំណួរនេះអស់លោក លោកស្រី ចៅក្រម បាននិយាយថា ផ្តល់យោងជាក់លាក់ពីពេលវេលាដែលយើងបានលើកឡើងនៅដំណាក់កាលស៊ើបអង្កេតនូវការតវ៉ាទាំងអស់នេះ។ យើងខ្ញុំមិនមាន -- មិនដឹងថា អស់លោក លោកស្រី ចៅក្រម និយាយអំពីយោងណានៅក្នុងបណ្តឹងសាទុក្ខរបស់យើង ឬក៏យ៉ាងណា? ប្រហែលជាមានការមិនយល់គ្នាក្នុងចំណុចនេះ ព្រោះថាយើងមិនដែលបានលើកឡើងអំពីការតវ៉ារបស់យើងនៅក្នុង

ដំណាក់កាលស៊ើបអង្កេតនោះទេ។ អ៊ីចឹង ខ្ញុំសុំសួរបញ្ជាក់កន្លែងនេះ ហើយបន្តមកទៀតខ្ញុំនឹងនិយាយអំពីថាហេតុអ្វីបានយើងមិនតវ៉ានៅចំពោះមុខចៅក្រមស៊ើបអង្កេត ហើយនិងអង្គបុរេជំនុំជម្រះ។ ខ្ញុំសូមរំឭកថា ចម្លើយនេះនឹងធ្វើឡើងតាមលក្ខណៈច្បាប់តែប៉ុណ្ណោះ ហើយមិនមែននិយាយពីបទហេតុ -- ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងទាំងពីរនាក់នោះទេ គឺ គង់ សំអុន ហើយនិងខ្ញុំគឺគាត់ចូលមកទីនេះនៅចុងឆ្នាំ២០១១ ហើយខ្ញុំចូលមកដើមឆ្នាំ២០១២ គឺថាបានចូលមកក្រោយពេលធ្វើអញ្ញត្រកម្ម។ អ៊ីចឹងយើងមិនអាចនិយាយជំនួសអ្នកដែលធ្វើការនៅទីនេះមុនយើងទេ ក៏ប៉ុន្តែយើងជាអ្នកការពារ ខៀវ សំផន យើងអាចនិយាយអំពីច្បាប់ ហើយនិងសង្កេតឃើញអំពីឧបសគ្គដែលកើតឡើង ហើយដែលនាំឲ្យមានការតវ៉ានៅពេលនោះ។ ដូចខ្ញុំបានលើកឡើងអ៊ីចឹងគឺថា នេះវាជាបញ្ហាសំខាន់ណាស់នៅពាក់ព័ន្ធវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ដែលមិនទាក់ទងតែ ខៀវ សំផន ម្នាក់នោះទេ គឺវាទាក់ទងទៅជនជាប់ចោទទាំងអស់នៅក្នុងចំពោះមុខតុលាការនេះ គឺឧទាហរណ៍ គឺថាវិធាន៧៤ នៃវិធានផ្ទៃក្នុង ដែលនិយាយអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមិនបើកឲ្យមានឧបាស្រ័យអ្វីទាល់តែសោះ។

ហើយវិធាន៨៩ នៃវិធានផ្ទៃក្នុងដែលនិយាយអំពីការអញ្ញត្រកម្មបឋមនៅចំពោះមុខសាលាដំបូងថា នៅពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរហើយ គឺមិនអាចលើកអញ្ញត្រកម្មនេះបានទេ។ ហើយខ្ញុំឃើញថា ដូចខាងព្រះរាជអាជ្ញាហ្នឹងដូចជាធ្វើ ចង់មាន ចង់ធ្វើអន្តរាគមន៍អីមួយ។

[១៤:៥៣:១០]

**លោកស្រី ហេឡេន វើសនុប៖**

ខ្ញុំស្ដាប់មេធាវីការពារក្ដីលើកឡើងអត់ឮសួរ។ ថាតើយើងអាចកែតម្រូវឡើងវិញ ឬក៏យ៉ាងម៉េច ឬក៏គួរសម្រាកកែតម្រូវចំណុចនេះព្រោះខ្ញុំស្ដាប់អត់បានឮនូវអ្វីដែលមេធាវីការពារក្ដីលើកឡើងអម្បាញ់មិញ?

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបើសិនជាសហព្រះរាជអាជ្ញាស្ដាប់មិនបានទេ គឺសូមឲ្យខាងសហមេធាវីហ្នឹង ដែលមានប្រសាសន៍អំមិញជួយមានប្រសាសន៍ម្ដងទៀត។

**លោកស្រី ហេឡេន វើសនុប៖**

ចាស លោកប្រធានដូចខ្ញុំបានលើកឡើងហ្នឹង ខ្ញុំស្ដាប់វាអត់ឮការលើកឡើងរបស់មេធាវីការពារក្ដី ខ្ញុំស្ដាប់ឆានែលអង់គ្លេស ក្រែងលោវាមានបញ្ហាខាងខ្ញុំ ឬដោយយ៉ាងណានោះ អ៊ីចឹងឯងបានជាខ្ញុំសុំ

សំណួមពរ ថាតើយើងអាចកែតម្រូវនូវចំណុចដែលមេធាវីការពារក្ដីលើកឡើងដែរឬទេ? ឬក៏ថាអាចឈប់សម្រាកកែតម្រូវឡើងវិញ ឬក៏យ៉ាងម៉េចលោកប្រធាន? សូមអភ័យទោសដែលខ្ញុំរំខានដល់ដំណើរការកិច្ចដំណើរការនីតិវិធី។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងខាងបច្ចេកទេសហ្នឹងគឺផែកមើល តើបាត់ពីចំណុចណាទៅ ដើម្បីឱ្យសហមេធាវីហ្នឹងគឺមើលគាត់និយាយឡើងវិញ។

[១៤:៥៥:៤២]

**លោកស្រី ហេឡេន វើសនុប៖**

សូមអធ្យាស្រ័យលោកប្រធាន ចំណុចនេះវាពាក់ព័ន្ធទៅនឹងសារណារបស់យើងខ្ញុំ ជាពិសេសខ្ញុំចាប់អារម្មណ៍ទៅលើសារណាពាក់ព័ន្ធទៅនឹងមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ដែលមេធាវីការពារក្ដីគាត់ទើបលើកឡើងអម្បាញ់មិញនេះ។

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមិនដឹងថាអ្នកបកប្រែជាភាសាអង់គ្លេសនេះឮយ៉ាងម៉េចទេ ឥឡូវខ្ញុំនិយាយជាភាសាបារាំងមើល៍ ចង់ដឹងថាអ្នកបកប្រែទៅជាភាសាអង់គ្លេសហ្នឹងស្ដាប់ឮទេ ហើយបញ្ហាហ្នឹងដោះស្រាយហើយឬនៅ?

**ប្រធានអង្គជំនុំ៖**

លោកស្រីសហព្រះរាជអាជ្ញាជាតិហ្នឹងស្ដាប់បានទេអំមិញហ្នឹងគឺនៅពេលដែលខាងសហមេធាវីបាននិយាយហ្នឹង?

**លោកស្រី ជា លាង៖**

ឯកឧត្ដមប្រធានស្ដាប់បាន ប៉ុន្ដែគ្រាន់តែឮដូចមានសំឡេងអីក្នុងហ្នឹងរំខាន ដូចមានសំឡេងស្រមោចអ៊ីចឹង កក់ៗចូលក្នុងនុ៎ង។

**ប្រធានអង្គជំនុំ៖**

ផែកមើលមីក្រូហ្វូនរបស់គាត់ហ្នឹងក្រែងលោថាវ *អែរ*ភ្ជីរានុ៎ង អស់ថ្ម អស់អី។

*(មានបញ្ហាបច្ចេកទេស)*

[១៤:៥៨:០០]

**លោកស្រី ហេឡេន វើសនុប៖**

លោកប្រធានខ្ញុំយល់ថា មិនមែនពាក់ព័ន្ធទៅនឹងមីក្រូរបស់មេធាវីការពារក្ដីទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវខាងអ្នកបច្ចេកទេសគាត់កំពុងតែឆែកមើលណេះ! ចាំម៉េចៗចាំមានដំណោះស្រាយរួច ចាំជម្រាបជូនទៀត ជម្រាបជូនបាទ។

[១៤:៥៨:៣៤]

**លោកស្រី ហេឡេន វើសនុប៖**

សូមអរគុណច្រើនលោកប្រធាន។

*(មានបញ្ហាបច្ចេកទេស)*

[១៥:០៣:០៣]

**ប្រធានអង្គជំនុំ៖**

ខាងបច្ចេកបានធ្វើរួចហើយ អ៊ីចឹងខ្ញុំសួរទៅខាងសហព្រះរាជអាជ្ញាអន្តរជាតិ តើគាត់ស្ដាប់មិនទាន់បានហ្នឹង គឺស្ដាប់មិនបានត្រង់ ចាប់ពីចំណុចណាមក?

សូមបញ្ជាក់ម្ដងទៀត សហព្រះរាជអាជ្ញាអន្តរជាតិ តើលោកស្រីស្ដាប់មិនបាន ចាប់ពីត្រង់ណាមក?

**លោកស្រី ហេឡេន វើសនុប៖**

ជម្រាបប្រសាសន៍លោកប្រធាន សូមជម្រាបថា តាមកានែលជាអង់គ្លេស និង-- អ៊ីចឹងៗការបកប្រែនេះ គឺបើតាមមើលទៅគឺថាទាំងបីក្រឡាហ្នឹងស្ដាប់អត់បានឮទាល់តែសោះតែម្ដង លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ខ្ញុំជាឆានែលខ្មែរហ្នឹង ស្ដាប់បានធម្មតាទេ អត់មានបញ្ហាទេ ប៉ុនអំមិញនេះលោកស្រីសហព្រះរាជអាជ្ញាអន្តរជាតិដែលគាត់មានប្រសាសន៍មក យើងអត់ទទួលបានការបកប្រែទេ អ៊ីចឹងសុំឱ្យបញ្ជាក់ឡើងវិញម្ដងទៀត លោកស្រីសហព្រះរាជអាជ្ញាអន្តរជាតិហ្នឹង គឺស្ដាប់មិនបានហ្នឹងចាប់ពីចំណុចណាមក?

**លោកស្រី ហេឡេន វើសនុប៖**

សូមអរគុណលោកប្រធាន ជម្រាបដោយត្រង់គឺថា សារណាដែលលើកឡើង គឺខ្ញុំស្ដាប់ស្ទើរតែ

មិនឮទាល់តែសោះនូវសារណាផ្ទាល់មាត់ដែលមេធាវីការពារក្តីលើកឡើង។ បើសិនជាលោកប្រធានមិនយល់ទាល់ទេ សុំឱ្យគាត់ឡើងនិយាយសាជាថ្មីលោកប្រធាន។ អ៊ីចឹងសូមជម្រាបថា គឺពាក់ព័ន្ធទៅនឹងសារណារបស់មេធាវីលើកឡើងអម្បាញ់មិញនេះ អត់ ស្ទើរតែមិនឮសោះ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងខ្ញុំបញ្ជាក់ជូនបន្តិច ដើម្បីឱ្យកុំពេលវេលាហ្នឹងយឺតយ៉ាវ បើសិនជាស្តាប់មិនបានត្រង់ចំណុចណាមួយ អាចលើកឡើងភ្លាមៗមក ហើយកុំទុករង់ចាំឱ្យយូរពេក ដូចជាគាត់បានលើកឡើងនេះ អស់រយៈពេលជាង ១០ នាទីជាងហើយ បានឆ្លើយ បានៗបញ្ជាក់ថាស្តាប់អត់បាន នាំឱ្យពិបាក។ អ៊ីចឹងដើម្បីឱ្យច្បាស់លាស់ឡើងវិញ គឺសូមអញ្ជើញសហមេធាវីការពារក្តីហ្នឹង លើកឡើងទាំងអស់ឡើងវិញតែម្តងទៅ។ បាទ សូមអញ្ជើញ!

[១៥:០៦:៥១]

**លោកស្រី អង់គា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំនឹងត្រឡប់ឡើងវិញតាំងពីដើមទីមក។ សូមបញ្ជាក់ផងដែរថា ខ្ញុំនឹងមិននិយាយពាក្យទាំងអស់បេះបិទនោះទេ ព្រោះថាជាទូទៅនោះ គឺខ្ញុំសម្របសម្រួលខ្លួនទៅតាមដំណើរការសវនាការហ្នឹង។ ខ្ញុំបានចាប់ផ្តើមនិយាយពីបណ្តឹងទាំងមូលនោះ ថាខ្ញុំនឹងផ្តោតទៅលើចម្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ហើយនិងឆ្លើយតបទៅនឹងព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយខ្ញុំក៏បានលើកឡើងផងដែរអំពីពាក្យការអន្តរាគមន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនិយាយអំពីសារណារបស់យើងចុះថ្ងៃទី១២ មីនា ឆ្នាំ២០២១ F60/1 ដែលនិយាយថា យើងមិនដែលលើកឡើងជំទាស់អំពីសិទ្ធិរបស់ពួកគាត់ហ្នឹងពីមុនមកទេ ទាក់ទងទៅនឹងយុត្តិធម៌នៃនីតិវិធី ក៏ប៉ុន្តែផ្ទុយទៅវិញយើងបានមិនត្រូវឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងទាំងមូលនោះទេ ពីព្រោះថា ព្រោះចំណុចទាំងអស់នេះវាជាបុព្វសិទ្ធិរបស់ព្រះរាជអាជ្ញានោះទេ ដែលពួកគាត់ហ្នឹងតំណាងឱ្យផលប្រយោជន៍ហ្នឹង ហើយនិងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ផលប្រយោជន៍រួម ហើយនៅពេលដែលមានការការពារផលប្រយោជន៍រួមនេះហើយ គឺវាជាការសំខាន់ណាស់ ដែលមិនចាំបាច់ឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយដដែលនោះទេ។ អ៊ីចឹងហើយត្រូវរឹតត្បិតនៅក្នុងបណ្តឹងឧទ្ធរណ៍នេះគឺរឹតត្បិតចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំក៏បានលើកឡើងផងដែរថា បញ្ហានេះ វាបញ្ហាគោលការណ៍ទេ គឺថាយើង លោក គង់ សំអុន ហើយនិងខ្ញុំហ្នឹងគឺជាអ្នកសិក្សាច្បាប់ផ្នែកស៊ីវិលឡ

ហើយទាក់ទងនឹងការចូលរួមចំណែកពីដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺវាមិនមានបញ្ហាអីទេ ចំពោះយើងទេ ក៏ប៉ុន្តែធ្វើយ៉ាងម៉េចកុំឲ្យគាត់ប្រាសចាកពីដែនកំណត់ដែលកំណត់ដោយតុលាការ រហូតទៅដល់និយាយអំពីទោសជាដើមនោះ ហើយ គង់ សំអុន គាត់នឹងលើកឡើងពីចំណុច ហើយព្រោះថាចំណុចនេះគឺជាបុព្វសិទ្ធិរបស់ព្រះរាជអាជ្ញានោះទេ។

[១៥:០៩:៣២]

ដើម្បីនិយាយឲ្យអស់តែម្ដងទៅ ខ្ញុំបានដកស្រង់ម្ដងទៀតគឺសេចក្ដីសម្រេច F10 គឺថាចុះ ដែលចេញនៅក្នុងសំណុំរឿង០០២/១ ដែលអស់លោក លោកស្រី ចៅក្រម បានរំឭកនៅក្នុងសំណុំ០ ០២/២ ដែរ ដែលចុះនៅថ្ងៃទី០៦ ខែ១២ ឆ្នាំ២០១៩ គឺឯកសារ F52/1 នៅក្នុងយុត្តិសាស្ត្រនេះ គឺអស់លោក លោកស្រីចៅក្រមបាននិយាយថា ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺត្រូវតែមានភាពរឹតត្បិត ដូចជាត្រូវតែមានសម្អាងហេតុត្រឹមត្រូវ ហើយនិងគោរពសិទ្ធិជាមូលដ្ឋាននៃជនជាប់ចោទផងដែរ ឧទាហរណ៍សមភាពនៃគូភាគីជាដើម។ ហើយខ្ញុំយោងទៅលើសេចក្ដីសម្រេចរបស់អស់លោក លោកស្រី គឺឯកសារ F10/2 កថាខណ្ឌ១៧។ អំណះអំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺត្រូវតែទាក់ទងទៅនឹងមូលដ្ឋានច្បាប់ដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែចៀសវាងកុំនិយាយអំពីអ្វីដែលព្រះរាជអាជ្ញាបានលើកឡើងហើយ។ នៅក្នុង -- យើងបានលើកឡើងពីចំណុចនេះនៅក្នុងសារណារបស់បណ្ដឹងឧទ្ធរណ៍របស់យើង។ ធ្វើការរឹតត្បិតនេះដោយហេតុថា ព្រះរាជអាជ្ញាហ្នឹងគាត់បានការពារផលប្រយោជន៍ទូទៅ ក៏ដូចជាផលប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណីដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏ត្រូវចូលរួមរឹតត្បិតធ្វើយ៉ាងម៉េចដើម្បីបង្គ្រប់បំពេញឲ្យព្រះរាជអាជ្ញាបានហើយ ហើយនិងការពារផលប្រយោជន៍ជាក់លាក់របស់ពួកគាត់បានហើយ ហើយមិនត្រូវបំពេញបន្ថែមឲ្យលើសទៅលើកិច្ចការរបស់ព្រះរាជអាជ្ញានោះទេ។ ហើយខ្ញុំក៏បានលើកឡើងផងដែរថាទោះបីមានការណែនាំអ៊ីចឹងក៏ដោយ ក៏ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះគឺឃើញថាវាប្រាសចាកហួសពីដែនកំណត់ គឺថាចេតនារបស់គាត់ហ្នឹង គឺគាត់ចង់ឆ្លើយលើសពីផលប្រយោជន៍ជាក់លាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទៅទៀត។ នេះដូចគាត់មានលើកឡើងអ៊ីចឹង។ ដូចអស់លោក លោកស្រីចៅក្រម គាត់លើកឡើងពីចំណុចនេះនៅក្នុងសេចក្ដីសម្រេច -- នៅក្នុងកំណត់ត្រាជើងទំព័រគឺ ឯកសារ F10/2។ ខ្ញុំនិយាយផងដែរថាចម្លើយតបរបស់យើងនេះគឺថា ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងបណ្ដឹងទាំងមូលតែម្ដង ដែលចំណុចនេះមិនពាក់ព័ន្ធទៅនឹងសិទ្ធិផលប្រយោជន៍ជាក់លាក់របស់គាត់ទេ គឺ

សិទ្ធិផលប្រយោជន៍ទូទៅដែលព្រះរាជអាជ្ញាបានការពាររួចទៅហើយ។

ហើយខ្ញុំក៏បានបន្ថែមផងដែរថា មូលហេតុដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺមានលក្ខណៈទូលំទូលាយពេក មិនច្បាស់លាស់ ដូចថានៅកថាខណ្ឌ១១៥, ១១៧នេះ គឺថា គាត់និយាយថា គាត់ត្រូវការយុត្តិធម៌ផ្នែកច្បាប់។ ឃើញថាវាមានភាពមិនច្បាស់លាស់ គឺយើងបានឆ្លើយតបវិញថា វាមិនសមស្របទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះរបស់អស់លោក លោកស្រី ចៅក្រមទេ យើងនិយាយថា សារណារបស់គាត់នោះវាមានលក្ខណៈទូទៅពេក ដែលមិនអាចឲ្យអស់លោក លោកស្រីទទួលយកបានស្របទៅតាមដែនកំណត់ដែលបានកំណត់ទុកនោះ។ ជួនកាលហ្នឹង ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងបានបន្ថែមទឡ្ហីករណ៍បន្ថែមទៅទៀត ហើយជួនកាលប្រកាន់គោលជំហរផ្លូវច្បាប់ហ្នឹងខុសពីព្រះរាជអាជ្ញាទៅទៀត។

[១៥:១៣:៥៥]

ហើយការលើកឡើងនៅកថាខណ្ឌ១៥៩ និង ១៨០ នៅសារណារបស់គាត់ហ្នឹង ដែលគាត់ -- ដែលគាត់និយាយថា គាត់ផ្តល់ពេលវេលាឲ្យយើងហ្នឹង ហើយដែលថាសក្ខីកម្មរបស់គាត់ហ្នឹងវាមិនសូវមានប្រយោជន៍នោះ។ អង្គជំនុំជម្រះតែងតែប្រើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមែនថាចម្លើយរបស់គាត់អត់មានប្រយោជន៍នោះទេ ហើយចង់និយាយថា ទោះបីជាមានការលើក -- ឥឡូវនេះខ្ញុំបានលើកឡើងការកត់សម្គាល់ទាំងអស់នេះហើយ ខ្ញុំនឹងចូលទៅជំពូកអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលដោយត្រឹមត្រូវតាមច្បាប់។ ហើយអង្គហេតុទាំងអស់នេះមានបួនប្រភេទ គឺទីមួយអង្គហេតុដែលចេញប្រើប្រាស់ចាកហួសពីវិសាលភាពនៃការស៊ើបអង្កេត ហើយអង្គហេតុដែលបន្ទុកមិនគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ ហើយនិងប្រភេទទីបី គឺអង្គហេតុដែលមិនត្រូវបានកំណត់ប្រភេទ ជាប្រភេទបទល្មើសនៅក្នុងដីកាដំណោះស្រាយ ហើយនិងអង្គហេតុដែលត្រូវបានដកចេញពី ដោយអង្គជំនុំជម្រះនៅពេលដែលបំបែកកិច្ចដំណើរការនីតិវិធី។ ហើយនៅក្នុងអង្គហេតុទាំងបួននេះ គឺមានបណ្តឹងទាំងមូល។ នៅក្នុងប្រភេទទាំងបួននេះ គឺថាមានជំពូកពីរ។ ជំពូក “ក” គឺមានន័យថាកំហុសទាក់ទងទៅនឹងបណ្តឹងទាំងមូល ពាក់ព័ន្ធនឹងកំហុសដែលចៅក្រមស៊ើបអង្កេតបានប្រព្រឹត្ត ហើយជំពូកទីពីរហ្នឹងគឺប្រភេទបី និងបួន ដែលទាក់ទងទៅនឹងការបកស្រាយខុសចំពោះដីការដំណោះស្រាយ ហើយនិងសេចក្តីសម្រេចបំបែកកិច្ចនីតិវិធីខ្លួនឯង។ ហើយខ្ញុំក៏បានលើកឡើងផងដែរអំពីចិរវេលា ចង់និយាយថាការតវ៉ានោះលើកឡើងនៅពេលណា។ ខ្ញុំនិយាយថា បើនៅក្នុងពិភពមួយដែលអ្វីទាំងអស់ដូចយើងធម្មតា ហើយវិធានផ្ទៃក្នុងនុំង

វាត្រឹមត្រូវនោះ គឺយើងគួរតែអាចលើកឡើងអំពីជំពូក“ក”ហ្នឹង គឺកំហុសរបស់ចៅក្រមស៊ើបអង្កេតមុនពេលបើកសវនាការជំនុំជម្រះ។ យើងនិយាយថា បញ្ហានេះជាបញ្ហាសំខាន់ណាស់ ពីព្រោះថាអង្គជំនុំជម្រះបានសម្រេចថាមិនទទួលយកការតវ៉ារបស់យើង ដោយសារតែយើងតវ៉ាយឺតយ៉ាវ ហើយអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលជាមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់យើង។

[១៥:១៧:១១]

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបដ៏វែងលើចំណុចនេះ ហើយអស់លោក លោកស្រី ចៅក្រម ក៏បានលើកឡើង ដាក់សំណួរមួយក្នុងចំណុចដែរ ដែលនេះវាបញ្ជាក់ថា ចំណុចនេះមានសារៈសំខាន់ណាស់។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីចំណុចនេះទាំងអស់នេះឡើងវិញ ទាក់ទងនឹងការតវ៉ាក្នុងជំពូក “ខ” ដែលកំហុសដែលអង្គជំនុំជម្រះបានប្រព្រឹត្តដែលត្រូវលើកឡើងនៅក្នុងពេលជំនុំជម្រះ ហើយឥឡូវនេះខ្ញុំនឹងចាប់ផ្តើមនិយាយអំពីកំហុសដែលប្រព្រឹត្តឡើងដោយចៅក្រមស៊ើបអង្កេតដែលធ្វើឲ្យមានវិការៈដល់ដីកាដំណោះស្រាយ។ ខ្ញុំបានពន្យល់អម្បាញ់មិញនេះ ថាខ្ញុំនឹងឆ្លើយទៅនឹង -- ថាយើងអត់បានលើកឡើងអំពីការតវ៉ាចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គបុរេជំនុំជម្រះនោះ ហើយនិងឆ្លើយទៅនឹងសំណួរអស់លោក លោកស្រី ចៅក្រម នៅទីនេះ គឺយើងចែកជាពីរផ្នែក គឺទីមួយត្រូវដឹងថា ដឹងថាតើយោងជាក់លាក់ហ្នឹងពាក់ព័ន្ធនឹងពេលវេលា ថាហេតុអីបានយើងលើកពីការតវ៉ានេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងអង្គបុរេជំនុំជម្រះ? ហើយបន្ទាប់មកទៀត អស់លោក លោកស្រី ចៅក្រម សួរថាផ្តល់យោងឲ្យជាក់លាក់ថាតើយើងបានលើកឡើងអំពីការតវ៉ានេះនៅក្នុងដំណាក់កាលស៊ើបអង្កេតហ្នឹងនៅពេលណាដែរ ក្នុងដំណាក់កាលស៊ើបអង្កេត? ទាក់ទងទៅនឹងផ្នែកសំណួរទីពីរ នៃសំណួររបស់លោកលោកស្រីចៅក្រមនោះ ខ្ញុំបានលើកឡើអម្បាញ់មិញនេះថា យើងមិនដឹងថាអស់លោក លោកស្រីសំដៅទៅលើផ្នែកណានៃបណ្តឹងសាទុក្ខរបស់យើងទេ។ ខ្ញុំពិបាកនឹងទាយដែរ។ ក៏ប៉ុន្តែយើងគិតថាប្រហែលជាយើងមិនយល់គ្នា ឬក៏មានការភាន់ច្រឡំ ព្រោះថាយើងមិនដែលបានលើកឡើងអំពីចំណុចនេះនៅក្នុងដំណាក់កាលស៊ើបអង្កេតនោះទេ។ ដើម្បីត្រឡប់មកផ្នែកទីមួយ នៃសំណួររបស់លោក លោកស្រីចៅក្រម ថាតើហេតុអ្វីក៏យើងមិនបានលើកឡើងពីការតវ៉ានេះនៅចំពោះមុខចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះ? យើងបានឆ្លើយតបថា ខ្ញុំបញ្ជាក់ថាយើងនឹងឆ្លើយតបតែផ្នែកច្បាប់ទេ ព្រោះថាសហភាតារបស់ខ្ញុំ លោក គង់ សំអុន ហ្នឹងគឺយើងមកចូលមកទីនេះគឺគាត់មកដល់ឆ្នាំ -- គាត់មកដល់ក្នុងសំណុំរឿងនេះចុងឆ្នាំ២០១១ ហើយខ្ញុំដើមឆ្នាំ២០១២ គឺថាយើងមិនអាចឆ្លើយតបទៅនឹង ទៅសំណួរ

ទាំងអស់នេះជំនួសមេធាវីដែលធ្វើការយើងមុនទេ ក៏ប៉ុន្តែយើងអាចឆ្លើយជាលក្ខណៈរួមបាន ដើម្បីមេធាវីការពារក្តីបានដោយផ្អែកទៅលើអត្ថបទច្បាប់ ផ្អែកទៅលើច្បាប់ គឺយើងអាចសង្កេតឃើញថា វាមានដែនកំណត់ជាសត្យានុម័ត ដែលថាការប្រព្រឹត្តទាំងអស់នេះវាហួសពីករណីសំណុំរឿងលោក ខៀវ សំផន។

[១៥:២០:២៦]

នៅក្នុងការតវ៉ារបស់ជនជាប់ចោទនៅដំណាក់កាលស៊ើបអង្កេតនេះ គឺមានលក្ខណៈស្មុគស្មាញហើយនិងមិនអាចធ្វើបាន។ ខ្ញុំបានលើកឡើងពីវិធានផ្ទៃក្នុងផងដែរ គឺ៧៤ហ្នឹង គឺដែលនិយាយអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ហើយវិធាន៧៤ នេះគឺមិនឲ្យមានឧបាស្រ័យអ្វីប្រឆាំងនឹងសេចក្តីសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ពាក់ព័ន្ធនឹងសំណុំរឿងទាំងមូល បណ្តឹងទាំងមូលទេ ហើយទាក់ទងនឹងវិធានផ្ទៃក្នុងដែលនិយាយអំពីការដាក់អញ្ញត្រកម្មចំពោះមុខសាលាដំបូងនោះ គឺថានៅពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរហើយមិនអាចឲ្យលើកពីអញ្ញត្រកម្មនេះបានទេ។ ឥឡូវនេះខ្ញុំចូលមកដល់ចំណុច--

**លោកស្រី ហេឡេន វើសនុប៖**

លោកប្រធានសូមអន្តរាគមន៍ម្តងទៀត គឺថា បាត់ការបកប្រែជាភាសាអង់គ្លេសនៅក្នុងបន្ទប់ដែលយើងខ្ញុំនេះតែម្តង អត់មានស្តាប់ឮទេ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ខ្ញុំគឺថាស្តាប់ឮតែបារាំង។

**លោកស្រី ហេឡេន វើសនុប៖**

លោកប្រធានស្តាប់ឮឡើងវិញហើយ សូមអរគុណ។

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំឆ្ងល់ដែរ ដល់ពេលខ្ញុំនិយាយបានច្រើនហើយជិតចប់ហើយ បានលើកថាមានបញ្ហាខ្ញុំដូចជាលែងមានកម្លាំងនឹងលើកឡើងទៀតហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីសូមអញ្ជើញដោយសារសហព្រះរាជអាជ្ញាទេ គឺជាកំហុសរបស់បច្ចេកទេស។ ដូច្នេះហើយគឺអាចបន្ទោសអ្នកណាបានទេ។ អ៊ីចឹងហើយខ្ញុំគ្រាន់តែសុំឲ្យលោកស្រីមេធាវីការពារក្តីហ្នឹង

លើកចាប់ពីកន្លែងវិធាន៧៤ មកម្ដងទៀត។ បាទ ចាប់ពីត្រង់ហ្នឹងមក។

[១៥:២២:៥៧]

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន អម្បាញ់មិញនេះខ្ញុំនិយាយថា គឺថាមានបញ្ហាចម្បងមួយនៅក្នុងវិធានផ្ទៃក្នុងនៃអ.វ.ត.ក យើងនេះគឺដែលវាៗហួសពីសំណុំរឿងរបស់ ខៀវ សំផន នោះគឺដោយសារវិធាន៧៤នេះដែលនិយាយអំពីដីកាដំណោះស្រាយនេះ គឺថាយើងអត់អាចធ្វើបណ្ដឹងឧទ្ធរណ៍បានទេនៅពេលដែលគេបញ្ជូនរឿងទៅជំនុំជម្រះ ហើយវិធាន៨៩ នៃវិធានផ្ទៃក្នុងនោះដែលនិយាយអំពីការដាក់អញ្ញត្រកម្មនៅចំពោះមុខសាលាដំបូងនោះ កាលណាដីកា -- នៅពេលដែលសាលាដំបូងបានទទួលដីកាដំណោះស្រាយនេះហើយ ចូលជាស្ថាពរហើយ គឺក៏មិនអាចឲ្យលើកអញ្ញត្រកម្មបានដែរ។ ខ្ញុំនិយាយពីចំណុចនូវវិធានទាំងពីរនេះ ក៏ប៉ុន្តែខ្ញុំសូមលើកជាបឋមដែរ គឺថាអង្គជំនុំជម្រះបានប្រើប្រាស់វិធាន៨៩នេះ ដើម្បីសម្រេចថា ការតវ៉ារបស់យើងហ្នឹងមិនអាចទទួលយកបានទេ។ អ៊ីចឹងហើយនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់យើងហ្នឹង គឺយើងបានលើកឡើងតែអំពីវិធាន៨៩ នេះទេ ដោយសារតែអង្គជំនុំជម្រះហ្នឹងគាត់ផ្អែកលើវិធានហ្នឹងដើម្បីមិនទទួលយកការតវ៉ារបស់យើង។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីគាត់ឆ្លើយតបទៅនឹងសារណារបស់យើងហ្នឹង គឺនៅក្នុងកថាខណ្ឌ១៤០, ១៤២ ហ្នឹង គាត់និយាយថា "យើងបានខកខានមិនបាននិយាយអំពីវិធាន៧៤" យើងមិនភ្លេចទេដោយសារតែអង្គជំនុំជម្រះមិនបានប្រើវិធាននេះ។ អ៊ីចឹងឥឡូវថ្ងៃនេះខ្ញុំនឹងនិយាយពីវិធាន៧៤នេះ។

ខ្ញុំរំឭកផងដែរថា នៅកថាខណ្ឌ៣០៤ យើងគឺថា កំហុសនេះគឺកំហុសអង្គច្បាប់មិនមែនជាកំហុសនៃការវាយតម្លៃនៅកថាខណ្ឌ១៣៧ និង ១៦០ នោះទេ។ នេះដែលនៅក្នុងសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើម្បីឆ្លើយតបឲ្យច្បាស់លាស់អំពីវិធាន៧៤(៣) ដែលថាមិនអនុញ្ញាតឲ្យប្ដឹងឧទ្ធរណ៍ទៅ -- ប្រឆាំងនឹងដីកាដំណោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះហ្នឹង។ នៅក្នុងវិធាន៧៤ ដែលមានចំណងជើងថា "សេចក្ដីសម្រេចដែលអាចប្ដឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ" ហើយបញ្ជីនេះត្រឹមមាននៅចំណុចទីបីនេះ គឺដីកា ឬក៏សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬជនជាប់ចោទហ្នឹងអាចប្ដឹងឧទ្ធរណ៍បាន។ មានចំណុច ប្រាំបួនចំណុច ហើយសេចក្ដីសម្រេចបញ្ជូនទៅជំនុំជម្រះហ្នឹងនោះវាអត់មាននៅក្នុងចំណោមប្រាំបួនចំណុចហ្នឹងទេ។ ហើយលទ្ធភាពតែមួយគត់ដែលអាចធ្វើបាននោះគឺដោយវិធាននោះ គឺថា អាចជំទាស់ទិដ្ឋភាពមួយចំនួននៃដីកាដំណោះស្រាយហ្នឹងឲ្យជាប់

មានទំនាក់ទំនងជាមួយនឹង -- ដែលពាក់ព័ន្ធទៅនឹងយុត្តាធិការ ឬក៏ការឃុំខ្លួន។ ដូចជាការឃុំខ្លួនបណ្តោះអាសន្ន ឬក៏ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការជាដើម។

[១៥:២៦:៤៣]

នៅកថាខណ្ឌ៧០ នៃសារណាសន្និដ្ឋានបញ្ចប់ការដេញដោលរបស់យើងនោះ គឺឯកសារ E467/6/4/1 កថាខណ្ឌ៧០ យើងមិនអាចប្តឹងឧទ្ធរណ៍ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ គឺថាយើងអត់មានសិទ្ធិធ្វើអ៊ីចឹងទេ។ យើងក៏បានរំឭកផងដែរនៅក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅឆ្នាំ២០១០នោះ សេចក្តីសម្រេចរបស់អង្គបុរេ ខ្ញុំយោងទៅនឹងសារណាសន្និដ្ឋានរបស់យើង គឺខ្ញុំសូមផ្តល់សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ខែឧសភា ឆ្នាំ២០១០ D97/14/15 ហើយ *(គ្មានការបកប្រែ)* អ៊ីចឹងយើងបានរំឭកពីសេចក្តីសម្រេចទាំងអស់នេះថា សេចក្តីសម្រេចថ្ងៃទី១០ ឧសភា ឆ្នាំ២០១០ ដែលមុនពេលដីកាដំណោះស្រាយចេញ ដែលនៅឆ្នាំ២០០០*(ស៊ីក)* ពេលក្រោយហ្នឹងនោះគឺថា អង្គបុរេជំនុំជម្រះថា មានតែការតវ៉ានិងយុត្តាធិការដែលអាចប្រើអនុវត្តវិធាន ៧៤(៣)(ក) បាន។

អ៊ីចឹងយើងស្ថិតនៅក្នុងប្រព័ន្ធមួយ តុលាការពិសេសគឺមិនមែនជាតុលាការស៊ីវិលឡនោះទេ។ អ៊ីចឹងគឺថាយើងមានការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ។ អង្គបុរេជំនុំជម្រះបានបញ្ជាក់នៅពេលក្រោយទៀតថា មធ្យោបាយ -- សម្អាងហេតុទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងយុត្តាធិការនេះគឺអាចដាក់ជូនទៅសាលាដំបូងបាន។ អង្គបុរេជំនុំជម្រះគឺថាយើងមិនអាចប្តឹងឧទ្ធរណ៍ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ គឺយើងអាចធ្វើបានតែទៅលើបញ្ហានីត្យានុកូលភាព ហើយមិនអាចប្តឹងឧទ្ធរណ៍ទាក់ទងនឹងបណ្តឹងទាំងមូលហ្នឹងបានទេ។

[១៥:២៩:៤៦]

អ្វីដែលសហព្រះរាជអាជ្ញាទទួលស្គាល់ដែរនោះ គឺភស្តុតាងដែលមានលើកឡើងនៅក្នុងវិធានផ្ទៃក្នុង ដែលនិយាយពីថាសំណើសុំឲ្យធ្វើមោឃភាពទៅលើកិច្ចស៊ើបអង្កេត។ គាត់និយាយពីចំណុចនេះនៅក្នុងចម្លើយរបស់គាត់ ហើយគាត់ទទួលស្គាល់ផងដែរថា វិធាននេះអាចអនុវត្តបានតែមុនពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ហើយមិនអាចអនុវត្តទៅលើដីកាបញ្ជូនទៅជំនុំជម្រះទេ គឺអនុវត្តបានតែលើវិការៈនៃដីកានេះនោះទេ ហើយដើមបណ្តឹងរដ្ឋប្បវេណីវិញ នៅកថាខណ្ឌ១២៥ នៃសារណារបស់គាត់ហ្នឹង គាត់បានលើកឡើងខុសពីព្រះរាជអាជ្ញា គាត់និយាយថា បណ្តឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយ

នោះ អាចធ្វើទៅបាន។ ហើយដូច្នេះអំណះអំណាងរបស់យើងហ្នឹង ថាអាចទទួលយកបាន បើយើងផ្អែកលើមូលដ្ឋាននេះ។ អានេះជាការលើកឡើងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។

[១៥:៣០:៥៥]

កាលនោះ ដើមបណ្ដឹងរដ្ឋប្បវេណីនេះ គាត់បានធ្វើការបកស្រាយវិធាន៧៦(៧) ដែលមិនមានពាក់ព័ន្ធទៅនឹងយុត្តិសាស្ត្រនៃ អ.វ.ត.ក យើងនេះទាល់តែសោះ។ វិធាន៧៦ និយាយអំពីវត្ថុតាងនៅក្នុងនីតិវិធី។ ខ្ញុំសូមត្រឡប់មកចំណុចនេះនិយាយអានពីកថាខណ្ឌនេះ ថាដីកាដំណោះស្រាយដែលចូលជាធរមានហើយ ប្រសិនបើធ្វើហើយ គឺមោឃភាពនីតិវិធីទាំងអស់ទាំងប៉ុន្មាននោះគឺត្រូវសម្អាត ហើយមិនអាចលើកឡើងពីចំណុចទាំងអស់នេះនៅចំពោះមុខសាលាដំបូង ឬក៏តុលាការកំពូលទេ។ ហើយយើងជាមេធាវីខាងច្បាប់បារាំងនេះ យើងស្គាល់ពីច្បាប់នេះ គឺវា -- ចុះបើកកាលណាបញ្ជូនរឿងទៅជំនុំជម្រះហើយ វាអ៊ីចឹងហើយ យើងយល់ ក៏ប៉ុន្តែវាមិនអាចសម្អាតវិការៈដោយខ្លួនឯងនោះទេ នៅពេលដែលដីកានោះត្រូវបានចេញហើយ ហើយបើចៅក្រមស៊ើបអង្កេតនោះធ្វើកំហុសនោះ ហើយម៉េចក៏ទៅឲ្យគាត់សម្អាតវិការៈខ្លួនឯងនោះបាន។

វិធាន៧៦ ចំណុច៧ នេះ មិនអាចឲ្យយើងប្ដឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយនេះបានទេ បើសិនជាយើងប្ដឹងបាននោះ យើងប្ដឹងទៅចំពោះមុខអង្គបុរេបាត់ទៅហើយ ប៉ុន្តែយើងធ្វើមិនបាន តែយើងធ្វើបានតែលើវិសាលភាពនៃបណ្ដឹងទាំងមូលតែប៉ុណ្ណោះ។ អ៊ីចឹងភាពចម្រូងចម្រាសរវាងវិធានទាំងពីរនេះ គឺថាធ្វើថាឲ្យជនជាប់ចោទហ្នឹងមានព្យសនកម្ម។ ខ្ញុំគិត -- ខ្ញុំសូមលើកវិធាននៅតុលាការអន្តរជាតិហ្នឹង ដែលមានលក្ខណៈដូចនឹងវិធានផ្ទៃក្នុងយើងហ្នឹងដែរ គឺឯកសារតុលាការពិសេសហ្នឹងមួយ ដែលៗនិយាយអំពីនីតិវិធី ហើយនិងពីភស្តុតាងនៅចំពោះតុលាការព្រហ្មទណ្ឌពិសេសមួយ ដែលជាតុលាការកូនកាត់ដែលក្របខណ្ឌនីតិវិធីហ្នឹងស្រដៀងនឹងតុលាការយើងហ្នឹង ដែលថាមានដំណាក់កាលស៊ើបអង្កេតដូចនៅ អ.វ.ត.ក យើងដែរ ដែលផ្អែកទៅលើច្បាប់ប្រព័ន្ធច្បាប់បារាំងហ្នឹង ដែលមាន ដែលតម្រូវឲ្យមានដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះវាជាតុលាការមួយដែលស្រដៀងនឹងតុលាការយើងនេះដែរ។

[១៥:៣៣:៥៩]

តុលាការពិសេសនេះគឺ បានចែងដូចនៅវិធាន៧៦ យើងដែរ គឺថា ការសម្អាតមោឃភាពនៃកិច្ចស៊ើបអង្កេតហ្នឹងគឺថា -- តែគ្រាន់តែខុសពី អ.វ.ត.ក យើងបន្តិច គឺជនជាប់ចោទអាចប្ដឹងឧទ្ធរណ៍បានទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អ៊ីចឹងវិធាន១០៧ នៃវិធាន៧ ហើយស្មើៗនឹងវិធាន៧៤ នៃ

តុលាការយើងនេះ ហើយដែលចែងពីសមត្ថកិច្ចតុលាការ ឬក៏លទ្ធភាពប្តឹងឧទ្ធរណ៍ជាដើម ហើយនិងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិង -- អ៊ីចឹងមានចំណុចដូចគ្នានឹងតុលាការយើង ក៏ប៉ុន្តែវាមានខុសមួយនៅចំណុច ចំណុចមួយនោះគឺថាមានលទ្ធភាពអាចប្តឹងឧទ្ធរណ៍បាន ប្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយហ្នឹងនៅសាលាវិនិច្ឆ័យបាន ដែលវាខុសពីអ.វ.ត.ក។ អ៊ីចឹងហើយបញ្ហារបស់យើងកន្លែងនេះ គឺថាជនជាប់ចោទអត់មាននីតិវិធីណាដែលធ្វើឲ្យគាត់អាចទៅប្តឹងឧទ្ធរណ៍បាននោះទេ។ អ៊ីចឹងបើសិនជាយើងមានលទ្ធភាពទៅតាមវិធាន៧៤ យើងហ្នឹង ដែលមានបទប្បញ្ញត្តិណាមួយស្មើនឹងបទប្បញ្ញត្តិដែលខ្ញុំបានលើកឡើងនៅតុលាការអន្តរជាតិនោះ តុលាការពិសេសហ្នឹង យើងប្រហែលជាមិនស្ថិតនៅក្នុងស្ថានភាពសព្វថ្ងៃនេះទេ។ វិធាន៧៤ យើងនេះ មិនអាចឲ្យយើងប្តឹងឧទ្ធរណ៍បានទេ ហើយក៏មិនអាចឲ្យ -- ហើយអាចឲ្យយើងប្តឹងឧទ្ធរណ៍នោះទៅទាក់ទងទៅនឹងយុត្តាធិការនៃ អ.វ.ត.ក នេះទេ។

[១៥:៣៦:១៥]

ខ្ញុំនិយាយដូចជាយុត្តាធិការលើបុគ្គល -- ដូចកាលនោះខាង អៀង សារី ហ្នឹងក៏បានលើកឡើងអំពីបញ្ហាការលើកលែងទោស ដែល អៀង សារី ហ្នឹងបានទទួល។ នេះ -- ហើយយុត្តាធិការវិធាន៧៤នេះ ហើយនិងវិធាន៨៩នោះ ដែលអ៊ីចឹងហើយបានថាយើងៗមិនអាចលើកឡើងការតវ៉ារបស់យើងនៅពេលនោះ។

វិធាន៨៩នោះ មិនអាចប៉ះប៉ូវទៅដល់វិធាន៧៤ និងអវត្តមាននៃបទប្បញ្ញត្តិដើម្បីឲ្យយើងអាចប្តឹងឧទ្ធរណ៍ទៅដីកាបញ្ជូនរឿងទៅជំនុំជម្រះបានទេ។ ប៉ុន្តែអង្គបុរេជំនុំជម្រះហ្នឹង គាត់បកស្រាយខុសគេបកស្រាយថា អំណះអំណាងរបស់យើងមិនអាចទទួលយកបាន ហើយអាហ្នឹងហើយជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់យើង។ ក៏ប៉ុន្តែច្បាស់លាស់ណាស់ គឺថាយុត្តាធិការដែលចែងនៅវិធាន៨៩ នោះគឺវាដូចនឹង៧៤ដែរ ហើយដូចដែលមាននៅក្នុងវិធាន៩៨ នៅក្នុងសាលក្រមហ្នឹងក៏ដូចគ្នាដែរ ហើយយើងបានលើកឡើងពីចំណុចនេះយ៉ាងច្បាស់នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងនៅកថាខណ្ឌ៣៣៧។

[១៥:៣៨:១០]

ដូចគ្នាដែរនៅតុលាការពិសេសហ្នឹង មានចំណុចដូចគ្នាដែរ គឺគាត់និយាយអំពី -- គឺមាននៅក្នុងមាត្រា១០៧ ហើយនិង ១១៣ នៃវិធានអំពីនីតិវិធី ហើយនិងភស្តុតាងហ្នឹង នៅពេលដែលយើងអានមាត្រានេះ មាត្រា១១៣នេះ យើងឃើញថា មាត្រានេះនិយាយអំពីបណ្តឹងឧទ្ធរណ៍ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបអង្កេត ហើយនិងរបស់តុលាការអង្គបុរេជាដើម។ ហើយយុត្តាធិការ

នេះវាមិនពាក់ព័ន្ធទៅនឹងបណ្តឹងទាំងមូលនៃរឿងក្តីនោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាច ថាយើងធ្វើអញ្ញត្រកម្មយឺតយ៉ាវនោះទេ ហើយធ្វើបែបនេះគឺប្រព្រឹត្តកំហុសអង្គច្បាប់។

អ្វីដែលយើងលើកឡើងនេះ គឺជាវិការៈនៃដីកាដំណោះស្រាយ ហើយៗអត់មានអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះណាមួយដោះស្រាយបញ្ហានេះទេ ហើយនៅក្នុង -- បើសិនជាអត់មានអ៊ីចឹងសាលាដំបូងគួរតែដោះស្រាយបញ្ហានេះនៅពេលជំនុំជម្រះលើអង្គសេចក្តី ហើយខ្ញុំសុំយោងទៅលើសារណាបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំ។

[១៥:៣៩:៤៥]

ខ្ញុំសង្កត់លើចំណុចនេះ គឺថាការពិនិត្យនេះវាសំខាន់ណាស់ទាក់ទងទៅនឹងយុត្តិធម៌នៃនីតិវិធី បើយើងថា ការជំទាស់យើងហ្នឹងវាយឺត តវ៉ារបស់យើងយឺតក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះត្រូវតែពិនិត្យយ៉ាងហោចណាស់ក៏ជាអប្បបរមាដែរលើការតវ៉ារបស់យើងនេះ។ ហើយយុត្តិសាស្ត្រដែលលើកឡើងដោយព្រះរាជអាជ្ញានោះ គឺគាំទ្រទស្សនៈរបស់យើងទៅវិញទេ។ ព្រះរាជអាជ្ញានោះទាក់ទងទៅនឹងសាលដីកាសំណុំរឿង ឌុច ចេញនៅឆ្នាំ២០១២នោះ នៅកថាខណ្ឌ២៦៨ហ្នឹង គឺព្រះរាជអាជ្ញាបាននិយាយថាគាត់បែងចែកពីរប្រភេទ តវ៉ាលើយុត្តាធិការពីរខុសគ្នា។ គឺទីមួយ គឺការយល់ច្រឡំពីវិធានលើសវនាការអង្គសេចក្តី ហើយនិងការយល់ច្រឡំពីវិធាននីតិវិធី។

អំមិញហ្នឹងខ្ញុំឃើញខាងព្រះរាជអាជ្ញាគេងើបឡើង អ៊ីចឹងខ្ញុំដឹងថាខ្ញុំអត់បានស្តាប់គាត់និយាយម៉េចក៏មិនដឹងទេ។

**លោកស្រី ហេឡេន វើសនុប៖**

សុំទោសដែលខ្ញុំកាត់។ ប៉ុន្តែខ្ញុំស្តាប់សំណួររបស់គាត់អត់ច្បាស់។ ខ្ញុំបើកមីក្រូហ្វូនហើយតើ! ស្តាប់ខ្ញុំអត់លឺហី?

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំស្តាប់ព្រះរាជអាជ្ញាលឺច្បាស់ណាស់ អំមិញហ្នឹងខ្ញុំឃើញគាត់ងើបឡើង ខ្ញុំមិនដឹងថា ងើបឡើងដោយមានមូលហេតុអី ឬក៏មានបញ្ហាបច្ចេកទេសអីថ្មីទៀតទេ? ប្រសិនបើអត់មានបញ្ហាអីទេ ខ្ញុំនឹងបន្តទៀត។

**លោកស្រី ហេឡេន វើសនុប៖**

សុំទោស យើងមានបញ្ហាបកប្រែបន្តិច។ ប៉ុន្តែដូចជាអត់អីទេឥឡូវ សុំទោសផងដែលខ្ញុំរំខាន។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

សុំទោស ខ្ញុំសូមនិយាយបន្តិច។ យើងប្រហែលជាគួរតែមានការវិធានការណាមួយទាក់ទងនឹងការបកប្រែ។ ខ្ញុំគិតថាប្រសិនបើយើងគិតពីតួនាទីជាមូលដ្ឋាន ថាតើយើងគួរដោះស្រាយយ៉ាងដូចម្តេច?

[១៥:៤២:៤៥]

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំនឹងត្រឡប់ក្រោយវិញបន្តិច។

អម្បាញ់មិញហ្នឹងខ្ញុំនិយាយថា មានយុត្តាធិការពីរទាក់ទងនឹងវិធាន៧៤នោះ វាអត់ទាក់ទងនឹងបណ្តឹងទាំងមូលនោះទេ។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី វាជាចំណុចដែលអង្គជំនុំជម្រះហ្នឹង គួរតែពិនិត្យអាហ្នឹងឡើង ដើម្បីឲ្យមានភាពយុត្តិធម៌ផ្នែកនីតិវិធី។ ខ្ញុំយោងទៅនឹងកថាខណ្ឌ៣៤៧ នៃសារណារបស់យើងហ្នឹង។ ហើយខ្ញុំក៏និយាយផងដែរថា សាលដីកាក្នុងសំណុំរឿង០០១ គឺសំណុំរឿង ឌុច ហ្នឹងដែលព្រះរាជអាជ្ញាបានដកស្រង់ឡើងហ្នឹង គាត់បែងចែកពីយុត្តាធិការពីរប្រភេទ។ ទីមួយ គឺថាយុត្តាធិការដោយសារតែយល់ច្រឡំពីវិធានលើអង្គសេចក្តី ហើយនិងមួយទៀតការយល់ច្រឡំអំពីវិធានការស្តីពីនីតិវិធី។ ព្រះរាជអាជ្ញាបានផ្អែកអំណះអំណាងរបស់ខ្លួនទៅលើការដែលថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចក្នុងសំណុំរឿង០០១ ដើម្បីវាយតម្លៃទៅលើភាពទទួលយកបាននៃអញ្ញត្រកម្ម ដែលលើកឡើងអំពីចំណុចទាំងពីរនេះ ហើយសហព្រះរាជអាជ្ញា កថាខណ្ឌ២៦៩ និង២៧០ហ្នឹង ចម្លើយរបស់គាត់ហ្នឹងគាត់លើកឡើងថា វិធានទី១ហ្នឹង វិធានទាំងអង្គសេចក្តីហ្នឹង គឺអាចលើកឡើងពេលណាក៏បានដែរ ក៏ប៉ុន្តែវិធានទាក់ទងទៅនឹងនីតិវិធីហ្នឹង គឺអាចដកហូតសិទ្ធិភាគីមិនឲ្យធ្វើយ៉ាងដូច្នេះ។ ហើយព្រះរាជអាជ្ញាក៏លើកឡើងផងដែរថាយើង បញ្ហាយើងនៅទីនេះគឺយើងស្ថិតនៅក្នុងវិធានការទី២ទេ គឺវិធានទាក់ទងនឹងនីតិវិធី ក៏ប៉ុន្តែទន្ទឹមហ្នឹងនោះព្រះរាជអាជ្ញាបានលើកឡើងថា អង្គបុរេជំនុំជម្រះចាត់ទុកថា ការតវ៉ារបស់យើងហ្នឹងមិនពាក់ព័ន្ធទៅនឹងអញ្ញត្រកម្មលើយុត្តាធិការទេ។ ហើយគាត់លើកឡើងចំណុចនេះ គឺនៅ F54/1 កថាខណ្ឌ២៧២។ ទោះបីជាអង្គជំនុំជម្រះនិយាយផ្ទុយពីនេះហើយ ក៏គាត់នៅតែលើកឡើងថាការតវ៉ារបស់យើងនេះគឺជាអញ្ញត្រកម្មពាក់ព័ន្ធទៅនឹងយុត្តាធិការ។

[១៥:៤៥:៤២]

ហើយនៅក្នុងឯកសារយោងក្នុងឯកសារ F54/1 កថាខណ្ឌ២៧១, ២៧៧ មូលហេតុដែលព្រះរាជអាជ្ញាថា ការតវ៉ារបស់យើងហ្នឹងមិនពាក់ព័ន្ធទៅនឹងយុត្តាធិការនៃ អ.វ.ត.ក នោះ គឺប៉ុន្តែទាក់ទងទៅ

នឹងបណ្តឹងទាំងមូលតែម្តងនោះ ហើយទាក់ទងទៅនឹងវិការៈនៃដីកាដំណោះស្រាយ។ ខ្ញុំគិតថាគាត់អះអាងដូច្នេះគឺវាស្រួលណាស់ ពីព្រោះធ្វើអ៊ីចឹងទៅគឺយើងអាចត្រូវបានដកហូតសិទ្ធិមិនឲ្យប្តឹងឧទ្ធរណ៍។ វាមិនមែនជាបញ្ហាយុត្តាធិការលើបុគ្គលអីនោះ អ៊ីចឹងគាត់លើកអ៊ីចឹងឡើងហ្នឹង វាជួយសម្រួលដល់កិច្ចការងារគាត់ ពីព្រោះវាពាក់ព័ន្ធតែអង្គហេតុ។ ក៏ប៉ុន្តែគាត់ -- ការលើកឡើងរបស់ព្រះរាជអាជ្ញានេះ គឺខុសទាំងស្រុង។ តាមពិតទៅគឺថា វាពាក់ព័ន្ធទៅនឹងវិធានលើអង្គសេចក្តីទៅវិញទេ។ តាមពិតទៅ ត្រូវអានយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះពីមុនមក គឺថាមិនអាចមកចាត់ទុកថាជាការយល់ច្រឡំលើវិធាននីតិវិធីទេ គឺវាពាក់ព័ន្ធនឹងវិធានលើអង្គសេចក្តី។ ឧទាហរណ៍ ដូចនៅក្នុងសាលដីការបស់សំណុំរឿង ឌុច នេះជាដើម គឺឯកសារ F28 កថាខណ្ឌ២៨ ទៅដល់ ៣៧។ នៅក្នុងសេចក្តីសម្រេចរបស់អស់លោក លោកស្រីចៅក្រម នៅកំណត់ត្រាជើងទំព័រ នៅក្នុង៧៨ហ្នឹង គឺថាយល់ច្រឡំលើវិធាននីតិវិធីដែលមិនបានជូនដំណឹងទៅដល់ជនជាប់ចោទនោះ គឺត្រូវចាត់ទុកថាជាមោឃៈ។

[១៥:៤៧:៥៥]

ផ្ទុយមកវិញ ឧបមារថា ការយល់ច្រឡំលើវិធានទៅលើអង្គសេចក្តីនេះ គឺថាវាអាចឧទាហរណ៍ដូចជាករណីលើក -- ធ្លាប់បានទទួលការលើកលែងទោសនោះគឺវាត្រូវតែរលត់អាជ្ញាយុកាល គឺបានន័យថាបញ្ចប់រាល់ការចោទប្រកាន់ ហើយនិងកម្ទេចនូវមូលដ្ឋានគតិយុត្តក្នុងការផ្តន្ទាទោស ហើយ -- ដូច្នេះវាគឺជាកំហុសខុសច្បាប់ គឺអង្គសេចក្តី មិនមែនជាកំហុសនីតិវិធីនោះទេ។ ដូច្នេះយើងនៅក្នុងលក្ខខណ្ឌ -- វិធានលើអង្គសេចក្តី។ អ៊ីចឹងបានន័យថា វារំលត់អាជ្ញាយុកាល គឺបញ្ចប់រាល់ការចោទប្រកាន់ទាំងអស់។ អង្គជំនុំជម្រះអាចពិនិត្យវិការៈទាំងអស់នេះដោយខ្លួនឯង ដោយឥស្សរៈចិត្តតែម្តង។ ទោះបីយើងនិយាយថាយើងលើកឡើងយឺតហ្នឹង គឺមិនមែនបានន័យថា អង្គជំនុំជម្រះហ្នឹងមានយុត្តាធិការនិយាយនោះទេ គឺធ្វើអ៊ីចឹង គឺធ្វើឲ្យខ្លួនឯងហ្នឹងខូចឈ្មោះទៅវិញទេ។ បើសិនជាយើងមានសិទ្ធិប្តឹងឧទ្ធរណ៍នោះ ប្រហែលជាការចោទប្រកាន់ទាំងអស់នោះត្រូវចាត់ទុកជាមោឃៈបាត់ទៅហើយ។ ការបកស្រាយភាន់ច្រឡំលើវិធាន៨៩ដោយព្រះរាជអាជ្ញា ព្រះរាជអាជ្ញាបានធ្វើការបកស្រាយខុសទាំងស្រុងនូវវិធាន៨៩នោះ។ ខ្ញុំសូមដកស្រង់នូវកថាខណ្ឌរបស់គាត់។

[១៥:៤៩:៥៩]

គាត់និយាយពីក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក ហើយអះអាងថា បើសិនជាអង្គបុរេជំនុំជម្រះកំណត់មូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលជនជាប់ចោទអាចប្រើប្រាស់ដើម្បីជំទាស់នឹងដីកាដំណោះស្រាយនៅចំពោះ

មុខសាលាដំបូងនោះ ក៏ទោះជាយ៉ាងណាក្តីក៏ដីកាដំណោះស្រាយនោះត្រូវតែចូលជាស្ថាពរបាត់ទៅហើយ -- ផងដែរ។ អ៊ីចឹងៗ យើងឆ្លើយតបទៅគាត់វិញថា ក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក មិនចែងអំពីលទ្ធភាពនៃការប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយនោះទេ ហើយការដែលអង្គបុរេជំនុំជម្រះគាំទ្រចំណុចនេះហ្នឹង គឺវិធាន៨៩ ចែងថា អង្គជំនុំជម្រះចេញសេចក្តីសម្រេចលើអញ្ញត្រកម្មជូនភ្លាមៗ ហើយនិងជូនក្នុងពេលជាមួយគ្នានឹងការចេញសាលក្រមលើអង្គសេចក្តី។ ហើយនៅចំពោះតុលាការកំពូលវិញ គឺវិធាន៨៩(១) គឺបានន័យថាមានការអនុវត្ត-- *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អ្នកបកប្រែអត់បានបកប្រែទេ។

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកប្រធានខ្ញុំនឹងនិយាយត្រឡប់ក្រោយបន្តិច។ ខ្ញុំនិយាយថា ក្របខ័ណ្ឌ អ.វ.ត.ក មិនបានចែងអំពីការប្តឹងលើដីកាដំណោះស្រាយនោះទេ ហើយវិធាន៨៨ បានចែងថាអញ្ញត្រកម្មគឺអង្គជំនុំជម្រះចេញសេចក្តីសម្រេចនៅលើអញ្ញត្រកម្មគឺភ្លាមៗ ឬក៏ក្នុងពេលជាមួយនឹងសាលក្រមលើអង្គសេចក្តីគឺវិធាន៨៩(៣)។ ហើយបើតាមតុលាការកំពូលវិធាន៨៩(១)(ក)ហ្នឹង គឺវាមានបញ្ជាក់អំពីការអនុវត្តមានកម្រិត។ ខ្ញុំសុំដកស្រង់នូវអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើង គឺជនជាប់ចោទមានសិទ្ធិបង្ហាញគ្រប់ពេលទាំងអស់នៅពេលដែលខ្លួនយល់ឃើញថា សមស្របសម្រាប់ការការពារផលប្រយោជន៍របស់ខ្លួន និងអញ្ញត្រកម្មអសមត្ថកិច្ច ដែលវាអាចនឹងបញ្ចប់នូវការចោទប្រកាន់។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនិយាយថា យើងបានលើកឡើងយឺតពេល គឺក្នុងនេះគឺបញ្ជាក់ហើយថា គ្រប់ពេលទាំងអស់។

ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងក្របខណ្ឌស្ថាពរនៃការជំនុំជម្រះនោះគឺថាវាមានការប្រែប្រួលនៅក្នុងសំណុំរឿង០០២/០១ នោះគឺថា យើងមានការប្រែប្រួលណា ក្របខ័ណ្ឌនេះគឺថា ផ្លាស់ប្តូររហូត ដូចជាយើងមានបញ្ហានៃការបំបែកកិច្ចនីតិវិធី គឺមុនពេលបិទសវនាការលើអង្គសេចក្តីហ្នឹងទៀតនោះ។ អ៊ីចឹងខ្ញុំសូមលើកឡើងនូវសេចក្តីសម្រេចរបស់តុលាការកំពូលគឺ E301/9/1/1/3 កថាខណ្ឌ៧៤។ នេះជាទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា។ គឺថាវាមិនពាក់ព័ន្ធនឹងអ្វីដែលបានសម្រេចដោយតុលាការកំពូលនោះទេ។

[១៥:៥៤:០៨]

ខ្ញុំសូមរំឭកនូវសេចក្តីសម្រេចមួយទៀតរបស់តុលាការកំពូលក្រោយពីមានបណ្តឹងសាទុក្ខរបស់លោក អៀង សារី នៅក្នុងសំណុំរឿង០០២/០១ គឺសេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ E95/8/1/4កថាខណ្ឌ១០។ តុលាការកំពូលបានប្រកាសមិនទទួលយកនូវបណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តី អៀង សារី ប្រឆាំងទៅនឹងសេចក្តីរបស់សាលាដំបូងដែលប្រកាសអំពីថានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ១៩៧៥ហ្នឹង មិនតម្រូវឲ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះទេ។ ហើយនៅក្នុងកថាខណ្ឌ១០ តុលាការកំពូលបានបញ្ជាក់ថា សាលាដំបូងគឺមិនត្រូវបានចងកាតព្វកិច្ចដោយការកំណត់បទល្មើសនៃអង្គហេតុ ដែលសម្រេចដោយអង្គបុរេជំនុំជម្រះនោះទេ ហើយកម្រិតនៃភាពមិនច្បាស់លាស់នៃបទចោទហ្នឹងគឺវាមិនមានបញ្ហាអ្វីនោះទេ។

[១៥:៥៥:២៣]

បន្ទាប់មកទៀតសហព្រះរាជអាជ្ញា គឺបានលើកឡើងអំពីយុត្តិសាស្ត្រជាតិ ដើម្បីបញ្ជាក់ថាមានលទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយ។ ខ្ញុំអាចលើកឡើងនូវច្បាប់បារាំងផងដែរ ពាក់ព័ន្ធទៅនឹងចំណុចនេះ។ ហើយប្រសិនបើមានបញ្ហាបច្ចេកទេសអីសូមលោកប្រធានអធ្យាស្រ័យផង ខ្ញុំបញ្ចប់ការអន្តរាគមន៍របស់ខ្ញុំ។ បរិបទនៃច្បាប់វាខុសគ្នា ពីព្រោះថានៅក្នុងបទឧក្រិដ្ឋហ្នឹងគឺថា គេអាចធ្វើប្តឹងឧទ្ធរណ៍ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន។ ដូច្នេះក្នុងករណីដែលខ្ញុំលើកឡើងហ្នឹងគឺវាពាក់ព័ន្ធទៅនឹងរឿងនៅក្នុងបទបស្ទឹម អ៊ីចឹងករណីនេះវាខុសគ្នាពីបទឧក្រិដ្ឋ។ នៅក្នុងបទបស្ទិមគឺថា ទោះបីជាមិនមានលទ្ធភាពប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឬបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏យើងមានលទ្ធភាពក្នុងការកត់សម្គាល់អំពីលទ្ធភាពនៃអញ្ញត្រកម្ម។ ក្នុងពេលនោះដែរសហព្រះរាជអាជ្ញាគាត់បានលើកឡើងអំពីសាលដីការបស់តុលាការកំពូលដែលបានបញ្ជាក់អំពីលទ្ធភាពរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងការកត់សម្គាល់អំពីលទ្ធភាពនៃការប្តឹងឧទ្ធរណ៍បាន។

ដូច្នេះ វាៗមិនមានលទ្ធភាពអីដែលថាដាច់ខាតនោះទេ។ ហើយសហព្រះរាជអាជ្ញាហ្នឹងក៏មិនបានឆ្លើយតបនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរនៅក្នុងសវនាការ។ ជាពិសេស គឺមិនបានឆ្លើយតបទៅនឹងសារណារបស់ភាគីទេ។

[១៥:៥៧:៤៩]

ឥឡូវហ្នឹងខ្ញុំសូមនិយាយអំពីប្រភេទផ្សេងៗពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលហួសវិសាលភាពបណ្តឹង អង្គហេតុប្រភេទពីរ គឺបទចោទមិនគ្រប់គ្រាន់ និងប្រភេទទីបី គឺអង្គហេតុដែលមិនត្រូវបានប្រើ

ប្រាស់នៅក្នុងការកំណត់ប្រភេទបទល្មើស ប្រភេទទីបួន គឺអង្គហេតុដែលបានដកចេញដោយដីកាបំបែកនីតិវិធីនៅក្នុងសំណុំរឿង០០២។ ហើយខ្ញុំសូមឆ្លើយតបភ្លាមៗទៅនឹងសំណួរ -- ខ្ញុំនឹងឆ្លើយតបទៅនឹងសំណួររបស់តុលាការកំពូលពាក់ព័ន្ធទៅនឹងអង្គហេតុដែលយើងយល់ថា វាមិនបង្កើតបានទៅជាបន្ទុកបទចោទគ្រប់គ្រាន់។ ខ្ញុំនឹងសង្ខេបនូវក្នុងដីកាដំណោះស្រាយ និងក៏ដូចជាសារណាបណ្តឹងសាទុក្ខរបស់យើង ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍របស់ចៅក្រម។

នៅក្នុងសារណារបស់យើងហ្នឹងគឺ កថាខណ្ឌ៤៣៩ ដល់ ៤៥៧ ដែលយោងទៅលើសារណាចុងក្រោយរបស់យើងហ្នឹងគឺៗសុទ្ធតែជាអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ D427 ហើយក៏នៅក្នុងសម្អាងហេតុនៃសាលក្រមដែលនៅក្នុងកថាខណ្ឌ១១៤២ ដល់ ១១៤៥ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តដោយរើសអើងចំពោះប្រជាជនថ្មីនៅត្រាំកក់ហ្នឹង គឺនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើង -- បណ្តឹងសាទុក្ខ (សូមទោស) គឺកថាខណ្ឌ៤៤៨ ដល់ ៤៥០ ដែលយោងទៅលើសារណាសន្និដ្ឋានស្ថាពររបស់យើង គឺកថាខណ្ឌ៩៤២ ដល់ ៩៤៨ ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយហ្នឹង គឺនិយាយនៅក្នុងកថាខណ្ឌ៣០៥ ហើយនៅក្នុងសម្អាងហេតុនៃសាលក្រមហ្នឹង គឺកថាខណ្ឌ១១៧៦ ទៅដល់ ១១៧៩។

[១៦:០០:០៦]

ចំពោះប្រភេទទីបី នៃអង្គហេតុដែលយើងយល់ឃើញថាបទចោទមិនគ្រប់គ្រាន់នោះ គឺពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ និងការបាត់បង់មន្ត្រីនៃសាធារណរដ្ឋខ្មែរ គឺសារណារបស់យើងកថាខណ្ឌ៤៥១ ដល់៤៥៦ ហើយក្នុងដីកាដំណោះស្រាយគឺកថាខណ្ឌ៣១៩, ៤៩៨ ហើយនៅក្នុងសម្អាងហេតុសាលក្រម E465 ហ្នឹងគឺមាននិយាយនៅក្នុងកថាខណ្ឌ១១៧៥, ១១៧៧ ដល់ ១១៧៩។

ខ្ញុំភ្លេចយោងមួយចំនួន ប្រសិនបើអង្គជំនុំជម្រះចង់បានឯកសារយោងបន្ថែមនោះ យើងអាចប្រាប់បាននៅពេលដែលយើងឆ្លើយនឹងសំណួរ។ ពាក់ព័ន្ធទៅនឹងអង្គហេតុជាក់លាក់ ពាក់ព័ន្ធទៅនឹងការអនុវត្តហួសពីវិសាលភាពនៃបណ្តឹងដោយសហចៅក្រមស៊ើបអង្កេត យើងដូចបានឃើញរួចមកហើយ គឺថាការជំទាស់របស់យើងហ្នឹងគឺអញ្ញត្រកម្មដែលវាយឺតពេល ខ្ញុំគិតថាវាមិនអ៊ីចឹងទេ ខ្ញុំសូមលើកឧទាហរណ៍ដើម្បីបញ្ជាក់ថា មានតែមួយទេ ដែលត្រូវបានពិនិត្យហ្នឹង គឺការជម្លៀសជនជាតិវៀតណាមហើយត្រូវបានបដិសេធចោលដោយភាន់ច្រឡំទៅទៀត។

ខាង អៀង សារី ក៏បានព្យាយាមលើកនូវបញ្ហានេះនៅអង្គបុរេជំនុំជម្រះដែរ។ មេធាវី អៀង

សារី បានលើកបញ្ហានេះនៅចំពោះមុខអង្គជំនុំជម្រះ មុនពេលបើកសវនាការ ហើយមិនដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងពាក់ព័ន្ធនឹងអញ្ញត្រកម្មនោះទេ គឺថា ១០ថ្ងៃក្រោយពេលដាក់អញ្ញត្រកម្មហ្នឹង គឺវាមានបញ្ហា។ ខ្ញុំសូមយោងទៅលើសារណារបស់យើង គឺកថាខណ្ឌ ៣៤៣ ដល់ ៣៤៦ យើងបានយកទឡ្ហីករណ៍របស់ អៀងសារី ហើយអង្គជំនុំជម្រះបានបដិសេធ។

[១៦:០២:២០]

ខ្ញុំសុំលើកនូវសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺថាបើទទួលយកវិសាលភាពនៃការជំនុំជម្រះនោះ វាអាចមានបញ្ហា ព្រោះថាបញ្ហាហ្នឹងគួរតែលើកឡើងនៅមុនពេលបើកសវនាការ ឬក៏ក្នុងពេលស៊ើបអង្កេត។ អ៊ីចឹងអង្គជំនុំជម្រះសាលាដំបូងហ្នឹងបដិសេធមិនព្រមពិនិត្យលើបញ្ហាហ្នឹងទេ ហើយបញ្ហាហ្នឹងក៏យើងលើកនៅក្នុងសារណាសន្និដ្ឋានស្ដាពររបស់យើងទៀត ដើម្បីចៀសវាងនូវយុត្តិនិសេធ ខ្ញុំសូមលើកនូវឯកសារ E457/6/4/1 កថាខណ្ឌ២១៣ ដល់ ២៧៦។

ខ្ញុំមិនដឹងថានេះជាសំណួរដែលអង្គជំនុំជម្រះបានសួរមកយើង ថាយើងបានលើកបញ្ហាហ្នឹងរួចមកហើយពីមុនហ្នឹង ឬក៏អត់ ប៉ុន្តែវាជាពេលដែលយើងត្រូវតែឆ្លើយតប យើងសូមបញ្ជាក់ថាគឺអង្គជំនុំជម្រះគាត់បានបញ្ជាក់អំពីសម្អាងហេតុនៃសាលក្រម ជាមួយនឹងទឡ្ហីករណ៍ដែលភាន់ច្រឡំ។ នៅក្នុងសម្អាងហេតុនៃសាលក្រម អង្គជំនុំជម្រះបានត្រឡប់មកសេចក្ដីសម្រេចរបស់ខ្លួន ហើយបានយល់ព្រមពិនិត្យបញ្ហាលើអង្គសេចក្ដី ប៉ុន្តែដូចដដែលទៀតហើយ អង្គជំនុំជម្រះគឺថាបានបដិសេធនូវសំណូមពររបស់យើង។ ដូច្នេះអង្គជំនុំជម្រះ គឺបានពិនិត្យអង្គហេតុដើម្បីកំណត់នូវអ្វីដែលបានប្ដឹង។ នៅក្នុងបណ្ដឹងសាទុក្ខរបស់យើង យើងបានជំទាស់ គឺសូមមើលកថាខណ្ឌ៣៥១ ដល់ ៣៦៦ នៃសារណារបស់យើង។

[១៦:០៤:១២]

លោកប្រធាន ខ្ញុំនៅសល់ចំណុចច្រើនទៀត ដែលត្រូវលើកឡើង ហើយខ្ញុំសុំបន្ថែមពេលវេលា។ ខ្ញុំមិនដឹងថា ខ្ញុំនៅសល់ប៉ុន្មាននាទីទៀតទេ អ៊ីចឹងខ្ញុំមិនអាចនិយាយអស់ក្នុងរយៈពេល ៥ នាទីទេ លោកប្រធាន។ អ៊ីចឹងសូមបន្ថែមពេលវេលា។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អាចសុំពេលបន្ថែមប៉ុន្មាន?

**លោកស្រី អង់គា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំត្រូវការយ៉ាងតិចបំផុតក៏ ២០នាទីទៀតដែរ លោកប្រធាន។ ដោយសារតែមាន

ការអន្តរាគមន៍កាត់យើងចុះឡើងៗអ៊ីចឹង។ អ៊ីចឹងយើងត្រូវការពេលវេលា ត្រូវការឆ្លើយតបជាមួយនឹងដើមបណ្តឹងផង ខាងសហព្រះរាជអាជ្ញាផង អ៊ីចឹងវាៗពិបាកណាស់ចំពោះយើង យើងត្រូវឆ្លើយតបទៅគ្រប់គ្នា អ៊ីចឹងយើងត្រូវលើកឡើងច្រើនចំណុច។ អ៊ីចឹងសុំលោកប្រធានសូមពេលបន្ថែម គឺ ២០នាទីលោកប្រធាន។

[១៦:០៦:០១]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដោយសារ ឌីវីឌី វាអស់ហើយ ហើយទុកឱ្យខាងបច្ចេកទេសហ្នឹងគេប្តូរ ឌីវីឌី សិន ហើយអង្គជំនុំជម្រះនឹងពិភាក្សានេះនៅលើនេះ អត់ចុះទៅណាទេ។

*(ចៅក្រមពិភាក្សាគ្នា)*

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ដើម្បីឱ្យច្បាស់លាស់នោះគឺថា ២០នាទីហ្នឹង អម្បាញ់មិញហ្នឹងគឺថាខ្ញុំបញ្ជាក់ហ្នឹងគឺអត់គ្រប់គ្រាន់ទេ លោកប្រធាន គឺសុំ ៣០ នាទី។ ចំណុចអង្គច្បាប់ហ្នឹងគឺថាវាមានឯកសារយោងច្រើនដើម្បីឱ្យមានភាពច្បាស់លាស់ អ៊ីចឹងសុំម្តងទៀត លោកប្រធាន គឺដើម្បីឱ្យវាមានតម្លាភាពហ្នឹងគឺ ៣០នាទីតែម្តងទៅលោកប្រធាន ព្រោះនេះជាលទ្ធភាពតែមួយគត់របស់យើងក្នុងការឆ្លើយតបទៅនឹងភាគីនានា ហើយវាជាបណ្តឹងសាទុក្ខចុងក្រោយរបស់យើងខ្ញុំផងដែរលោកប្រធាន។

[១៦:០៩:៣០]

**ប្រធានអង្គជំនុំ៖**

តាមពិតទៅគឺសារណាហ្នឹងធ្វើច្រើនហើយ ប៉ុន្តែខ្ញុំមើលទៅឃើញ មើលការនិយាយហ្នឹងជាន់គ្នាច្រើនដែរ ហើយពេលវេលាហ្នឹងគឺមួយម៉ោងទៅហើយ។ អ៊ីចឹងពេលវេលាដែលត្រូវឱ្យហ្នឹងតែ ៥៥នាទីទេ។ អ៊ីចឹងហើយគឺតាមការសម្រេចរបស់អង្គជំនុំជម្រះ គឺថាអនុញ្ញាតថែមឱ្យលោកមេធាវីហ្នឹងអាចត្រឹមតែ ១០នាទីទៀតទេ ហើយឱ្យសរុបឃ្លាទៅ អត្ថន័យទៅ ឱ្យវាច្បាស់លាស់ទៅ។

សូមអញ្ជើញត្រឹម ១០នាទីទៀត។ បាទសូមអញ្ជើញ! ហើយឱ្យសរុបឃ្លាទៅ អត្ថន័យទៅ ឱ្យវាច្បាស់លាស់ទៅ។ សូមអញ្ជើញត្រឹម១០នាទីទៀត។

**លោកស្រី អង់តា ហ្គីសសេ៖**

វាជាជម្រើសមួយដ៏លំបាកសម្រាប់ខ្ញុំលោកប្រធាន ព្រោះពេលតិចពេក។

នៅក្នុងសារណាចុងក្រោយរបស់យើង យើងបានលើកឡើងអំពីយុត្តិនិសេធនៅកថាខណ្ឌ៣៥១ ដល់៣៦៦ហ្នឹង គឺចៅក្រមហ្នឹង គឺត្រូវបានទទួលពាក្យបណ្តឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានកំណត់ជាក់លាក់នៅក្នុងផ្លូវច្បាប់ គឺថាមិនមែននៅក្នុងអង្គហេតុដែលរៀបរាប់នៅក្នុងភស្តុតាងទេ។ ពិតណាស់ គឺថាដើម្បីសរសេរដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរហ្នឹងគឺថា ត្រូវតែមានអង្គហេតុ ហើយវាគឺជាកាតព្វកិច្ចសំខាន់ណាស់ដែលអង្គហេតុទាំងអស់ហ្នឹងត្រូវបានដាក់បញ្ចូលនៅក្នុងដីកាសន្និដ្ឋាននោះ។ នេះគឺជាទឡ្ហីករណ៍ដែលលើកឡើងដោយចៅក្រម -- គឺដែលសហព្រះរាជអាជ្ញាទេបានបញ្ជាក់ប្រាប់យើងទេថាអង្គបុរេជំនុំជម្រះហ្នឹងគឺបាននិយាយផ្ទុយពាក្យនេះវិញ ហើយក៏បានលើកឡើងអំពីយុត្តិសាស្រ្តបារាំងផងដែរ ដែលគាត់និយាយថាមាននៅស្រុកបារាំងគឺមានយុត្តិសាស្រ្តពេញលេញពាក់ព័ន្ធនឹងចំណុចនេះ។ ដូច្នេះវា គឺវាមានអត្ថិភាពនៃវិធានជាក់លាក់ដែលពាក់ព័ន្ធទៅនឹងភាពស្មុគស្មាញទាំងអស់នេះ ហើយនៅថ្នាក់ជាតិហ្នឹងគឺថា វាមិនមានករណីដូចជាពាក់ព័ន្ធទៅនឹងរឿង ខៀវ សំផន នោះទេ។ ដូច្នេះនៅពេលដែលយើងទទួលបានព័ត៌មានអំពីចំណុចណាមួយនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរហ្នឹងគឺថា -- គឺថាយើងពិបាកមែនទែន។ ខ្ញុំសូមយោងទៅលើយុត្តិសាស្រ្តរបស់តុលាការកំពូលដែលនិយាយអំពីបរិបទផ្សេងៗនៅថ្នាក់ជាតិ និងអន្តរជាតិ គឺឯកសារ E350/2/1/4 គឺនៅពាក់ព័ន្ធទៅនឹង--

**អ្នកបកប្រែ៖**

លោកប្រធាន សុំឲ្យមេធាវីគាត់បន្ថយល្បឿនបន្តិច។ គាត់អានលឿនពេក អ្នកបកប្រែតាមអត់ទាន់ទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីមេធាវី បន្ថយល្បឿនបន្តិច កុំឲ្យលឿនពេក។ ខាងបកប្រែបកអត់ទាន់ទេ។

[១៦:១៤:៣០]

**លោកស្រី អង់តា ហ្គីសសេ៖**

ដោយសារឲ្យពេលខ្ញុំតែ១០នាទី។ អ៊ីចឹងហើយបានខ្ញុំនិយាយលឿន។

សហព្រះរាជអាជ្ញាបានបន្ទោសយើងពាក់ព័ន្ធទៅនឹងការបែងចែករវាងអង្គហេតុ។ នៅកថាខណ្ឌមួយនៃចម្លើយតបរបស់ខ្លួនហ្នឹងគឺសហព្រះរាជអាជ្ញាបាននិយាយថា វាមានការបែងចែករវាងអង្គហេតុ ហើយនិងភស្តុតាង។ ដូច្នេះជាការសន្និដ្ឋានហ្នឹងគឺថា អ្វីៗគឺថាយើងបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងនៅក្នុងកថាខណ្ឌ៣៦៧ ដល់ ៤៤៨។ ខ្ញុំសូមនិយាយអំពីកថាខណ្ឌមួយចំនួននៃ

សារណារបស់យើង។

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែតាមអត់ទាន់ទេ។ គាត់លឿនពេក។

**លោកស្រី អង់តា ហ្គីសសេ៖**

គឺអង្គហេតុប្រភេទទីបីដែលខ្ញុំបានលើកឡើងគឺវាហួសពីអ្វី ពីវិសាលភាពនៃបណ្ដឹង។ នេះគឺជាការរិះគន់ដែលយើងបានលើកឡើងនៅក្នុងសារណារបស់យើង គឺនៅក្នុងកថាខណ្ឌ៨៧ ដល់៩៧។ ហើយនៅក្នុងកថាខណ្ឌ៤៥៨ ដល់៤៦៤ គឺអង្គហេតុទទួលបណ្ដឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយហើយដែលត្រូវបានកំណត់ជាក់លាក់តាមផ្លូវច្បាប់។ ដីកាដំណោះស្រាយហ្នឹងគឺដំណោះដីកាមួយដែលថាស្រពិចស្រពិលមិនច្បាស់លាស់ទេ។ ខ្ញុំរំឭកនៅកថាខណ្ឌ៤៦១ហើយគឺថា គឺមានសេចក្ដីសន្និដ្ឋានដែលវាមិនចាំបាច់ច្រើនណាស់ ហើយយើងត្រូវការពិនិត្យមើលស្រាវជ្រាវទៅលើកថាខណ្ឌទាំងអស់ហ្នឹង ដើម្បីឲ្យដឹងថាតើអ្វីដែលត្រូវបានចោទប្រកាន់ពិតប្រាកដ អ្វីដែលត្រូវបានកំណត់ថាជាបទល្មើសពាក់ព័ន្ធនឹងបញ្ហាផ្លូវច្បាប់ហ្នឹង ដើម្បីបញ្ជាក់ថាវាជាបទចោទនេះ។ នេះគឺជាអ្វីដែលមាននៅក្នុងដីកាដំណោះស្រាយ ដែលខ្ញុំសូមយោងទៅលើសារណាបណ្ដឹងសាទុក្ខរបស់យើងគឺ កថាខណ្ឌ៤៦១។

[១៦:១៨:១៥]

ខ្ញុំសូមនិយាយអំពីឧទាហរណ៍ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម ជាពិសេសគឺការចោទប្រកាន់តែនៅស្វាយរៀង និងព្រៃវែង ហើយបន្ទាប់មកទៀតមានភស្តុតាងទៅលើដែនដីទាំងមូលតែម្តង។ ហើយប្រហែលជាឥឡូវនេះខ្ញុំមិនអាចនិយាយបាន ប្រហែលជាខ្ញុំនឹងធ្វើនៅពេលក្រោយទៀត។

ហើយដោយសារតែពេលវេលាមានកំណត់ ខ្ញុំសូមនិយាយអំពីប្រភេទទីបួននៃការអនុវត្តហួសពីដីកាបំបែកសំណុំរឿង គឺជាការឆ្លើយតបទៅនឹងសំណួររបស់តុលាការកំពូលពាក់ព័ន្ធទៅនឹងការនិយាយយោងទៅដល់ជនជាតិវៀតណាមនៅពេលដែលមានការបាត់ខ្លួនដោយបង្ខំ។ អង្គជំនុំជម្រះបានទទួលស្គាល់ថាការបាត់ដោយបង្ខំនូវជនជាតិវៀតណាមនេះត្រូវបានដកចេញពីសំណុំរឿង០០២/០២ ដោយដីកាបំបែកនីតិវិធី។ ហើយយើងក៏បានលើកឡើងនៅក្នុងសារណាចុងក្រោយរបស់យើងហើយ ដូច្នេះគ្មានអ្វីដែលថ្មីទេ ហើយខ្ញុំក៏សូមយោងទៅលើអ្វីដែលយើងបានបកស្រាយនៅក្នុងសារណារបស់យើង។ នេះមិនមែនជាបញ្ហានៃការបកស្រាយដីកាបំបែកនីតិវិធីនទេ។ គឺវាបញ្ហាវាថា គឺថាអង្គជំនុំជម្រះបានដក

ចេញរួចហើយៗបានកាត់ក្ដីទៅលើអង្គហេតុដែលខ្លួនបានសម្រេចដកចេញនោះទៅវិញ។ ខ្ញុំសូមយោងទៅលើកថាខណ្ឌ៥៣៨ ដល់ ៥៤៦ ខ្ញុំសូមយោងទៅលើកថាខណ្ឌ៤៣ ផងដែរ។

ដើម្បីបញ្ចប់ ខ្ញុំសូមបញ្ជាក់ថានៅក្នុងសំណុំ០០២/០២ហ្នឹង គឺអង្គជំនុំជម្រះទទួលបណ្ដឹងពាក់ព័ន្ធទៅនឹងបញ្ហាជនជាតិចាមផងដែរ។ ខ្ញុំសូមសោកស្ដាយណាស់ដែលមិនបានលើកឡើងនូវទឡ្ហីករណ៍សំខាន់មួយចំនួនទៀត ហើយខ្ញុំត្រូវបង្ខំចិត្តបញ្ចប់នៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តដល់សារណារបស់សហព្រះរាជអាជ្ញា អ៊ីចឹងសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសារណា បាទ។

[១៦:២២:៣០]

**លោកស្រី ហេឡេន វើសនុប៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំឈ្មោះ ហេឡេន។ នៅមូលដ្ឋានចំនួនបណ្ដឹងសាទុក្ខចំនួនប្រាំ មានមូលដ្ឋានទីពីរ ៣៨, ពី១២២ ទៅដល់ ១២៣ បានលើកឡើងនៅក្នុងសំណុំរឿង០០២ ថាតើអង្គហេតុណាខ្លះដែលស្ថិតនៅក្នុងសំណុំរឿង០០២ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនោះ។ នៅក្នុងចម្លើយតបរបស់ខ្ញុំ កថាខណ្ឌ២៤៥ ដល់ ២៧២ យើងបានលើកឡើងអំពីប្រវត្តិសាវតារច្បាប់ អំពីយុត្តិសាស្ត្រ គោលការណ៍ ហើយក៏ដូចជាគោលការណ៍នៃនីតិវិធីមួយចំនួនពាក់ព័ន្ធទៅនឹងមូលដ្ឋានទាំងនេះ។ ថ្ងៃនេះខ្ញុំនឹងផ្ដោតទៅលើសារណារបស់ខ្ញុំ ថាហេតុអ្វីបានជាទឡ្ហីករណ៍របស់ម្ចាស់បណ្ដឹងសាទុក្ខនីមួយៗហ្នឹងគឺថា វាមានការខកខានមិនបានលើកឡើងពេញលេញនោះ ជាពិសេសទាក់ទងទៅនឹងប្រភេទបណ្ដឹងសាទុក្ខប្រភេទមួយ ពីរ បី និង បួន ដែលប្រើប្រាស់និយមន័យតែមួយនៅក្នុង ដែលបានរកឃើញនៅក្នុងចម្លើយតបរបស់យើងខ្ញុំ ដោយសារដំណើរការយើងកំពុងតែដើរទៅមុខនេះ គឺកាលណានិយាយអំពីប្រភេទនេះគឺយើងចំណុចមួយដែលខ្ញុំនៅតែលើកឡើងគឺម្ចាស់បណ្ដឹងសាទុក្ខបានទទួលអង្គជំនុំជម្រះមិនមានកាតព្វកិច្ចសម្រេចអ្វីនៅពីខាងក្រោយដីកាដំណោះស្រាយនោះទេ។ ផ្ទុយទៅវិញនៅសំណុំរឿង០០២/០២ នេះ គឺគិតទៅដំណើរការនីតិវិធីជិត១០ឆ្នាំមកហើយ។ ពាក់ព័ន្ធទៅនឹងប្រភេទទីមួយ និយាយអំពីប្រវត្តិសាវតារមូលដ្ឋានភាគច្រើនរបស់ម្ចាស់បណ្ដឹងសាទុក្ខ គឺយើងគិតទៅជិត១០ឆ្នាំមកហើយលើកឡើងបញ្ហានេះ។ ប្រភេទទីមួយ គឺមូលដ្ឋានបណ្ដឹងសាទុក្ខ៣៩ ដល់ ៥៩ និង ១២៣ ហើយម្ចាស់បណ្ដឹងសាទុក្ខបានលើកក្នុងអង្គហេតុមួយចំនួន ចំណុចទាំងអស់នេះមិនមាននៅក្នុងដីកា

បញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរទេ ដែលបានដាក់នៅក្នុងឆ្នាំ២០០៧។

[១៦:២៥:១៧]

សារណាដំបូងរបស់ខ្ញុំគឺថា វាពាក់ព័ន្ធទៅនឹងការជម្លៀសជនជាតិវៀតណាម ហើយមូលដ្ឋាន -- ហើយពាក់ព័ន្ធទៅនឹងករណីរបស់ម្ចាស់បណ្ដឹងសាទុក្ខ សហចៅក្រមស៊ើបអង្កេតមិនដែលបានស៊ើបអង្កេតអង្គហេតុទាំងអស់នេះនោះគឺមិនត្រឹមត្រូវទេ។ ដូចយើងបានស្ដាប់ពីខាងដើមហើយ ទាំងម្ចាស់បណ្ដឹងសាទុក្ខ ឬក៏ភាគីណាមួយនៅក្នុង មិនបានប្ដឹងសាទុក្ខទៅលើចំណុចនេះទេ។ នេះគឺស្ថិតនៅក្នុងមូលដ្ឋានបណ្ដឹងសាទុក្ខទី៤១។ ដោយសាររឿងក្ដីនេះចាប់ផ្ដើមតាំងពីឆ្នាំ២០០៧ ម្ចាស់បណ្ដឹងសាទុក្ខមិនដែលប្ដឹងអំពីវិសាលភាពនៃការស៊ើបអង្កេត ឬក៏មិនដែលដាក់សំណើណាមួយឲ្យធ្វើមោឃភាពទៅនឹងផ្នែកណាមួយនៃការស៊ើបអង្កេតស្ថិតនៅក្រោមវិធាន៧៦(២) នោះទេ ដូច -- ខ្ញុំៗសុំលើកឡើងអំពីការខកខានមិនបានលើកឡើងអំពីចំណុចនេះនៅក្នុងសារណារបស់ -- នៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញមកគឺថា មិនដែលបានលើកឡើងអំពីអញ្ញត្រកម្មអ្វីមួយ មុនពេលសវនាការនេះចាប់ផ្ដើមទេ។ ហើយនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបំបែកកិច្ចដំណើរការនីតិវិធីនេះ គឺថាក៏មិនមានការប្ដឹងជំទាស់តវ៉ាទៀត។ នៅពេលដែលសំណុំរឿង០០២/០១ បញ្ចប់ហើយទើបតែលើកឡើងចំណុចនេះឡើង។ គឺលើកឡើងនៅថ្ងៃទី០២ ឧសភា ឆ្នាំ២០១៧។ ដីកាដំណោះស្រាយកំណត់អំពីវិសាលភាពទាំងវិសាលភាពនៃការជំនុំជម្រះ ក៏ដូចជាសាលក្រម។

[១៦:២៧:០៦]

វាពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់យើងម្នាក់ៗនោះ រួមទាំងផលប្រយោជន៍របស់ជនជាប់ចោទផងដែរ គឺថាតាមការរបស់ខ្ញុំៗមើលឃើញថា ប្រភេទទីមួយ នៃអំពីមូលដ្ឋានបណ្ដឹងសាទុក្ខ ដូច្នេះផលប៉ះពាល់គឺវាពាក់ព័ន្ធទៅនឹងការឃើតយ៉ាវរបស់ម្ចាស់បណ្ដឹងសាទុក្ខនេះទៅវិញទេ។ ហើយនិយាយឲ្យទូលំទូលាយគឺថាបណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍នេះគឺលើកឡើងអំពីអង្គហេតុនេះបន្តិច នោះបន្តិច តាមការស្រមៃរបស់ខ្លួនតែប៉ុណ្ណោះ។ ហើយជាពិសេសពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈ និងការរៀបអាពាហ៍ពិពាហ៍នេះដែរ។

អ.វ.ត.ក ក៏បានចំណាយពេលពាក់ព័ន្ធទៅនឹងផ្នែកមិនពាក់ព័ន្ធ ហើយប្រឈមមុខទៅនឹងចំណុចមួយចំនួនដែលធ្វើឲ្យជនរងគ្រោះគិតថាមានត្រូវម៉ា។ នៅក្នុងសាលដីកាសំណុំរឿង០០១ ត្រង់ជើងទំព័រលេខ៧៤ អង្គជំនុំជម្រះតុលាការកំពូលក៏បានរកឃើញ -- បានចេញនូវសេចក្ដីសន្និដ្ឋានរបស់តុលាការ

អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងមីឡូទីណូវិច នៅពេលដែលខ្លួនលើកថាតម្រូវការពាក់ព័ន្ធទៅនឹងអញ្ញត្រកម្ម គឺនៅមុនការចាប់ផ្តើមសវនាការ។ ជាមួយនឹងករណីលើកលែងដ៏ចង្អៀតចង្អល់នេះ តួនាទីរបស់អង្គជំនុំជម្រះនោះគឺទៅជំនុំជម្រះរឿងក្តីនេះ ហើយត្រូវតែវិភាគគ្រប់បន្ទាត់ទាំងអស់នៅក្នុងដីកាដំណោះស្រាយ។ វិធានផ្ទៃក្នុងក៏ដូចជាយុត្តិសាស្ត្រ គឺចាប់ផ្តើម ថាតើមានអ្វីកើតឡើងនៅមុនការជំនុំជម្រះ? វិធាន៧៩(១) គឺកំណត់ថា អង្គជំនុំជម្រះបានទទួលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១៦:២៨:៥៧]

វិធាន៧៦(៧) កំណត់ថាដីកាដំណោះស្រាយវាត្រូវដោះស្រាយនៅរាល់វិការៈនៃកិច្ចដំណើរការនីតិវិធីទាំងអស់។ ហើយនៅក្នុងវិធាន៧៦(៧) មិនអនុវត្តដោយផ្ទាល់ទៅនឹងដីកាដំណោះស្រាយទាំងពីរនេះទេ ដោយសារថាបញ្ហានេះមិនបានអនុញ្ញាតឲ្យបើកធ្វើការប្តឹងសាទុក្ខទេ ប៉ុន្តែគឺចំណុចនេះវាកើតមានឡើងនៅចន្លោះពេលមុនការជំនុំជម្រះ ក៏ដូចដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ឥឡូវនេះវាមាននីតិវិធីដែលបានលើកឡើងម្តងហើយម្តងទៀត មានន័យថាវាមានការត្រួតគ្នាច្រើននៅមុនដំណាក់កាលជំនុំជម្រះនេះ។

ដូចមេធាវីការពារក្តីលើកឡើងនៅពេលមូលដ្ឋានប្រភេទទីមួយ គឺត្រូវបានដាក់ជូននៅចំពោះមុខ អ.ប.ជ ស្តីអំពីបណ្តឹងឧទ្ធរណ៍គឺថា អ.ប.ជ បដិសេធមិនដោះស្រាយបញ្ហានេះទេ ហើយក៏បានបញ្ជូនរឿងនេះមកដល់អង្គជំនុំជម្រះសាលាដំបូងតែម្តង។

ដូច្នេះនៅពេលដែលយើងយល់ស្របថា អ.ប.ជ គួរតែដោះស្រាយបញ្ហាវិសាលភាពនៅមុនដំណាក់កាលជំនុំជម្រះ ប៉ុន្តែមិនបានធ្វើទៅវិញ។ តាមទ្រឹស្តីយ៉ាងហោចណាស់ម្ចាស់បណ្តឹងសាទុក្ខគាត់បានបោះបង់សិទ្ធិនេះដែរ វាជាការពិត ដូចដែលខ្ញុំបានលើកឡើង បញ្ហានៃការជម្ទៀសនោះគឺថាបានដាក់ជូនអង្គជំនុំជម្រះដោយ អៀង សារី មិនមែនដោយម្ចាស់បណ្តឹងឧទ្ធរណ៍នេះទេ ហើយគឺចំណុចនេះបានធ្វើឡើងនៅក្នុងឆ្នាំ២០១៤។ ម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់នេះបានលើក -- មិនបានលើកឡើងប្រភេទនៃមូលដ្ឋានណាមួយនៅមុនដំណាក់កាលជំនុំជម្រះទេ។ ប៉ុន្តែសាលាដំបូង គឺថាត្រឹមត្រូវហើយក្នុងការដែលបានសម្រេចថា នេះគឺម្ចាស់បណ្តឹងសាទុក្ខមិនមានសិទ្ធិលើកឡើងអំពីបញ្ហាថាតើគាត់ពេញចិត្ត ឬមិនពេញចិត្តនោះទេ ដើម្បីធានាទៅដល់វិសាលភាពនៃការជំនុំជម្រះមុនពេលការជំនុំជម្រះចាប់ផ្តើមនោះ។ អង្គជំនុំជម្រះបានលើកឡើងនៅក្នុងសាលដីកា -- តុលាការកំពូលលើកឡើងក្នុងសាលដីកាសំណុំរឿង ០០១ កថាខណ្ឌ២៨ និងវិធាន៨៩(១) ដែលមានរយៈពេល៧ថ្ងៃ។

គោលបំណងរបស់ម្ចាស់បណ្តឹងសាទុក្ខគឺពាក់ព័ន្ធជាបញ្ហានេះ គឺត្រូវបានហាមឃាត់ដោយវិធាន ៨៩(១) ដោយសារសាលាដំបូងបានរកឃើញ ដោយសារបញ្ហាអញ្ញត្រកម្មនេះ គឺគាត់បានជំទាស់ថាពាក់ព័ន្ធបញ្ហា -- បញ្ហានេះពាក់ព័ន្ធទៅនឹងយុត្តាធិការផ្លូវច្បាប់។ ម្ចាស់បណ្តឹងបានលើកឡើង ដោយយោងថា អង្គជំនុំជម្រះតុលាការកំពូល គឺថាមានយុត្តាធិការផ្តាច់មុខ តែនៅពេលដែលវាយតម្លៃទៅលើភាពអាចទទួលបាននៃការជំទាស់តវ៉ាស់ទៅលើបញ្ហាយុត្តាធិការ។

[១៦:៣២:០០]

ហើយម្យ៉ាងវិញទៀត និយាយពីបញ្ហាយុត្តាធិការលើអង្គហេតុនេះ គឺជាប្រភេទដែលអង្គជំនុំជម្រះហៅថាយុត្តាធិការស្តីអំពីកិច្ចដំណើរការនីតិវិធី។ ខ្ញុំសុំលើកឡើងឧទាហរណ៍បញ្ហាពាក់ព័ន្ធទៅនឹងយុត្តាធិការផ្តាច់មុខតែម្តង។ យុត្តាធិការផ្តាច់មុខលើកឡើងពីលទ្ធភាពតុលាការ អនុវត្តអំណាចរបស់ខ្លួននៅក្នុងរឿងក្តីណាមួយ ក្នុងពេលពិនិត្យមើលទៅលើការជំនុំជម្រះពាក់ព័ន្ធទៅនឹងវិធានដែលអាចអនុវត្តបាន។ ដោយសារតែម្ចាស់បណ្តឹងសាទុក្ខធ្វើការជំទាស់តវ៉ាទៅបណ្តឹងដោយសម្អាងទៅលើកំហុសអង្គហេតុនៅក្នុងការស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ មិនមែនអំពីយុត្តាធិការរបស់ អ.វ.ត.ក ដោយផ្ទាល់នោះទេ។

ជំហររបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងបណ្តឹងសាទុក្ខនេះ គឺវាមានការខុសផ្ទុយគ្នាស្រឡះនៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ហើយ គឺអនុវត្តតាមវិធាន ៨៩(១) ពាក់ព័ន្ធទៅនឹងរបបនៃអញ្ញត្រកម្មនេះ។ ក៏ប៉ុន្តែតុលាការកំពូលបានពន្យល់ហើយថា រយៈពេលកំណត់ ៣០ថ្ងៃនេះ មិនអនុវត្តទៅនឹងការជំទាស់តវ៉ាទៅលើយុត្តាធិការទាំងស្រុងនោះទេ។ វាអនុវត្តទៅនឹងការជំទាស់តវ៉ាទៅលើយុត្តាធិការនីតិវិធី ដែលស្ថិតនៅក្នុងវិធាន ៨៩(១)។ ហើយពាក់ព័ន្ធទៅនឹងមូលហេតុដូចខ្ញុំបានលើកឡើងគឺថាហេតុអ្វីបានជាចំណុចទាំងអស់នេះមិនត្រូវបានដោះស្រាយមុនការជំនុំជម្រះ ហេតុអីក៏ខកខានមិនបានលើកចំណុចនោះឡើងយ៉ាងដូច្នេះ ធ្វើឱ្យខ្លួនបាត់បង់សិទ្ធិ។ ហេតុដូច្នេះ សាលាដំបូងគឺត្រឹមត្រូវក្នុងការពិចារណាទៅលើមូលដ្ឋានប្រភេទទីមួយ ស្ថិតនៅក្នុងវិធាន៨៩(១) ហើយហេតុផលដូចគ្នានេះ គឺខ្ញុំលើកឡើងថា គឺដែលមានលើកឡើងនៅក្នុងមូលដ្ឋាន៤១ ហើយចំណុចដូចគ្នាក៏បានលើកឡើងនៅក្នុងមូលដ្ឋានទី៤៤ផងដែរ។ ចំណុចនេះមិនអាចទទួលយកបានឡើយ។

ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលត្រូវពិចារណាទៅលើអង្គសេចក្តី យើងខ្ញុំសូមលើកឡើងថា ការលើកឡើងនេះគឺមិនត្រឹមត្រូវទេ គឺជាការខកខានមួយ។ អង្គហេតុមួយមានលើកជំទាស់គឺថា មិន

ស្ថិតនៅក្នុងវិសាលភាពនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះទេ ជាពិសេសនៅក្នុងកថាខណ្ឌ២៨១ និង ៣០៥ នៃដីកាដំណោះស្រាយ។

[១៦:៣៤:៤០]

នៅក្នុងគោលបំណងដែលត្រូវដកអង្គហេតុចេញពីសំណុំរឿង០០២ នេះគឺសំណើនេះគឺនេះមិនបានគាំទ្រទៅដល់ការលើកឡើងនេះទេ។ វិធាន៥៣(១) លើកឡើងថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចតែក្នុងការផ្តល់អង្គហេតុសង្ខេប ហើយនិងការកំណត់លក្ខណៈផ្លូវច្បាប់ពាក់ព័ន្ធទៅនឹងបទល្មើសដែលបានចោទប្រកាន់នេះ។ វាជារឿងមិនសមស្របទេ ដែលក្នុងគិតថា ដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះ ដែលបានរៀបធ្វើសេចក្តីព្រាងក្រោយការបញ្ចប់ការស៊ើបអង្កេតបឋមរួចមក ហើយក្រោយមក ក៏មានការចេញដំណោះស្រាយនោះ។ បើសិនបើធ្វើដូចនេះ គឺថាកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ គឺវាហាក់បីដូចជាមិនលក្ខណៈមិនច្បាស់។

យុត្តិសាស្ត្រដែលយើងបានទទួលពី អ.ប.ជ ក៏ដូចពីតុលាការបារាំង គឺបានបញ្ជាក់ឲ្យច្បាស់ហើយ ចៅក្រមស៊ើបអង្កេត គឺមិនមែនស៊ើបអង្កេតតែអ្វីដែលអនុញ្ញាតទេ ប៉ុន្តែវាជាកាតព្វកិច្ចត្រូវស៊ើបអង្កេត និងចេញដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់។

នៅជុំវិញកិច្ចស៊ើបអង្កេតដែលត្រូវកំណត់ដោយពិនិត្យមើលទៅលើដីកាបញ្ជូនរឿងឲ្យស៊ើបសួរទាំងមូលតែម្តង។ នេះមានន័យថា កាតព្វកិច្ចរបស់ចៅក្រម គឺមិនមែនពិនិត្យតែទៅលើអង្គហេតុដែលកំណត់នៅក្នុងបរិបទនៃសារណានេះទេ ក៏ -- ដូចដែលម្ចាស់បណ្តឹងសាទុក្ខលើកឡើង ក៏ប៉ុន្តែនៅក្នុងជើងទំព័រ និងឧបសម្ព័ន្ធរបស់ខ្លួនក៏បានលើកឡើងដែរ។

[១៦:៣៦:១០]

នៅក្នុងរឿងក្តីនេះ សហព្រះរាជអាជ្ញាគឺថាមានការពាក់ព័ន្ធយ៉ាងច្បាស់លាស់ ហើយយុត្តិសាស្ត្រនេះគឺបានបង្ហាញឲ្យឃើញថា កាលៈទេសៈជុំវិញអង្គហេតុទាំងអស់នេះ បានលើកឡើងយ៉ាងច្បាស់ហើយនៅក្នុងសារណារបស់យើងខ្ញុំ ក៏ដូចជាបានពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់ផងដែរ ជាពិសេសវាមានសារៈសំខាន់ នៅពេលដែលវាមានការជាប់ពាក់ព័ន្ធទៅនឹងការកំណត់លក្ខណៈផ្លូវច្បាប់។ ដូច្នេះ អង្គហេតុនេះបានលើកឡើងយ៉ាងច្បាស់នៅក្នុងសារណារបស់យើងនេះ គឺជាការច្បាស់លាស់ហើយ កាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត គឺត្រូវពិនិត្យមើលគ្រប់ពេលវេលា ឧទាហរណ៍ ទៅពិនិត្យមើលនៅទីតាំងឧក្រិដ្ឋកិច្ច តាមរយៈការបង្ខំឲ្យធ្វើពលកម្មដោយលើសកម្លាំង។

អ៊ីចឹងនិយាយដោយងាយ គឺចៅក្រម គឺតម្រូវឲ្យពិនិត្យមើលរូបភាពនេះពេញលេញតែម្តង ដែលបាន -- ដែលសហព្រះរាជអាជ្ញាបានដាក់ជូនខ្លួន។

លោក លោកស្រីចៅក្រមជាទីគោរព ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ពាក់ព័ន្ធទៅនឹងការដាក់ឲ្យទៅជាទាសករ ជាពិសេសនៅភ្នំក្រោលតែម្តង។ យើងខ្ញុំយល់ថា នេះគឺជាមូលដ្ឋានបណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទី៤៨ ហើយសហព្រះរាជអាជ្ញាបានទទួលបញ្ហានេះតាមរយៈសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងអង្គហេតុនៃពលកម្មដោយបង្ខំនៅក-១១ -- នៅការដ្ឋាន ក-១១ ហើយនិងនៅ ក-១៧ ក៏ដូចជាភ្នំក្រោល ដែលទាំងអស់នេះគឺវាស្ថិតនៅក្នុងវិសាលភាពសំណុំរឿង០០២/២។

ម្ចាស់បណ្តឹងសាទុក្ខនេះ គឺថាជាដំបូងហ្នឹងគឺនៅក្នុងសវនាការផ្ទាល់ពី២០១៧ ហើយដែលត្រូវបានពិចារណានៅក្រោមវិធាន៨៩(១)។ នៅក្នុងករណីណាក៏ដោយ សហព្រះរាជអាជ្ញាគឺ ចៅក្រមស៊ើបអង្កេតគាត់បានស៊ើបអង្កេតទៅលើពលកម្មដោយបង្ខំនៅក្នុងការដ្ឋានបីៈ គឺនៅមន្ទីរសន្តិសុខភ្នំក្រោល ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា ការរៀបរាប់ និងភស្តុតាងគឺពាក់ព័ន្ធទៅនឹង ក-១៧។ ក៏ប៉ុន្តែនៅពេលដែលកិច្ចស៊ើបអង្កេតចាប់ផ្តើម គឺថាវាច្បាស់ថា ហើយវាមានទីតាំងមួយចំនួន វាមានការជាប់ពាក់ព័ន្ធនៅតំបន់១០៥។ ហើយសហព្រះរាជអាជ្ញាបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម គឺឯកសារ D202 បានពន្យល់ពាក់ព័ន្ធទៅនឹងមន្ទីរក-១១ ដែលបានរៀបរាប់យ៉ាងច្បាស់ ដែលនៅក្នុងនោះរួមទាំង ក-១៧ រួមទាំងគុកភ្នំក្រោលផងដែរ។

[១៦:៣៨:៥៥]

ភស្តុតាងបានបញ្ជាក់នៅក្នុងជើងទំព័រ ជាពិសេសវាពាក់ព័ន្ធទៅនឹងការដ្ឋានការងារដោយបង្ខំ។ ឧទាហរណ៍នៅក្នុងដីកា នៅក្នុងកំណត់ហេតុស៊ើបសួរ អ៊ំ ម៉ុល នេះ រៀបរាប់ការធ្វើការនៅក្នុងអំឡុងពេលរបស់គាត់នៅក-១១។ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ ចាន់ ទូច នេះក៏អ៊ីចឹងដែរ គឺជាអតីតអ្នកទោសនៅមន្ទីរក-១៧។

ដូចគ្នានេះដែរ អ៊ុំង ដួស នេះរៀបរាប់ថាគាត់ត្រូវបានបង្ខំឲ្យធ្វើពលកម្មនៅពេលគេឃុំឃាំងគាត់នៅគុកភ្នំក្រោល។

ឥឡូវខ្ញុំចូលទៅដល់មូលដ្ឋានប្រភេទទីពីរ។ មូលដ្ឋាន ៦២, ៦៤ គឺវាពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់។ នៅក្នុងសហករណ៍ទាំងអស់នេះ ម្ចាស់បណ្តឹងសាទុក្ខគឺថាសុំឲ្យដកចេញនូវអង្គហេតុដែលគាត់គិតថាមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ដាក់មកជំនុំជម្រះ។

ជំហររបស់យើងខ្ញុំគឺសូមលើកឡើងដោយត្រង់តែម្តង ប្រភេទមូលដ្ឋានទីពីរនេះ គឺត្រូវបានហាមឃាត់ដោយវិធាន៨៩(១) ដែរ។ ហើយម្ចាស់បណ្តឹងសាទុក្ខ គឺទទួលបានព័ត៌មានទាំងអស់ដែលគាត់ត្រូវការ នៅពេលចេញដីកាដំណោះស្រាយនោះ។ ប៉ុន្តែគាត់ខកខានមិនបានប្តឹងជំទាស់ទៅនឹងដីកាដំណោះស្រាយ ឬក៏លើកអំពីអញ្ញត្រកម្មណាមួយយោងតាមវិធាន៨៩(១) ដែលកំណត់ពេលឱ្យរយៈពេល៣០ថ្ងៃ។ ក្នុងករណីណាក៏ដោយ កថាខណ្ឌ៣១០ ដល់៣១៤នៅក្នុង -- នៃចម្លើយតបរបស់យើង អង្គហេតុទាំងអស់នោះគឺថាបញ្ជាក់ឱ្យឃើញថា ហើយនៅក្នុងមូលដ្ឋាន៦២ និង៦៤ គឺវាពាក់ព័ន្ធទៅនឹងប្រភេទកំហុសមូលដ្ឋានប្រភេទទី១ ដល់ ៣៩។ ហើយម្ចាស់បណ្តឹងសាទុក្ខបានពិនិត្យមើលទៅលើភស្តុតាងតែឯង ហើយធ្វើមិនដឹងមិនឮទៅដល់បរិបទទាំងអស់ ក៏ដូចជាភស្តុតាងស៊ីសង្វាក់គ្នានៅក្នុងដីកាដំណោះស្រាយតែម្តង។

[១៦:៤០:៥៧]

ឥឡូវចូលដល់ប្រភេទទីបី។ និយាយអំពី គឺជាមូលដ្ឋាន៦០ មូលដ្ឋាន៥៥, ៨១, មូលដ្ឋាន១២៤ និង ១៣៤។ យើង ខ្ញុំបាន -- យើងខ្ញុំគឺថាយើងមានការពាក់ព័ន្ធទាំងស្រុងតែម្តងនៅក្នុងករណីនេះ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងហើយថា អង្គជំនុំជម្រះបានសម្រេចនៅខាងក្រៅវិសាលភាពនៃសំណុំរឿង០០២។ មូលដ្ឋាននីមួយៗបានបញ្ជាក់យ៉ាងច្បាស់។ ក៏ប៉ុន្តែដូចខ្ញុំបានលើកឡើងនូវចំណុចពីរនិយាយអំពីគោលការណ៍ដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នៅក្នុងសាលដីកាមុនរបស់ខ្លួននោះ។ ទីមួយសាលាដំបូងត្រូវបានកំណត់ មានទទួលអង្គហេតុដែលមានកំណត់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅពេលដែលជនជាប់ចោទគាត់តម្រូវឱ្យមានការបញ្ជាក់អំពីបណ្តឹងនៅក្នុងពេលជំនុំជម្រះនេះ។ ទីពីរ យុត្តិសាស្ត្រមកពីអង្គជំនុំជម្រះនីមួយៗនៃអ.វ.ត.ក យើងហ្នឹង ក៏ដូចជាគឺមានការបញ្ជាក់យ៉ាងច្បាស់ក្នុងដីកាបញ្ជូនរឿងជំនុំជម្រះ ហើយក៏បានពិចារណាទៅលើកថាខណ្ឌនីមួយៗនៅក្នុងបរិបទនៃដីកាដំណោះស្រាយទាំងនេះដែរ។ ឥឡូវចូលដល់មូលដ្ឋានប្រភេទទីបួន។ ខ្ញុំសូមលើកនូវឧទាហរណ៍មួយចំនួន។ ទីមួយ មូលដ្ឋានទី៦៥ មិនស្នើឱ្យអង្គជំនុំជម្រះពិនិត្យទៅលើស្ថានភាពអត់ឃ្លាននៅស្រុកត្រាំកក់នោះទេ។

**អ្នកបកប្រែៈ**

លោកប្រធានសុំការអនុញ្ញាតិលោកប្រធាន។ ញាប់តាមអត់ទាន់ទេលោកប្រធាន។

[១៦:៤៣:០៧]

**លោកស្រី ហេឡេន វើសនុបៈ**

អង្គហេតុពាក់ព័ន្ធក្រៅពីការអត់ឃ្លាននេះ។ នៅក្នុងមូលដ្ឋានទី៦០ និងមូលដ្ឋាន៨០ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងពាក់ព័ន្ធទៅនឹងអង្គហេតុទាក់ទងទៅនឹងជនជាតិវៀតណាម។ ហើយនៅក្នុងពេលជាមួយគ្នានេះ គាត់បានចោទ -- សុំឱ្យអង្គជំនុំជម្រះសម្រេចទៅលើអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ។

ឥឡូវយើងចូលដល់ប្រភេទទីបួន គឺមូលដ្ឋានពាក់ព័ន្ធទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីនេះ ដែលមានលើកឡើងនៅក្នុងមូលដ្ឋានទីពីរ ៨២ និង ៨៤ ដែលម្ចាស់បណ្តឹងសាទុក្ខជំទាស់ទៅនឹងការបកស្រាយរបស់សាលាដំបូងពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី។ ក៏ដូចជាពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ដែលកំណត់អំពីវិសាលភាពនៃការសំណារឿង០០២។ ហើយម្ចាស់បណ្តឹងសាទុក្ខហ្នឹងគឺគាត់យល់ច្រឡំទាំងស្រុងទៅលើពាក្យពេចន៍នៃសេចក្តីសម្រេច ក៏ដូចជាឧបសម្ព័ន្ធដែលបានដាក់បង្ហាញ។ ហើយនៅក្នុងមូលដ្ឋានទី៨៣នេះ គឺម្ចាស់បណ្តឹងសាទុក្ខលើកឡើងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេសគឺការបញ្ជូន ជម្លៀសជនជាតិចាមនៅក្នុងដំណាក់កាលទីពីរ។ គាត់ធ្វើមិនដឹងមិនឮទៅនឹងអ្វីដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើអង្គហេតុទាំងនេះ។ ឥឡូវនេះយើងសូមចូលមកដល់អំពីវិសាលភាពនៃភស្តុតាងម្តង។

នៅក្នុងមូលដ្ឋានទីបី ម្ចាស់បណ្តឹងសាទុក្ខដំបូងគាត់បានអះអាងថា សាលាដំបូងមានកំហុសនៅក្នុងការសម្អាងទៅលើអង្គហេតុដែលស្ថិតនៅក្រៅពេលវេលា ក៏ដូចជាស្ថិតនៅក្រៅវិសាលភាពពេលវេលាវិសាលភាពភូមិសាស្ត្រនៃដីកាដំណោះស្រាយ។ ទីមួយ ត្រូវបញ្ជាក់អំពីបរិបទនេះ, ទីពីរ ត្រូវបង្ហាញឱ្យឃើញដោយសម្អាងទៅលើធាតុផ្សំទាំងអស់ ជាពិសេសបង្ហាញពីធាតុចេតនា។ ហើយទីបី គឺត្រូវបង្ហាញអំពីបែបបទពាក់ព័ន្ធទាំង អស់។ យើងខ្ញុំសូមលើកឡើងថាការអះអាងនេះគួរតែត្រូវច្រានចោលតែម្តងទៅ ដោយសារតែការលើកឡើងវាខុស។ ម្ចាស់បណ្តឹងមិនបានគាំទ្រទៅដល់បណ្តឹងសាទុក្ខនេះទេ។ តាមការពិតទៅ គឺគាត់គ្រាន់តែយោងទៅលើដីកាដំណោះ -- សារណានៃដីកាដំណោះស្រាយតែប៉ុណ្ណោះ។ ហើយគាត់បានលើកថាអង្គជំនុំជម្រះនេះគឺថាមានសិទ្ធិយោងទៅលើប្រភេទនៃភស្តុតាងទាំងអស់។ ហើយក្នុងករណីណាក៏ដោយ គោលការណ៍នេះគឺត្រូវបានទទួលយកដោយតុលាការអាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ,អេស.ស៊ី.អេស.អិល ក៏ដូចជា អាយ.ស៊ី.ស៊ី ហើយក៏បានយោងទៅលើចំណុចមួយ

ចំនួននៅក្នុងសារណាឆ្លើយតបនេះដែរ។

[១៦:៤៥:៥៩]

ហើយក្រៅពីនេះទៀត មូលដ្ឋានទីបី ១១២, ១៨៨ ម្ចាស់បណ្តឹងសាទុក្ខចោទប្រកាន់ថាវិសាលភាពនៃអង្គហេតុ ក៏ដូចជាអង្គហេតុទាក់ទងទៅនឹងខ្មែរក្រោម ពុទ្ធសាសនិក ស្ថិតនៅខាងក្រៅវិសាលភាពស្រុកត្រាំកក់។ ហើយអង្គហេតុទាំងអស់នេះមិនបានបំពេញគោលបំណងណាមួយទេ។ ម្ចាស់បណ្តឹងសាទុក្ខគឺមានកំហុសនៅក្នុងការអះអាងនីមួយៗ ខុសទាំងអស់។ ទីមួយ គាត់យល់ច្រឡំទៅលើវិសាលភាពនៃឧក្រិដ្ឋកម្ម ដែលថាអង្គហេតុទាំងអស់ដែលសាលាដំបូងនេះ ធ្វើការផ្តន្ទាទោសមកលើរូបគាត់នោះ។ ឧទាហរណ៍និយាយអំពីពលកម្មដោយបង្ខំនៅភ្នំក្រោល យើងបាន -- ខ្ញុំបានលើកឡើងនៅខាងដើមនេះ។ វិសាលភាពនៃសំណុំរឿង០០២/០២ គឺវាស្ថិតនៅខាងក្រៅពីមូលដ្ឋានឧក្រិដ្ឋកម្ម រួមមានក្នុងនោះគឺអង្គហេតុដែលតម្រូវឲ្យបង្ហាញអំពីធាតុផ្សំផ្លូវច្បាប់ជារួមតែម្តង។

ដូច្នេះ ដោយសារតែអង្គហេតុមិនមែនជាផ្នែកមួយនៃឧក្រិដ្ឋកម្មនេះ មិនមែនមានន័យថាវាមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២នោះទេ។ ទីពីរ តុលាការកំពូលបានបានពន្យល់នៅក្នុងសំណុំរឿង០០២/០១មកហើយ ហើយយើងខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា បញ្ហានេះគឺជាបញ្ហាមួយដែលយើងអាចយល់បានជាទូទៅទាំងអស់គ្នា។ ម្ចាស់បណ្តឹងសាទុក្ខព្យាយាម គិតថាចងភ្ជាប់ភស្តុតាងទាំងនេះ ហើយរួចហើយអះអាងថាភស្តុតាងទាំងនេះ គឺស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ប៉ុន្តែដូចជាធ្វើមិនដឹងមិនឮលើភស្តុតាងដែលទាក់ទងទៅនឹងអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពផ្លូវច្បាប់ទៅវិញនោះ។ ដូច្នេះសាលាដំបូងមិនបានប្រព្រឹត្តកំហុសអីទេ ម្ចាស់បណ្តឹងសាទុក្ខខ្លួនឯងដឹងច្បាស់ហើយ ហើយអង្គជំនុំជម្រះមិនបានធ្វើការផ្តន្ទាទោសគាត់ឲ្យលើសពីវិសាលភាពនៃឧក្រិដ្ឋ មូលដ្ឋានឧក្រិដ្ឋកម្មនោះទេ។ ឧទាហរណ៍ ភស្តុតាងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិកស្ថិតនៅខាងក្រៅស្រុកតាំងកក់ ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់ប.ក.ក ប្រឆាំងមកលើពុទ្ធសាសនិក ក្នុងគោលបំណង -- នេះពាក់ព័ន្ធទៅនឹងគោលបំណងបង្ហាញអំពីការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម។ ហើយនៅក្នុងមធ្យោបាយដូចគ្នា គឺថាវាគួរអស្ចារ្យដែលយើងយោងទៅលើភស្តុតាងពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលថាបានប្រព្រឹត្តឡើងប្រឆាំងមកលើជនជាតិវៀតណាម ហើយដែលក្នុងនោះគឺថា ខ្មែរក្រោមក៏ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ នេះផងដែរ។

ប្រសិនណាជាលោកប្រធាន ឬក៏អង្គជំនុំជម្រះមិនមានសំណួរអីទេ ខ្ញុំក៏សុំបញ្ចប់សារណារបស់ខ្ញុំ

ត្រឹមនេះចុះ។

**ប្រធានអង្គជំនុំៈ**

ខាងអង្គជំនុំជម្រះអត់មានសំណួរអីទេនៅពេលនេះ។ ហើយសូមបញ្ជាក់ថា ថ្ងៃទី១នេះ គឺយើងចប់នៅពេលនេះ។ អ៊ីចឹងស្អែកយើងនឹងបន្តនៅវេលាម៉ោងប្រាំបួនព្រឹកតទៀត។ ដូច្នេះ គឺសូមខាងអនុរក្សពន្ធនាគារហ្នឹងគឺសូមនាំជនជាប់ចោទទៅទីកន្លែងវិញ។ ហើយថ្ងៃស្អែកព្រឹក សូមអញ្ជើញនាំជនជាប់ចោទមកកន្លែងរបស់ជនជាប់ចោទវិញ នៅពេលវេលាដូចដែលការកំណត់ខាងដើមអ៊ីចឹង។

អ៊ីចឹងតុលាការប្រកាសសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:៤៩នាទី)*